ADB

# យុទ្ធសាស្ត្រឆ្នាំ ២០២០

## ក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែង
## របស់ធនាគារអភិវឌ្ឍន៍អាស៊ី
## ឆ្នាំ ២០០៨-២០២០

**ធនាគារអភិវឌ្ឍន៍អាស៊ី**

ADB

# យុទ្ធសាស្ត្រឆ្នាំ ២០២០

## ក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែង

## របស់ធនាគារអភិវឌ្ឍន៍អាស៊ី

## ឆ្នាំ ២០០៨-២០២០

ធនាគារអភិវឌ្ឍន៍អាស៊ី

© ២០០៨ ធនាគារអភិវឌ្ឍន៍អាស៊ី

រក្សាសិទ្ធិគ្រប់យ៉ាង  បោះពុម្ពឆ្នាំ ២០០៨

បោះពុម្ពនៅ Philippines

ទិន្នន័យចុះបញ្ជីក្នុងការបោះពុម្ព

សន្និធិបោះពុម្ពលេខ PRF១៣៧៩០៨

ធនាគារអភិវឌ្ឍន៍អាស៊ី
យុទ្ធសាស្ត្រ ឆ្នាំ ២០២០: ក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី  ឆ្នាំ ២០០៨-២០២០
Mandaluyong City, Philippines:  ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៨

១.ក្របខ័ណ្ឌយុទ្ធសាស្ត្រ          I.  ធនាគារអភិវឌ្ឍន៍អាស៊ី

ធនាគារអភិវឌ្ឍន៍អាស៊ី  លើកទឹកចិត្តក្នុងការបោះពុម្ព  ឬថតចម្លងព័ត៌មានសម្រាប់តែការប្រើប្រាស់ផ្ទាល់ខ្លួន  និងមិនមែនសំរាប់ធ្វើពាណិជ្ជកម្ម  ហើយត្រូវមានការទទួលស្គាល់ត្រឹមត្រូវពី  ADB ។ អ្នកប្រើប្រាស់  មិនអនុញ្ញាតឱ្យលក់  និងចែកចាយបន្ត  ឬចម្លងឯកសារសំរាប់ធ្វើពាណិជ្ជកម្ម  ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពី ADB ឡើយ ។

ពាក្យថា  "ប្រទេស"  ដែលប្រើក្នុងអត្ថបទរបស់ ADB  យោងទៅលើប្រទេសជាសមាជិករបស់ខ្លួន  ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈណាមួយរបស់ ADB ចំពោះអធិបតេយ្យភាព ឬឯករាជ្យភាពរបស់ប្រទេសជាសមាជិកខ្លួនឡើយ ។

6 ADB Avenue Mandaluyong City
1550 Metro Manila Philippines
Tel: +63 632 4444
Fax: +63 636 4444
Website: www.adb.org

ដើម្បីទទួលបានឯកសារ សូមទាក់ទង :

នាយកដ្ឋានទំនាក់ទំនងផ្នែកខាងក្រៅ
Fax: +63 2 636 2648
E-mail: adbpub@adb.org

នៅក្នុងប្រទេសជាសមាជិកំពុងអភិវឌ្ឍន៍ផ្សេងៗគ្នារបស់  ADB  ឬស្សី  មានបង្កប់អត្ថន័យវិជ្ជមានជាច្រើន ។  នៅទូទាំងតំបន់អាស៊ី-ប៉ាស៊ីហ្វិក  ឬស្សីតំណាងឱ្យមិត្តភាព  សាមគ្គីភាព  និងភាពបត់បែនបាន ។  ដូច្នេះហើយ  ឬស្សី  ត្រូវបានបង្ហាញក្នុងរូបភាពជាជណ្តើរនៅលើក្របសៀវភៅនៃយុទ្ធសាស្ត្រឆ្នាំ  ២០២០  ពីព្រោះ  ប្រទេសក្នុងតំបន់អាចទាញយកអត្ថន័យទាំងនេះមកប្រើប្រាស់នៅពេលដែលខ្លួនឡើងជណ្តើរសំរាប់ធ្វើការអភិវឌ្ឍសេដ្ឋកិច្ចក្នុងភាពជាដៃគូជាមួយ  ADB ។

ចំពោះ ADB ឬស្សី ក៏ជានិមិត្តសញ្ញានៃការប្តេជ្ញាចិត្តផងដែរចំពោះបរិស្ថាន ព្រមទាំង ឫសគល់ដ៏ជ្រៅរបស់ខ្លួននៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ។

# អារម្ភកថា

យុទ្ធសាស្ត្រឆ្នាំ ២០២០ គឺជាលទ្ធផលនៃការពិគ្រោះយោបល់ដ៏ទូលំទូលាយមួយដែលបានធ្វើឡើងជាមួយប្រទេសជាសមាជិកចំនួន ៦៧ ។ យុទ្ធសាស្ត្រនេះ សម្រេចបាននូវគោលដៅនៃការបង្កើតតួនាទី និងទិសដៅយុទ្ធសាស្ត្រដ៏ច្បាស់លាស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី（ADB）ឆ្ពោះទៅកាន់ឆ្នាំ ២០២០។ យុទ្ធសាស្ត្រនេះ ក៏បានកំណត់គោលដៅរបស់ស្ថាប័នយើងដ៏រឹងមាំដើម្បីបំពេញនូវចក្ខុវិស័យស្តីអំពីតំបន់អាស៊ី-ប៉ាស៊ីហ្វិក គ្មានភាពក្រីក្រ ដែលជាចក្ខុវិស័យមួយអាចក្លាយទៅជាការពិតនៅឆ្នាំ ២០២០។ ផែនការរយៈពេលវែងរបស់យើងបានតម្រង់ផ្លូវ ADB ឱ្យក្លាយជាស្ថាប័នមួយដែលមានប្រសិទ្ធភាពបន្ថែមទៀត និងផ្អែកលើលទ្ធផលជាសំខាន់។

ដោយមានយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB ត្រៀមខ្លួនជាស្រេចដើម្បីបន្តដំណើរការទៅមុខ។ មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ហើយយើងបានប្តេជ្ញាធ្វើការងារទាំងនោះដើម្បីផ្លាស់ប្តូរ។ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ យើងនឹងផ្តោតការយកចិត្តទុកដាក់របស់យើងឡើងវិញទៅលើកម្មវិធីយុទ្ធសាស្ត្រសំខាន់បីក្នុងតំបន់: កំណើនសេដ្ឋកិច្ចចម្រុះ កំណើនប្រកបដោយនិរន្តរភាពបរិស្ថាន និងការធ្វើសមាហរណកម្មក្នុងតំបន់។ យើងនឹងកំណត់តួនាទីរបស់យើងឱ្យមានលក្ខណៈជាយុទ្ធ-សាស្ត្របន្ថែមទៀតក្នុងភាពជាដៃគូ និងភាពជាភ្នាក់ងារសម្រាប់ធ្វើការផ្លាស់ប្តូរ ដោយលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន អភិបាលកិច្ចល្អ សមធម៌យេនឌ័រ ដំណោះស្រាយចំណេះដឹង និងភាពជាដៃគូ។ យើងនឹងផ្តោតការយកចិត្តទុកដាក់ឡើងវិញទៅលើប្រតិបត្តិការក្នុងវិស័យដែលយើងមានឧត្តមភាព ក្នុងខណៈពេលដែលកំពុងដាក់ចេញញនូវដៃគូភាពថ្មីៗដើម្បីបង្កើនបណ្តាញសហហិរញ្ញប្បទាន និងចែករំលែកចំណេះដឹង។ យើងក៏នឹងធ្វើការគណនានូវតម្រូវការធនធាន និងកៀងគរមូលនិធិផងដែរស្របពេលដែលកំពុងធ្វើការធានានូវប្រសិទ្ធភាពនៃប្រតិបត្តិការ ។ ផែនការសម្រាប់លើកកម្ពស់ធនធានមនុស្ស និងជំនាញចម្រុះរបស់យើងកំពុងតែដំណើរការ ក្នុងខណៈពេលដែលយើងកំពុងតែធ្វើការប្រឹងប្រែងបន្ថែមទៀត ដើម្បីកាត់បន្ថយការចំណាយក្នុងការធ្វើពាណិជ្ជកម្មជាមួយយើង ដោយរក្សានូវការការពារបរិស្ថាន និងសង្គម ។

ភារកិច្ចនៅចំពោះមុខយើងមានភាពស្មុគស្មាញខ្លាំងក្លាថែមទៀត ក៏ប៉ុន្តែយើងមានការតាំងចិត្តក្នុងការចាប់ផ្តើមធ្វើការកែសម្រួលផ្នែកស្ថាប័ន និងប្រតិបត្តិការរបស់យើងរហូតដល់ឆ្នាំ ២០២០។ តំបន់អាស៊ី-ប៉ាស៊ីហ្វិក កំពុងតែមានការផ្លាស់ប្តូរយ៉ាងខ្លាំង ហើយ ADB ត្រូវតែរក្សាការបោះជំហានទៅមុខ និងសម្របខ្លួនឯងទៅតាមសេចក្តីចាំបាច់ និងតម្រូវការថ្មីៗរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក។ សព្វថ្ងៃនេះ យើងមានផែនការរយៈពេលវែងដ៏សមស្របមួយដើម្បីធ្វើការងារទាំងនេះ។ ដូច្នេះហើយ ខ្ញុំមានសេចក្តីរីករាយណាស់នឹងបង្ហាញជូននូវយុទ្ធសាស្ត្រឆ្នាំ ២០២០ ដល់ដៃគូអភិវឌ្ឍន៍របស់យើងនៅជុំវិញពិភពលោក ដោយសង្ឃឹមថា អ្នកទាំងអស់គ្នានឹងចូលរួមជាមួយយើងនៅក្នុងយុទ្ធសាស្ត្រឆ្នាំ ២០២០ ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យរបស់យើង ស្តីអំពីតំបន់អាស៊ី-ប៉ាស៊ីហ្វិក គ្មានភាពក្រីក្រ។

Haruhiko Kuroda

ប្រធាន

ធនាគារអភិវឌ្ឍន៍អាស៊ី

## បញ្ជីអក្សរកាត់

| | | |
|---|---|---|
| **ADB** | - | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **ADF** | - | មូលនិធិអភិវឌ្ឍន៍អាស៊ី |
| **DMC** | - | ប្រទេសសមាជិកកំពុងអភិវឌ្ឍន៍ |
| **GDP** | - | ផលិតផលក្នុងស្រុកសរុប |
| **LTSF I** | - | ក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែង សម្រាប់ឆ្នាំ ២០០១-២០១៥ |
| **MDG** | - | គោលដៅអភិវឌ្ឍន៍សហវត្សរ៍ |
| **MIC** | - | ប្រទេសដែលមានប្រាក់ចំណូលកណ្តាល |
| **NGO** | - | អង្គការមិនមែនរដ្ឋាភិបាល |
| **OCR** | - | ប្រភពធនធានធម្មតា |
| **PPP** | - | សមភាពកម្លាំងទិញ |
| **RCI** | - | កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មក្នុងតំបន់ |
| **SME** | - | សហគ្រាសខ្នាតតូច និងមធ្យម |
| **TA** | - | ជំនួយបច្ចេកទេស |

កំណត់ចំណាំ

នៅក្នុងរបាយការណ៍នេះ $ សំដៅលើប្រាក់ដុល្លាអាមេរិក

### ក្រុមការងារយុទ្ធសាស្ត្រឆ្នាំ ២០២០

| | |
|---|---|
| អគ្គនាយក | K.Sakai នាយកដ្ឋាន យុទ្ធសាស្ត្រ និង គោលនយោបាយ (SPD) |
| ប្រធានក្រុម | C.W. MacCormac នាយកជាន់ខ្ពស់ ផ្នែកផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងទំនាក់ទំនងអន្តរទីភ្នាក់ងារ របស់ SPD |
| សមាជិកក្រុម | S. Hattori អ្នកជំនាញជាន់ខ្ពស់ផ្នែកផែនការ និងគោលនយោបាយ របស់ SPD |
| | M. Senapaty អ្នកសេដ្ឋកិច្ចផែនការ និងគោលនយោបាយជាន់ខ្ពស់ របស់ SPD |
| | V. B. Tulasidhar អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ (កិច្ចសហប្រតិបត្តិការក្នុងតំបន់) នាយកដ្ឋានអាស៊ីខាងកើត |
| | L. Sillorequez ជំនួយការរដ្ឋបាល របស់ SPD |
| | V. Pacardo ទីប្រឹក្សាក្នុងស្រុក របស់ SPD |

| | |
|---|---|
| គណៈកម្មាធិការនាយក | K. Sakai ប្រធាន |
| | I. Ali ប្រធានសេដ្ឋវិទូ នាយកដ្ឋានសេដ្ឋកិច្ច និងស្រាវជ្រាវ |
| | S. Bajpai លេខាធិកា ការិយាល័យលេខាធិការ |
| | M. Kashiwagi ហិរញ្ញិក នាយកដ្ឋានរតនាគា |
| | M. Kawai ព្រឹទ្ធបុរស វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី |
| | J. W. Lee ប្រធាន ការិយាល័យសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ |
| | J. Miranda អគ្គនាយក នាយកដ្ឋានអាស៊ីកណ្ដាល និងខាងលិច |
| | H. S. Rao អគ្គនាយក នាយកដ្ឋានអាស៊ីខាងកើត |
| | X. Yao អគ្គនាយកស្ដីទី អគ្គនាយកដ្ឋានអភិវឌ្ឍន៍តំបន់ និងប្រកបដោយនិរន្តរភាព |

# មាតិកា


សេចក្តីសង្ខេប....................................................................................................................................

I. សេចក្តីផ្តើម ...................................................................................................................................... ១

II. ការកែប្រែតំបន់អាស៊ី-ប៉ាស៊ីហ្វិក.......................................................................................................... ៣

ការកែប្រែតំបន់ និងរចនាសម្ព័ន្ធជំនួយ ..................................................................................................... ៣

បញ្ហាប្រឈមខាងមុខ .......................................................................................................................... ៤

III. ទស្សនវិស័យ និងកម្មវិធីយុទ្ធសាស្ត្រ...................................................................................................... ១៣

IV. ដៃគូ និងភ្នាក់ងារសម្រាប់ធ្វើការផ្លាស់ប្តូរ.................................................................................................. ១៦

កត្តាជំរុញនូវការផ្លាស់ប្តូរ .......................................................................................................................... ១៦

ប្រទេសជាដៃគូអភិវឌ្ឍ.......................................................................................................................... ២០

វិស័យប្រតិបត្តិការស្នូល......................................................................................................................... ២៣

វិស័យប្រតិបត្តិការនានា ......................................................................................................................... ២៧

V. គោលដៅ និងសកម្មភាពការងារ ............................................................................................................. ៣០

ការផ្លាស់ប្តូររបស់ ADB ឆ្ពោះទៅឆ្នាំ ២០២០ : គោលដៅប្រតិបត្តិ .......................................................................... ៣០

ការផ្លាស់ប្តូររបស់ ADB ឆ្ពោះទៅឆ្នាំ ២០២០: គោលដៅស្ថាប័ន ............................................................................. ៣៣

ការគ្រប់គ្រងលើការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០: ក្របខ័ណ្ឌលទ្ធផលរបស់ ADB ................................................... ៣៥

ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផល............................................................................................................... ៣៧

ជំហានបន្ទាប់........................................................................................................................................ ៣៨

VI. ការផ្តល់ធនធានសម្រាប់ដំណើរការយុទ្ធសាស្ត្រ.......................................................................................... ៣៩

VII. សេចក្តីសន្និដ្ឋាន................................................................................................................................ ៤១

ឧបសម្ព័ន្ធទី ១ : សេចក្តីសង្ខេបស្តីអំពីការអភិវឌ្ឍតំបន់អាស៊ី-ប៉ាស៊ីហ្វិក......................................................... ៤២

ឧបសម្ព័ន្ធទី ២ : រចនាសម្ព័ន្ធនៃក្របខ័ណ្ឌលទ្ធផលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី.................................................... ៤៦

# សេចក្តីសង្ខេប

កំណើនសេដ្ឋកិច្ចដ៏លឿននៅតំបន់អាស៊ី ប៉ាស៊ីហ្វិក និងការផ្លាស់ប្តូរដ៏សំខាន់ៗ នៅក្នុងទ្រង់ទ្រាយអភិវឌ្ឍន៍ ជំនួយ និងហិរញ្ញវត្ថុ បានបង្កើតនូវតម្រូវការ និងកាលានុវត្តភាពសំរាប់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីរៀបចំកំណត់ទិសដៅយុទ្ធសាស្រ្តថ្មីមួយ។ ក្របខ័ណ្ឌយុទ្ធសាស្រ្តថ្មីរយៈពេលវែងសម្រាប់ឆ្នាំ ២០០៨-២០២០ (យុទ្ធសាស្រ្តឆ្នាំ ២០២០) នឹងក្លាយជាឯកសារផែនការរួមទូលំទូលាយមួយរបស់ ADB ហើយផ្តល់ឱ្យ ADB នូវតួនាទីដែលមានការពាក់ព័ន្ធ និងការច្នៃប្រឌិតមួយបន្ថែមទៀត នៅក្នុងការរៀបចំអនាគតរបស់តំបន់។ យុទ្ធសាស្រ្តឆ្នាំ ២០២០ នឹងមកជំនួសក្របខ័ណ្ឌយុទ្ធសាស្រ្តឆ្នាំ ២០០១-២០១៥។

ត្រឹមឆ្នាំ ២០២០ តំបន់អាស៊ី និងប៉ាស៊ីហ្វិក អាចឈានឆ្ពោះទៅកាន់កម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចខ្ពស់ជាងមុន។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលកំណើនបន្តកើនឡើង វាអាចបង្កើនការលំបាកថែមទៀតចំពោះអ្នកទាំងឡាយណាដែលមិនបានទទួលផលប្រយោជន៍ពីកំណើនទាំងនេះ។ ភាពលំអៀងនៃគម្លាត អាចនឹងកាន់តែធំនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក (DMCs) របស់ ADB។ ភាពលំអៀងនេះ និងតម្លៃបរិស្ថានដែលកំពុងតែកើនឡើង អាចចាប់ផ្តើមគំរាមកំហែងលើនិរន្តរភាពនៃការអភិវឌ្ឍន៍របស់ប្រទេសទាំងនោះ។ ជំពូកទី២នៃឯកសារនេះ នឹងអធិប្បាយអំពីការផ្លាស់ប្តូររូបរាងរបស់តំបន់ និងបញ្ហាប្រឈមខាងមុខ ។

ជំពូកទី ៣ និងជំពូកទី ៤ នឹងពិភាក្សាអំពីទិសដៅយុទ្ធសាស្រ្តថ្មី ដែលនឹងអាចឱ្យ ADB ដោះស្រាយបញ្ហាប្រឈមទាំងនោះ។ ក្រោមយុទ្ធសាស្រ្តឆ្នាំ ២០២០ ADB នឹងផ្លាស់ប្តូរខ្លួនឯងដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ដោយនៅតែរក្សាការប្តេជ្ញាចិត្តចំពោះការកាត់បន្ថយភាពក្រីក្រ ដែលជាគោលដៅដ៏ចម្បងរបស់ខ្លួនតាំងពីឆ្នាំ ១៩៩៩។ ចក្ខុវិស័យរួមរបស់ ADB ក្រោមយុទ្ធសាស្រ្តឆ្នាំ ២០២០ នឹងនូវតែបន្ត "តំបន់អាស៊ី-ប៉ាស៊ីហ្វិក គ្មានភាពក្រីក្រ" ហើយបេសកកម្មរបស់ខ្លួន នឹងជួយ DMCs ក្នុងការកាត់បន្ថយភាពក្រីក្រ និងកែលម្អស្ថានភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជន។

ADB នឹងសម្រេចឱ្យបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួន ដោយផ្តោតទៅលើកម្មវិធីយុទ្ធសាស្រ្តបំពេញបន្ថែមចំនួនបីគឺ កំណើនចម្រុះ កំណើនប្រកបដោយនិរន្តរភាពបរិស្ថាន និងការធ្វើសមាហរណកម្មក្នុងតំបន់។ ដើម្បីកៀងគរប្រភពធនធានឱ្យបានកាន់តែប្រសើរឡើង រួមទាំងការសន្សំ និងលំហូរចូលនៃមូលធន និងដើម្បីទទួលបាននូវលទ្ធផលជាអតិបរមាពីបទពិសោធន៍ដ៏វិសេសវិសាលក្នុងតំបន់ និងឧត្តមភាពរបស់ខ្លួននៅក្នុងក្របខ័ណ្ឌវិវត្តន៍នៃរចនាសម្ព័ន្ធជំនួយ ADB នឹងផ្តោតទៅលើកត្តាជំរុញនៃការផ្លាស់ប្តូរប្រាំគឺ (១) ការអភិវឌ្ឍន៍ និងប្រតិបត្តិការរបស់វិស័យឯកជន (២) អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព (៣) សមធមិយេនឌ័រ (៤) ដំណោះស្រាយចំណេះដឹង និង (៥) ដៃគូភាព។

ADB ក៏នឹងផ្តោតការយកចិត្តទុកដាក់ឡើងវិញផងដែរចំពោះកិច្ចប្រតិបត្តិការលើវិស័យឯកទេសស្នូលចំនួនប្រាំ ដែលទ្រទ្រង់កម្មវិធីរបស់ខ្លួន ឆ្លុះបញ្ចាំងតម្រូវការរបស់ DMCs និងឧត្តមភាពរបស់ ADB និងកិច្ចប្រឹងប្រែងដែលជួយបំពេញបន្ថែមដោយដៃគូអភិវឌ្ឍន៍ដូចជា : (១) ហេដ្ឋារចនាសម្ព័ន្ធ (២) បរិស្ថាន រួមទាំង បម្រែបម្រួលអាកាសធាតុ (៣) កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មក្នុងតំបន់ (៤) ការអភិវឌ្ឍផ្នែកហិរញ្ញវត្ថុ និង (៥) ការអប់រំ ។ នៅក្នុងវិស័យ

ផ្សេងៗទៀត ADB នឹងបន្តកិច្ចប្រតិបត្តិការណាដែលបានជ្រើសរើសតែប៉ុណ្ណោះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារដទៃទៀត។

ជំពូកទី ៥ នឹងអត្ថាធិប្បាយអំពីគោលដៅប្រតិបត្តិការ និងស្ថាប័ន ក្រោមយុទ្ធសាស្ត្រ ឆ្នាំ២០២០ រួមមាន ផែនការរបស់ ADB ដើម្បី : (១) មាន ៨០% នៃកិច្ចប្រតិបត្តិការរបស់ខ្លួននៅក្នុងវិស័យប្រតិបត្តិការស្នូលថ្មីត្រឹមឆ្នាំ ២០១២ (២) បង្កើនការអភិវឌ្ឍ និងកិច្ចប្រតិបត្តិការវិស័យឯកជននៅគ្រប់វិស័យប្រតិបត្តិការទាំងអស់ឱ្យបាន ៥០% នៃប្រតិបត្តិការប្រចាំឆ្នាំ ត្រឹមឆ្នាំ ២០២០ (៣) បង្កើនការគាំទ្រលើការអភិវឌ្ឍប្រកបដោយនិរន្តរភាពបរិស្ថាន រួមទាំងគម្រោងនានា ត្រូវកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីត និងដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ និង (៤) បង្កើនកិច្ចប្រតិបត្តិការវិស័យឯកជន និងវិស័យសាធារណៈ នៅថ្នាក់តំបន់ និងអនុតំបន់ ឱ្យបានយ៉ាងតិច ៣០% នៃសកម្មភាពទាំងអស់ ត្រឹមឆ្នាំ ២០២០។

យុទ្ធសាស្ត្រឆ្នាំ ២០២០ ក៏នឹងតម្រូវឱ្យមានការផ្លាស់ប្តូរផ្នែកស្ថាប័នផងដែរ។ យុទ្ធសាស្ត្រនេះ នឹងបង្កើតឡើងវិញនូវការតភ្ជាប់គ្នាក្នុងក្របខ័ណ្ឌប្រតិបត្តិគោលយោបាយទាំងមូលរបស់ ADB ។ ការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០ នឹងមានភាពចាំបាច់ក្នុងការផ្លាស់ប្តូរក្នុងជំនាញចម្រុះនៃធនធានមនុស្សរបស់ ADB ដែលតម្រូវឱ្យមានការអនុវត្តឱ្យបានល្អបំផុតក្នុងការជ្រើសរើស និងការថែរក្សាទុកបុគ្គលិក។ ADB ក៏នឹងកែតម្រូវរចនាសម្ព័ន្ធអង្គភាពរបស់ខ្លួនផងដែរ ដើម្បីឆ្លើយតបទៅនឹងការពង្រីកសកម្មភាព និងសេវាកម្មថ្មីៗ ជាពិសេស នៅក្នុងផ្នែកប្រតិបត្តិការវិស័យឯកជន សេវាហិរញ្ញវត្ថុ ការគ្រប់គ្រងចំណេះដឹង និងកិច្ចប្រតិបត្តិការផ្នែកបរិស្ថាន។

ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ថ្នាក់ដឹកនាំរបស់ ADB នឹងអង្កេតតាមដាន និងរាយការណ៍អំពីប្រសិទ្ធភាពការងាររបស់ខ្លួន ដោយប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលថ្មី ជាមួយនឹងវិធានការសំខាន់ៗចំនួនបួនគឺ :

(i) លទ្ធផលតំបន់: នឹងត្រូវធ្វើការវាយតម្លៃលើសកម្មភាពអភិវឌ្ឍន៍ទូទៅរបស់តំបន់ តាមរយៈគោលដៅអភិវឌ្ឍន៍សហវត្សរ៍ (MDGs) និងសូចនាករនានា។

(ii) ការរួមចំណែកចំពោះលទ្ធផលប្រចាំប្រទេស: នឹងចាប់យកតួនាទីរបស់ ADB នៅក្នុងវិស័យឯកទេសស្នូលទាំងប្រាំរបស់ខ្លួន។

(iii) ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ: នឹងយកសូចនាករដែលប្រើប្រាស់ដោយធនាគារអភិវឌ្ឍពហុភាគីភាគច្រើនសម្រាប់សកម្មភាពការងាររបស់ ADB និង

(iv) ប្រសិទ្ធភាពរបស់អង្គភាព: នឹងផ្តោតលើសកម្មភាពការងារនៅក្នុងវិស័យជាគន្លឹះនានា។

ជំពូកទី ៦ នឹងពិភាក្សាអំពីការវិនិយោគទុនដែលតម្រូវឱ្យមានការដោះស្រាយបញ្ហាប្រឈមចំពោះការអភិវឌ្ឍសំខាន់ៗខាងមុខ និងតម្រូវការសំរាប់ ADB ឱ្យមានធនធានគ្រប់គ្រាន់ជាលក្ខណៈសម្បទាន និងមិនសម្បទាន ដើម្បីគាំទ្រនូវតួនាទីនាំមុខរបស់ខ្លួនជាដៃគូអភិវឌ្ឍន៍ហិរញ្ញវត្ថុនៅក្នុងតំបន់។

តាមរយៈយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB នឹងរួមចំណែកកែលម្អសុខមាលភាពសង្គមទាំងក្នុងតំបន់ និងលើពិភពលោក។ ការបញ្ចប់ភាពក្រីក្រនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក នឹងក្លាយទៅជាសមិទ្ធផលជាប្រវត្តិសាស្ត្រមួយ ហើយវាមានសារៈសំខាន់ណាស់ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសត្សវ៍ជាសកល។ ការបង្កើតទីផ្សារសេដ្ឋកិច្ចទូទាំងតំបន់ នឹងជួយធ្វើសុខដុម-នីយកម្មកំណើនក្នុងចំណោមប្រទេស DMCs ហើយនឹងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចពិភពលោកទាំងមូល តាមរយៈការពង្រីកពាណិជ្ជកម្ម និងការវិនិយោគទុន។ ការធ្វើទំនើបកម្មវិស័យហិរញ្ញវត្ថុក្នុងតំបន់ នឹងជួយឱ្យប្រទេស DMCs មានភាពម្ចាស់ការខ្លួនឯងក្នុងការផ្តល់ហិរញ្ញប្បទានចំពោះការអភិវឌ្ឍរបស់ខ្លួន ហើយរួមចំណែកដល់ស្ថេរភាពហិរញ្ញវត្ថុពិភពលោក។ ការសម្របសម្រួលគោលនយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់បានទូលំទូលាយ និងកាលើកកំពស់អភិបាលកិច្ច នៅក្នុងស្ថានភាពដ៏ផុយស្រួយ នឹងជួយសម្រួលស្ថេរភាពក្នុងតំបន់ ហើយជួយជម្រុញឱ្យមានការចូលរួមទាំងក្នុង និងក្រៅតំបន់ ទាំងវិស័យសាធារណៈ និងវិស័យឯកជន។ ការរីកចម្រើនដ៏គួរឱ្យកត់សម្គាល់លើប្រសិទ្ធផលថាមពល និងវិធានការនានា ដើម្បីដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុនៅទូទាំងតំបន់អាស៊ី ប៉ាស៊ីហ្វិក នឹងបង្កើតបានជាលទ្ធផលវិជ្ជមាន ដែលឥទ្ធិពលរបស់វានឹងផ្តល់ផលប្រយោជន៍ឆ្លងតំបន់ និងមនុស្សជំនាន់ក្រោយ។

# I. សេចក្តីផ្តើម

ការផ្លាស់ប្តូរគឺជាចំណុចដ៏សំខាន់នៃបទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ទោះជាយ៉ាងណាក៏ដោយ ការត្រៀមខ្លួនរបស់ ADB ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ ការទទួលយកកាលានុវត្តភាពថ្មីៗ និងការធ្វើដំណើរអោយស្របទិសដៅថ្មីកម្រមានភាពជាប់ពាក់ព័ន្ធច្រើនដូចនៅក្នុងទសវត្សរ៍ទីមួយនៃសតវត្សរ៍ថ្មីនេះណាស់។ កំណើននៅក្នុងតំបន់មានលើសពីការរំពឹងទុកយ៉ាងច្រើន ដែលក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ឆ្នាំ ២០០១-២០១៥ (LTSF I)[១] បានព្យាករណ៍ទុកកាលពីប្រាំពីឆ្នាំកន្លងទៅ។ សេដ្ឋកិច្ចបានផ្លាស់ប្តូរ បទពិសោធន៍ជាច្រើនបានទទួល ហើយរចនាសម្ព័ន្ធជំនួយ និងហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងវិញ។ ជាមួយនឹងការផ្លាស់ប្តូរដ៏ធំធេងកំពុងស្ថិតនៅខាងមុខយើង ADB ត្រូវការយុទ្ធសាស្ត្រថ្មីមួយដើម្បីនាំផ្លូវស្ថាប័នខ្លួនឆ្ពោះទៅកាន់តំបន់អាស៊ីថ្មី ឆ្នាំ ២០២០។ ADB ត្រូវតែធ្វើការសម្រេចចិត្ត និងរៀបចំអនាគតរបស់តំបន់ និងមុខងាររបស់ខ្លួននៅក្នុងតំបន់នេះ។

LTSF I ត្រូវបានបង្កើតឡើងដោយផ្អែកលើការយល់ដឹងមួយផ្អែកពីវិបត្តិហិរញ្ញវត្ថុអាស៊ី ដែលកើតឡើងនៅឆ្នាំ ១៩៩៧ គឺជាពេលដែលប្រជាជនជាច្រើន ដែលមានជីវភាពងើបផុតពីខ្សែបន្ទាត់នៃភាពក្រីក្រ បានត្រឡប់ទៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រវិញ។ ដូច្នេះ LTSFI បានផ្តោតការយកចិត្តទុកដាក់ទៅលើអ្នកក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រទាំងឡាយ។ សេដ្ឋកិច្ចក្នុងតំបន់មិនគ្រាន់តែស្ទុះឡើងវិញទេ តែថែមទាំងបានលូតលាស់ក្នុងជំហានមួយយ៉ាងអស្ចារ្យ ហើយបានលើកស្ទួយជីវភាពប្រជាជនជាច្រើនជាងការរំពឹងទុក ឱ្យមានប្រាក់ចំណូលលើសពី ១ ដុល្លា ដែលជាបន្ទាត់នៃភាពក្រីក្រ[២]។ ទោះបីជាយ៉ាងណាក៏ដោយ សព្វថ្ងៃនេះ នៅមានប្រជាជនជាច្រើន ដែលមានលទ្ធភាពតិចតួច ឬមិនមានលទ្ធភាពទទួលផលប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចនេះទេ។ គំលាតប្រាក់ចំណូល និងកម្រិតជីវភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (DMCs) បានកើនឡើងយ៉ាងលឿន និងធំជាងមុន ហើយគួរឱ្យព្រួយបារម្ភជាងការរំពឹងទុករបស់ LTSF I។ កំណើនសេដ្ឋកិច្ច ធ្វើឱ្យវិនាសហិនហោចដល់បរិស្ថាន ជំរុញឱ្យមានការបាត់ធនធានធម្មជាតិ និងថាមពលនៅក្នុងតំបន់ និងបង្កើនដល់បម្រែបម្រួលអាកាសធាតុជាសកល។ ទោះបីជាវាដាច់ដោយឡែកតែឯង និងបូករួមជាមួយបញ្ហាដទៃទៀតក៏ដោយ បញ្ហាទាំងនេះ នឹងធ្វើឱ្យអន្តរាយដល់កំណើនសេដ្ឋកិច្ច ហើយអាចស៊ីច្រោះផលចំណេញពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកាត់បន្ថយផលប្រយោជន៍នានានៅពេលអនាគត។

---

[១] ADB ២០០១ *ការរំកិលរបៀបវារៈកាត់បន្ថយភាពក្រីក្រឆ្ពោះទៅមុខ: ក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០១-២០១៥)* ម៉ានីល ។

[២] រង្វាស់នៃភាពក្រីក្រ ផ្អែកលើខ្សែបន្ទាត់នៃភាពក្រីក្រជាលក្ខណៈអន្តរជាតិ ប្រកាន់យកនូវតម្លៃពិតប្រាកដនៃខ្សែបន្ទាត់ភាពក្រីក្រ ដោយប្រៀបធៀបរវាងប្រទេសជាច្រើន ហើយដែលស្ថិតនៅនឹង។ ស្តង់ដារ ១ដុល្លា ក្នុងមួយថ្ងៃ ដែលបានស្ថាបស្ទង់នៅឆ្នាំ ១៩៨៥ និងបានកែតម្រូវទៅតាមរូបិយវត្ថុក្នុងស្រុកដោយប្រើសមភាពកម្លាំងទិញ (PPP) ត្រូវបានជ្រើសរើសដោយ *របាយការណ៍អភិវឌ្ឍន៍ពិភពលោក ១៩៩០: ភាពក្រីក្រ* របស់ធនាគារពិភពលោក ព្រោះវាជាប្រភេទនៃខ្សែបន្ទាត់ភាពក្រីក្រនៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប។ ការចេញផ្សាយដំបូងនៃសូចនាករអភិវឌ្ឍន៍ពិភពលោកប្រើប្រាស់ PPP ពីតារាងពិភពលោក Penn។ ការចេញផ្សាយថ្មីៗនេះ ប្រើប្រាស់ការប៉ាន់ប្រមាណ PPP ឆ្នាំ ១៩៩៣ ដែលបង្កើតឡើងដោយធនាគារពិភពលោក។

ស្របពេលជាមួយគ្នានេះ ប្រសិនបើមានការទាញយកផលប្រយោជន៍ឱ្យបានពេញលេញពីកាលានុវត្តភាពថ្មីៗដែលបានបង្កើតឡើង គឺអាចជួយដោះស្រាយបញ្ហាទាំងនេះបាន។ ឧទាហរណ៍ ប្រសិនបើមានការគាំទ្រ ឬការលើកទឹកចិត្ត កម្លាំងចលករឆ្ពោះទៅកាន់កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មក្នុងតំបន់ (RCI) អាចជួយទ្រទ្រង់ និងបង្កើនល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច។ ទីផ្សារមូលធនអន្តរជាតិដែលចាប់កម្រើកឡើងវិញរួចជាស្រេចនៅពេលមានអំណោយផល អាចជួយដល់ការអភិវឌ្ឍហិរញ្ញវត្ថុ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាជនទូទៅ។ ការសន្សំដ៏ធំនៅក្នុងតំបន់ អាចនឹងយកមកប្រើប្រាស់ឱ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងប្រទេស DMCs។ សន្ទុះដ៏ខ្លាំងក្លារបស់វិស័យឯកជន នឹងផ្តល់នូវកាលានុវត្តភាពកាន់តែច្រើនថែមទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

ក្របខ័ណ្ឌយុទ្ធសាស្ត្រថ្មីសម្រាប់ឆ្នាំ ២០០៨-២០២០ (យុទ្ធសាស្ត្រឆ្នាំ ២០២០) នឹងចាប់យកកាលានុវត្តភាពទាំងនេះ ហើយបើកផ្លូវថ្មីឱ្យ ADB អនុវត្តឧត្តមភាពរបស់ខ្លួននៅក្នុងរចនាសម្ព័ន្ធជំនួយអន្តរជាតិដែលបានវិវត្តន៍តាំងពី LTSF I មកម្លេះ។ យុទ្ធសាស្ត្រ ឆ្នាំ ២០២០ ក៏នឹងជួយបំពេញនូវតម្រូវការសំខាន់ផ្សេងៗទៀតផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការរីកសាយនូវឯកសារយុទ្ធសាស្ត្រនៅក្នុង ADB ពេលខ្លះក៏អាចបណ្តាលឱ្យមានផលវិបាកផងដែរ ដូចជា ភាពច្រំដែល ភាពត្រួតស៊ីគ្នា និងភាពច្របូកច្របល់ ដែលបណ្តាលមកពីការកម្រិតក្នុងការធ្វើផែនការ ការអនុវត្ត និងឋានានុក្រមយុទ្ធសាស្ត្រ [៣] ដែលមានភាពស្មិតរមួតជាប់គ្នា។ ADB ត្រូវការឯកសារយុទ្ធសាស្ត្រដ៏ប្រសើរបំផុតដែលលាតត្រដាងនូវទិសដៅយុទ្ធសាស្ត្រច្បាស់លាស់ និងស្របគ្នា ហើយអាចផ្តល់នូវក្របខ័ណ្ឌសម្រាប់ធ្វើផែនការ និងផ្តល់ហិរញ្ញប្បទានចំពោះប្រតិបត្តិការ ការចាត់ចែង និងដំណើរការសកម្មភាពរបស់ខ្លួន។

សេចក្តីសម្រេចចិត្តនានាដែលមានការពាក់ព័ន្ធនៅក្នុងការបង្កើតយុទ្ធសាស្ត្រឆ្នាំ ២០២០ បានកើតមានឡើងបន្ទាប់ពីមានការពិភាក្សាគ្នាយ៉ាងល្អិតល្អន់។ ក្រុមពិភាក្សាដែលមានបុគ្គលសំខាន់ៗបានបង្កើតឡើងនៅខែ មិថុនា ឆ្នាំ ២០០៦ ដើម្បីវាយតម្លៃអំពីអនាគតរបស់តំបន់ និងការជះឥទ្ធិពលទៅលើតួនាទីរបស់ ADB រហូតដល់ឆ្នាំ ២០២០។ របាយការណ៍របស់ក្រុមពិភាក្សា[៤] ដែលបានដាក់ស្នើជូនទៅប្រធានធនាគារ នាខែ មីនា ឆ្នាំ ២០០៧ គឺជាផ្នែកដ៏សំខាន់មួយនៅគ្រប់ការពិភាក្សាជាបន្តបន្ទាប់ ហើយរបាយការណ៍នោះ ត្រូវបានធ្វើសេចក្តីថ្លែងការណ៍ឡើងដោយក្រុមប្រឹក្សាភិបាល នៅក្នុងកិច្ចប្រជុំលើកទី ៤០ នាខែ ឧសភា ឆ្នាំ ២០០៧។ ការពិភាក្សាដ៏ទូលំទូលាយជាច្រើនបានធ្វើឡើងរវាងក្រុមប្រឹក្សានាយក គណៈគ្រប់គ្រង បុគ្គលិក ភាគីពាក់ព័ន្ធទាំងឡាយ អ្នកតំណាង DMCs ព្រមទាំងវិស័យឯកជន និងសង្គមស៊ីវិលផងដែរ។ អនុសាសន៍នៅក្នុងយុទ្ធសាស្ត្រឆ្នាំ ២០២០ បានទទួលគុណប្រយោជន៍ពីការសិក្សា ការវិភាគ ការវាយតម្លៃ និងការស្រាវជ្រាវជាច្រើន ដែលបានលើកឡើងថា ADB អាចជួយតំបន់កាន់តែប្រសើរឡើង និងអាចទទួលបានលទ្ធផលកាន់តែធំធេងឡើង លុះត្រាតែខ្លួនត្រូវមានការផ្លាស់ប្តូរប្រកបដោយការអភិវឌ្ឍ។

---

[៣] ADB ២០០៨: *ការសិក្សាវាយតម្លៃពិសេសនៃក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែង : មេរៀនពីការអនុវត្តន៍ (២០០១-២០០៦)* ម៉ានីល ។

[៤] ក្រុមបុគ្គលសំខាន់ៗ ២០០៧: *ឆ្ពោះទៅរកធនាគារអភិវឌ្ឍន៍អាស៊ីថ្មីនៅក្នុងតំបន់អាស៊ីថ្មី* ម៉ានីល : ADB ។

# II. ការកែប្រែតំបន់អាស៊ី ប៉ាស៊ីហ្វិក

## ការកែប្រែតំបន់ និងរចនាសម្ព័ន្ធជំនួយ

សេដ្ឋកិច្ចក្នុងតំបន់ បានរីកដុះដាលក្នុងជំហានមួយគួរឱ្យកត់សំគាល់ ក្នុងរយៈពេលពីរបីទសវត្សរ៍ចុងក្រោយនេះ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និងឆ្នាំ ១៩៩០ ផលិតផលក្នុងស្រុកសរុបពិតប្រាកដក្នុងម្នាក់ (GDP) បានកើនឡើងជាង ៦០% ជារៀងរាល់ឆ្នាំនៅអាស៊ីខាងកើត និង ៣% នៅអាស៊ីខាងត្បូង ខណៈពេលដែលតំបន់កំពុងអភិវឌ្ឍដទៃទៀតនៅលើពិភពលោកមិនបានខិតខំប្រឹងប្រែងក្នុងការបង្កើនប្រាក់ចំណូលក្នុងមនុស្សម្នាក់ៗ[៥] របស់ខ្លួនទាល់តែសោះ ។ កំណើន GDP របស់តំបន់បានកើនឡើងម្តងទៀត ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៦ គឺមានមធ្យមភាគ ៦% ក្នុងមួយឆ្នាំៗចាប់តាំងពីមានវិបត្តិហិរញ្ញវត្ថុអាស៊ី។ ការរួមចំណែកនៃការនាំចេញនៅតំបន់អាស៊ីបានឡើងពី ១៦% នៅក្នុងទសវត្សរ៍ ឆ្នាំ ១៩៨០ មក ២៧% នាពេលបច្ចុប្បន្ននេះ។ តំបន់នេះមានប្រាក់បម្រុងច្រើន និងអត្រាសន្សំខ្ពស់ជាងគេបំផុតនៅលើពិភពលោក។ ជាមួយនឹងការរីកចម្រើននៃវិស័យសេដ្ឋកិច្ចដែលមាននិរន្តរភាពក្នុងតំបន់ភាគច្រើននៅអាស៊ីនោះ ប្រទេស DMCs របស់ ADB តំណាងឱ្យសេចក្តីសង្ឃឹមដ៏មុតមាំបំផុតរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៍ (MDGs)[៦]។

កំណើនដ៏ឆាប់រហ័ស បានធ្វើឱ្យមានការផ្លាស់ប្តូរជាសារវន្តនៅក្នុងតំបន់ ចាប់តាំងពី ADB បានដាក់ចេញនូវ LTSF I។ តថភាពក្នុងតំបន់ថ្មីនេះ រួមមាន ការកើនឡើងនូវប្រាក់ចំណូលព្រមជាមួយនឹងភាពក្រីក្រខ្លាំងបានធ្លាក់ចុះ លំហូរចូលមូលធនខ្ពស់ និងមាននិរន្តរភាព សហត្ថិភាព (នៅក្នុងតំបន់ដែលខ្វះខាតមូលធនកាលពីមុន) នៃអត្រាសន្សំខ្ពស់និងតម្រូវការមិនអាចបំពេញបានសម្រាប់ការវិនិយោគទុនសាធារណៈនិងឯកជន ការរីកដុះដាលនៃពាណិជ្ជកម្មនិងការវិនិយោគក្នុងតំបន់ និងការលើកកម្ពស់ជំនាញគ្រប់គ្រងនិងបច្ចេកវិទ្យារបស់ប្រជាជន។ ចំនួនប្រជាជនបានកើនឡើងយ៉ាងខ្លាំងនៅតាមទីក្រុង និងទីប្រជុំជន។ ហើយក៏មានការកើនឡើងយ៉ាងខ្លាំងផងដែរ នៃចំនួនប្រជាជនដែលមានជីវភាពថ្នាក់កណ្តាល[៧] ដែលជាធនធានសន្សំ និងចំណាយ។ ត្រឹមឆ្នាំ ២០២០ ពាណិជ្ជកម្មក្នុងតំបន់អាចមានទំហំស្មើនឹងមួយភាគបីនៃពាណិជ្ជកម្មពិភពលោក ។ ចំណែក GDP ក្នុងតំបន់ គិតជាប្រាក់ដុល្លាតំណាង អាចកើនឡើងទ្វេដងរហូតដល់មួយភាគបួន ឬប្រហែលជា ៤៥% នៃសមភាពកម្លាំងទិញ (PPP)។ ប្រាក់សន្សំរបស់តំបន់ អាចនៅតែមានចំនួនច្រើនដូចប្រាក់បម្រុងបរទេសរបស់ខ្លួនដែរ។ ប្រជាជនប្រហែល ៩០% អាចនឹង

---

[៥] ធនាគារពិភពលោក ២០០៥: របាយការណ៍តាមដានសកល វ៉ាស៊ីនតោន DC ។

[៦] គោលដៅអភិវឌ្ឍន៏សហវត្សរ៍ គឺជាកម្រងគោលដៅប្រាំបីបញ្ចូលគ្នា ដែលអាចវាស់វែងបាន ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមក្នុងការអភិវឌ្ឍរបស់ពិភពលោក ភាគច្រើនត្រឹមឆ្នាំ ២០១៥ ដោយប្រើបទដ្ឋាន ឆ្នាំ១៩៩០។ គោលដៅទាំងប្រាំបីមាន (១) លុបបំបាត់ភាពក្រីក្រខ្លាំង និងភាពអត់ឃ្លាន (២) សម្រេចឱ្យបាននូវការអប់រំបឋមជាសកល (៣) ជម្រុញសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី (៤) កាត់បន្ថយមរណភាពកុមារ (៥) លើកកម្ពស់សុខភាពមាតា (៦) ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត (៧) ធានានិរន្តរភាពបរិស្ថាន និង (៨) កសាងភាពជាដៃគូក្នុងការអភិវឌ្ឍ។ សូចនាករនានា ក៏ត្រូវបានបង្ហាញ ដើម្បីវាស់វែងការរីកចម្រើនរបស់គោលដៅនីមួយៗផងដែរ។

[៧] ឧទាហរណ៍ ប្រជាជនថ្នាក់កណ្តាលនៅសាធារណៈរដ្ឋប្រជាមានិតចិន បានកើនឡើង ពី ៦៥,៥ លាននាក់ ទៅ ៨០ លាននាក់ ក្នុងឆ្នាំ ២០០៧។

កំពុងរស់នៅក្នុងបណ្ដាប្រទេសដែលបានទទួលប្រាក់ចំណូលកណ្ដាល ហើយភាគច្រើនស្ថិតនៅក្នុងតំបន់ធំៗ និងតំបន់ទីក្រុង។ ភាពក្រីក្រខ្លាំងបំផុតអាចកាត់បន្ថយនៅត្រឹម ២% នៃចំនួនប្រជាជនសរុបរបស់ DMCs នៅពេលដែលការកាត់បន្ថយភាពក្រីក្រខ្លាំងនេះ មិនទាន់បានទទួលជោគជ័យជាស្ថាពរ។

ទស្សនវិស័យនេះ ជាបន្ទុកយ៉ាងធំធេងមួយចំពោះ ADB និងដៃគូអភិវឌ្ឍន៍របស់ខ្លួនដើម្បីសម្រេចឱ្យបាននូវគោលដៅរួមនៅក្នុងការវិវត្តន៍នៃរចនាសម្ព័ន្ធជំនួយ។ ដោយមានការខិតខំប្រឹងប្រែង និងការគាំទ្រសមស្រប សេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីសស្ដីអំពីប្រសិទ្ធភាពនៃជំនួយ[៨] មានសក្ដានុពលដើម្បីផ្ដល់អំណាចឱ្យប្រទេស DMCs ថែមទៀត ក្នុងការឆ្ពោះទៅរកដំណើរការអភិវឌ្ឍន៍។ ប្រសិនបើមានការបង្កើតឡើង និងការអនុវត្តន៍យុទ្ធសាស្ត្រសមស្របផ្សេងៗ ប្រភពធនធាន និងយន្តការថ្មីៗនៃជំនួយបរទេស អាចជួយបង្កើនការបែងចែកជំនួយចំពោះតំបន់សម្រាប់ប្រជាជនម្នាក់ៗ។ ស្ថានភាពទាំងនេះ អាចផ្ដល់កាលានុ-វត្តភាពឱ្យ ADB ដើម្បីធ្វើការប្រកបដោយការជ្រើសរើស នៅពេលដែលខ្លួនមានឧត្ដមភាពជ្រើសរើសជាច្រើន។ ដោយមានការផ្ដោតការយកចិត្តទុកដាក់កាន់តែច្រើនឡើងថែមទៀត ADB អាចពង្រឹងផលប្រយោជន៍ពិសេសដែលខ្លួនផ្ដល់ឱ្យទៅម្ចាស់ភាគហ៊ុនជាដៃគូនៅក្នុងការអភិវឌ្ឍតំបន់។ ADB អាចផ្ដល់ឱ្យដៃគូនូវជំនាញដែលជួយបង្កើនជំនួយពីស្ថាប័នអន្តរជាតិ និងបណ្ដាម្ចាស់ជំនួយទ្វេភាគី និងផ្ដល់ផលប្រយោជន៍ និងការគាំទ្រជាពិសេស ដល់វិស័យឯកជន ដើម្បីឱ្យពួកគេមានលទ្ធភាពធ្វើការនិងវិនិយោគនូវអ្វីដែលពួកគេមិនអាចធ្វើបាន។ ជាមួយនឹងបទពិសោធន៍ និងការយល់ដឹងអំពីតំបន់ដ៏ទូលំទូលាយ ADB អាចជួយកាត់បន្ថយថ្លៃចំណាយ និងបង្កើនភាពជឿជាក់លើព័ត៌មានគោលនយោបាយដែលពាក់ព័ន្ធ ហើយអាចដើរតួយ៉ាងមានប្រសិទ្ធភាពក្នុងការជួយអភិវឌ្ឍរបស់តំបន់នៅក្នុងរចនាសម្ព័ន្ធជំនួយអន្តរជាតិ។ ADB ក៏អាចជាអ្នកសម្របសម្រួលចំពោះកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍតំបន់អាស៊ី-ប៉ាស៊ីហ្វិក ផងដែរ។

## បញ្ហាប្រឈមខាងមុខ

ក្នុងការរៀបចំយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB បានកំណត់បង្ហាញនូវបញ្ហាប្រឈមសំខាន់ៗចំនួនប្រាំបួនដែលតំបន់កំពុងតែប្រឈម។ ADB បានពិនិត្យឃើញថា បញ្ហាទាំងអស់នេះសុទ្ធតែជាកាលានុវត្តភាពដែលមានសក្ដានុពលដើម្បីអនុវត្តជំនាញ បទពិសោធន៍ ឥទ្ធិពល និង ធនធានរបស់ខ្លួន ហើយយល់ថា បញ្ហាទាំងនេះ អាចស្ថិតនៅក្នុងវិសាលភាពនៃយុទ្ធសាស្ត្រ ឆ្នាំ ២០២០។

[៨] ទទួលការអនុម័តថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៥ ដោយប្រទេស និងអង្គការអភិវឌ្ឍន៍ជាង ១០០ រួមទាំង ADB និងប្រទេស DMCs ចំនួន ១៩ ។

## ១. ភាពក្រីក្រនៅតែជាបញ្ហាប្រឈមដ៏ធំបំផុតនៅក្នុងតំបន់

ប្រជាជនជាង ៦០០ លាននាក់ នៅតំបន់អាស៊ី ប៉ាស៊ីហ្វិក ដែលមានចំនួនប្រហែលជាងពីរដងនៃប្រជាជនសហរដ្ឋអាមេរិក នៅតែរស់នៅក្នុងភាពក្រីក្រយ៉ាងខ្លាំងដែលមានប្រាក់ចំណូលតិចជាង ១ដុល្លា ក្នុងមួយថ្ងៃ ។ ជនក្រីក្រស្ទើរតែពាក់កណ្តាលនៃជនក្រីក្រទាំងអស់នៅលើពិភពលោក រស់នៅតំបន់អាស៊ី ប៉ាស៊ីហ្វិក (ឧបសម្ព័ន្ធលេខ ១) ។ មនុស្សម្នាក់ក្នុងចំណោមមនុស្សពីរនាក់ នៅក្នុងតំបន់ ឬចំនួន ១.៧ ពាន់លាននាក់ នៅតែមានជីវភាពក្រីក្រ ប្រសិនបើគេធ្វើការថ្លឹងថ្លែងដោយយកប្រាក់ចំណូល ២ដុល្លា ក្នុងមួយថ្ងៃជាមូលដ្ឋាន (ឧបសម្ព័ន្ធលេខ ១)។ តួលេខនេះ មានមួយដងកន្លះនៃចំនួនប្រជាជនសរុបរបស់ប្រទេសអភិវឌ្ឍន៍នៃអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ។ នៅក្នុងប្រទេស DMCs ដែលអាចទទួលហិរញ្ញប្បទានពីមូលនិធិអភិវឌ្ឍន៍អាស៊ី (ADF)[៩] ប្រជាជនចំនួន ១០០ លាននាក់ ស្មើនឹង ១៥% នៃប្រជាជនទាំងអស់ នៅតែរស់នៅក្នុងភាពក្រីក្រយ៉ាងខ្លាំងហើយប្រជាជនជិត ៤០០ លាននាក់ ស្មើនឹង ៦០% នៃប្រជាជនទាំងអស់ រស់នៅដោយមានប្រាក់ចំណូលតិចជាង ២ដុល្លាក្នុងមួយថ្ងៃ។ នៅសាធារណៈរដ្ឋប្រជាមានិតចិន ប្រជាជន ៤៥២ លាននាក់ រស់នៅដោយមានប្រាក់ចំណូលតិចជាង ២ ដុល្លា ដែលជាខ្សែបន្ទាត់នៃភាពក្រីក្រប្រចាំថ្ងៃ ខណៈដែលនៅឥណ្ឌា តួលេខនេះមាន ៨៦៨ លាននាក់។ ប្រទេស DMCs ភាគច្រើន ក៏ប្រឈមមុខនឹងឧបសគ្គដើម្បីសម្រេចឱ្យបាននូវគោលដៅគ្មានប្រាក់ចំណូលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលជាបញ្ហាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងភាពក្រីក្រ។ ជាញឹកញាប់ កង្វះអាហារូបត្ថម្ភរបស់កុមារមានកម្រិតខ្ពស់ ដូចជា នៅប្រទេសអាហ្វហ្គានីស្ថាន បង់ក្លាដែស ឥណ្ឌា កុមារខ្វះអាហារូបត្ថម្ភមានស្ទើរតែពាក់កណ្តាល ហើយនៅប្រទេសនេប៉ាល់ កុមារមានភាពស្គមស្គាំង។ ជាងនេះទៅទៀត ប្រជាជន ១.៩ ពាន់លាននាក់នៅក្នុងតំបន់ មិនបានទទួលសេវាអនាម័យមូលដ្ឋានឡើយ។ ត្រឹមឆ្នាំ ២០២០ ភាគរយនៃប្រជាជនដែលរស់នៅដោយមានប្រាក់ចំណូលតិចជាង ១ ដុល្លា ក្នុងមួយថ្ងៃនៅក្នុងតំបន់ អាចធ្លាក់ចុះរហូតដល់ត្រឹម ២% ប៉ុន្តែការធ្លាក់ចុះនេះ ទាមទារឱ្យមានការខិតខំធ្វើការងារបន្តទៅទៀត ដើម្បីទ្រទ្រង់នូវអត្រាខ្ពស់នៃកំណើន GDP សម្រាប់មនុស្សម្នាក់ៗនាពេលថ្មីៗនេះ ព្រមទាំងត្រូវខិតខំបន្ថែមទៀត ដើម្បីធានាថា ប្រជាជនក្រីក្រអាចចូលរួម ឬអាចទទួលបានផលប្រយោជន៍ និងអាចរួមចំណែកចំពោះដំណើរការនៃកំណើន[១០] ។

---

[៩] ADF ជាឧបករណ៍ដ៏សំខាន់មួយនៃការផ្តល់ហិរញ្ញប្បទានសម្បទាន ដែលបានគាំទ្រការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងសមធមិសំរាប់តំបន់ តាំងពីឆ្នាំ ១៩៧៣។ ដោយបានទទួលមូលនិធិពីប្រទេសផ្តល់ជំនួយជាសមាជិករបស់ ADB ADF ផ្តល់ប្រាក់កម្ចីដោយយកអត្រាការប្រាក់ទាបបំផុត និងជំនួយឥតសំណង ដើម្បីជួយកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសក្រីក្របំផុតដែលខ្ចីប្រាក់របស់ ADB ។

[១០] គណៈកម្មាការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក *ADB* និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ២០០៧: *គោលដៅអភិវឌ្ឍន៍សហសវត្សរ៍: ការរីកចម្រើននៅអាស៊ី-ប៉ាស៊ីហ្វិក ២០០៧* បាងកក Humpphry ២០០៦។ ចក្ខុវិស័យ និងបញ្ហាប្រឈមចំពោះកំណើន និងការកាត់បន្ថយភាពក្រីក្រនៅអាស៊ី: *ការពិនិត្យមើលឡើងវិញលើគោលនយោបាយអភិវឌ្ឍន៍ ២៤.១* ។

## ២. គំលាតផ្នែកសុខមាលភាពកំពុងតែរីកធំនៅក្នុង និងរវាងប្រទេស DMCs

កំណើនសេដ្ឋកិច្ចឆាប់រហ័ស មិនបានទៅដល់គ្រប់ក្រុមប្រជាជនទាំងអស់នៅក្នុងប្រទេស DMCs ក្នុងលក្ខណៈសមាមាត្រឡើយ។ ពាក់ព័ន្ធនឹងផលប្រយោជន៍សេដ្ឋកិច្ច និងលទ្ធភាពទទួលបានសេវាសង្គម ប្រជាជនមួយចំនួនធំបានទទួលតិចតួច ឬមិនបានទទួលតែម្តង។ ដោយប្រើប្រាស់មេគុណ Gini ដើម្បីស្ទាបស្ទង់នៅក្នុងប្រទេស DMCs ជាច្រើន វិសមភាពសេដ្ឋកិច្ចបានកើនឡើងក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ ប្រាក់ចំណូល និងចំណាយរបស់ប្រជាជន បានកើនឡើងលឿនជាងប្រាក់ចំណូល និងចំណាយនៃប្រជាជនក្រីក្រ[១១] ។ ដោយពុំមានវិធានការណ៍ដើម្បីបញ្ឈប់ ឬត្រឡប់គំលាតទាំងនេះ ហានិភ័យនៃនិន្នាការនេះរួមទាំង អស្ថេរភាពសង្គមផង នឹងបន្តកើនឡើង។

វិសមភាពគ្មានប្រាក់ចំណូល ក៏កាន់តែអាក្រក់ឡើងផងដែរ។ ឧទាហរណ៍ នៅប្រទេសឥណ្ឌា កុមារប្រហែល ៥% មិនគ្រប់ទម្ងន់នៅក្នុងគ្រួសារដែលមានបំផុត ២០% ខណៈដែលតួលេខនៃកុមារមិនគ្រប់ទម្ងន់នេះមានដល់ទៅ ២៨% នៅក្នុងគ្រួសារដែលក្រីក្របំផុត ២០%[១២] ។ កុមារដែលរស់នៅក្នុងគ្រួសារក្រីក្រ ទំនងជាអាចរស់រានរហូតដល់អាយុ ៥ឆ្នាំ តិចតួចណាស់ ។ នៅប្រទេស DMCs ភាគច្រើន ក៏បង្ហាញនូវចន្លោះគំលាតរវាងតំបន់ភូមិសាស្ត្ររបស់ខ្លួនដែរ ជាពិសេសប្រទេសដែលមានទំហំធំ។ នៅប្រទេស ហ្វីលីពីន អត្រាភាពក្រីក្រថ្នាក់ជាតិ មានប្រហែល ១៥% អត្រាតាមតំបន់មានចាប់ពី ៨% ទៅ ៦៣%។ នៅប្រទេសឥណ្ឌូណេស៊ី ដែលអត្រាកង្វះអាហារូបត្ថម្ភថ្នាក់ជាតិរបស់កុមារ មាន ២៦% អត្រាតាមតំបន់ប្រែប្រួលពី ១៨% ទៅ ៤០%។ គេអាចរកឃើញគំលាតដ៏ធំរវាងកម្រិតសុខមាលភាពនៅក្នុងប្រទេស DMCs នីមួយៗរបស់ ADB ។ ឧទាហរណ៍ ចំណូលរបស់ប្រជាជនម្នាក់នៅប្រទេសម៉ាឡេស៊ី ស្មើនឹង១៨ដងនៃចំណូលរបស់ប្រជាជនម្នាក់នៅប្រទេសណេប៉ាល់។ ការអភិវឌ្ឍសេដ្ឋកិច្ចឱ្យបានស្របគ្នាទូទាំងតំបន់ដែលបង្ហាញឱ្យឃើញនៅក្នុងធម្មនុញ្ញ (Charter) នៅមិនទាន់សម្រេចបាននៅឡើយ។

## ៣. បំលាស់ប្តូរប្រជាសាស្ត្រ នឹងមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅដល់ការអភិវឌ្ឍន៍

ដោយមានប្រជាជនប្រមាណជា ៧៥០ លាននាក់ នៅរវាងឆ្នាំ ២០០៤ និង ២០២៥ នៅក្នុងតំបន់ នឹងមិនគ្រាន់តែកើនឡើងប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបង្កើតទ្រង់ទ្រាយថ្មីមួយក្នុងការផ្លាស់ប្តូរប្រជាសាស្ត្រ ដែលអាចមានផលប៉ះពាល់យ៉ាងខ្លាំងទៅនឹងគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាល និងការចំណាយលើសេវាជាមូលដ្ឋានផ្សេងៗ ដូចជា ការអប់រំ សុខភាព និងសន្តិសុខសង្គម ផងដែរ[១៣] ។ កំណើនប្រជាជន នឹងទាមទារឱ្យបង្កើតការងារចំនួន ៤២០ លានការងារត្រឹមឆ្នាំ ២០៣០ នៅក្នុងតំបន់មួយដែលមានកម្លាំងពលកម្មយ៉ាងហោចណាស់ ៥០០ លាននាក់ ក្នុងកម្មករ ១,៧ ពាន់លាននាក់ គ្មានការងារធ្វើ ឬមានការងារធ្វើមិនគ្រប់គ្រាន់រួចទៅហើយ។ ប្រសិនបើប្រាក់ចំណូល និងកិរិតជីវភាពរស់នៅរបស់ប្រជាជន ត្រូវកើនឡើង

---

[១១] នៅអាស៊ី មេគុណ Gini បានកើនឡើងពី ៤៦.៨២ នៅឆ្នាំ ១៩៩៣ ទៅ ៥២.៤២ នៅឆ្នាំ ២០០៣ ។

[១២] ADB ២០០៧: *សូចនាករគន្លឹះឆ្នាំ ២០០៧* ម៉ានីល ។

[១៣] Hussain, Athar, Robert Cassen និង Tim Dyson ២០០៦ បំលាស់ប្តូរប្រជាសាស្ត្រ និងផលវិបាក។ *តំបន់អាស៊ី២០១៥ : កំណើនប្រកបដោយនិរន្តរភាព និងការបញ្ចប់ភាពក្រីក្រ* (ព្រឹត្តប័ត្រ IDS ៣៧ [៣]) Brighton : វិទ្យាស្ថានសិក្សាលើការអភិវឌ្ឍ។

នោះ ផលិតភាព និងរបរចិញ្ចឹមជីវិត ក៏ត្រូវមានការកើនឡើងផងដែរ[១៤]។ ស្របពេលជាមួយគ្នានេះ ប្រជាជននៅក្នុងប្រទេស DMCs មួយចំនួន នឹងឈានចូលវ័យចំណាស់ ដែលនាំឱ្យការចំណាយសម្រាប់សេវាសុខភាពមានការកើនឡើង។ ប្រព័ន្ធប្រាក់សោធននិវត្តន៍សមស្រប គោលនយោបាយការងារ ដែលចេះតែផ្លាស់ប្តូរ និងការអនុវត្តន៍ដើម្បីអនុញ្ញាតឱ្យកម្មករចាស់ៗនៅបន្តមានការងារធ្វើ នឹងនៅតែចាំបាច់ ជាពិសេស នៅក្នុងប្រទេស DMCs ដែលអាយុរំពឹងទុកកំពុងតែកើនឡើង។ ការប្រឈមនឹងផ្នែកប្រជាសាស្ត្រដែលជាសម្ពាធមួយទៀត គឺការកើនឡើងនូវចំនួនប្រជាជននៅតាមទីក្រុង និងភាពកកស្ទះ ភាពក្រីក្រ និងការបំពុលបរិស្ថាន។ កំណើនទីក្រុង នឹងសាកល្បងសមត្ថភាព និងផែនការអភិវឌ្ឍន៍នៃប្រព័ន្ធចែកចាយសេវាសាធារណៈរបស់តំបន់។

## ៤. កំណើនសេដ្ឋកិច្ចលឿនកំពុងដាក់សំពាធយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន

ទស្សនវិស័យតំបន់ដើម្បីអភិវឌ្ឍដំណើរការសេដ្ឋកិច្ចរឹងមាំ និងនិរន្តរភាព នឹងស្ថិតក្នុងហានិភ័យ ប្រសិនបើគ្មានយុទ្ធវិធីទប់ស្កាត់ការបំពុលបរិស្ថាន ការបំផ្លាញធនធានធម្មជាតិ និងការធ្វើឱ្យហិនហោចបរិស្ថាន (រួមទាំង បម្រែបម្រួលអាកាសធាតុ) ពីការអភិវឌ្ឍសេដ្ឋកិច្ចនោះទេ។ ការខូចខាតបរិស្ថាន និងការបាត់បង់ធនធានធម្មជាតិក្នុងកំណើនយ៉ាងលឿន បានរារាំងការអភិវឌ្ឍនៅក្នុងតំបន់ និងកាត់បន្ថយគុណភាពជីវិតរួចទៅហើយ ជាពិសេស កំពុងមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតទៅលើប្រជាជនក្រីក្រ។ ការរួមចំណែករបស់វិស័យថាមពលតំបន់អាស៊ី ចំពោះការបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីត បានកើនឡើងបីដង ពីប្រហែល ៨% ទៅ ២៨% នៅឆ្នាំ ២០០៥ (ឧបសម្ព័ន្ធ ១)។ ទីភ្នាក់ងារថាមពលអន្តរជាតិ បានព្យាករណ៍ទុកថាតម្រូវការថាមពលរបស់តំបន់ នឹងកើនទ្វេដងនៅត្រឹមឆ្នាំ ២០១៥[១៥]។ ទោះបីជាមានការកែលម្អខ្លះៗនៅតាមទីក្រុងមួយចំនួនក្តីក៏ដោយ ក៏តំបន់អាស៊ីនៅតែមានកម្រិតនៃការបញ្ចេញជាតិពុលទៅក្នុងបរិយាកាសខ្ពស់ជាងគេបំផុតនៅលើពិភពលោក។ សម្ពាធនេះ នឹងបន្តកើនឡើងលើផ្ទៃដី ព្រៃឈើ ប្រព័ន្ធផ្លូវទឹក ដីទំនាបលិចទឹក ប្រព័ន្ធបរិស្ថានក្នុងទឹក និងធនធានធម្មជាតិផ្សេងៗទៀតរបស់តំបន់ ដែលប្រជាជនក្រីក្រពឹងផ្អែកក្នុងជីវភាពរស់នៅ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងការពារបរិស្ថានឱ្យបានច្រើនថែមទៀតនោះទេ។ ទីប្រជុំជន ក៏នឹងទទួលរងនូវផលប៉ះពាល់ផងដែរ ហើយអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ បានឱ្យដឹងថា ទីក្រុងចំនួនប្រាំបីក្នុងចំណោមទីក្រុងចំនួនដប់នៅតាមតំបន់ឆ្នេរសមុទ្រ នឹងទទួលនូវហានិភ័យយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលវែងទៅមុខពីបម្រែបម្រួលអាកាសធាតុ និងការកើនឡើងនូវកម្ពស់ទឹកសមុទ្រ។

---

[១៤] Filipe Jesus និង Rana Hasan 2006: *ទីផ្សារការងារនៅតំបន់អាស៊ី- បញ្ហា និងចក្ខុវិស័យ* ក្រុងឡុង: Palgrave Macmillan សម្រាប់ ADB ។

[១៥] ទីភ្នាក់ងារថាមពលអន្តរជាតិ ២០០៧: *ទស្សនវិស័យថាមពលពិភពលោក* ប៉ារីស ។

## ៥. កង្វះខាតហេដ្ឋារចនាសម្ព័ន្ធកំពុងរារាំងកំណើនទីផ្សារ និងការទទួលបានសេវាសង្គមនៅក្នុងប្រទេសជាច្រើន

ការធ្វេសប្រហែស និងការវិនិយោគមិនបានគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធអស់រយៈពេលជាច្រើនឆ្នាំ បាននាំឱ្យមានភាពកកស្ទះ ការរស់នៅដោយគ្មានអនាម័យ និងគ្មានសុខភាពល្អ ក្នុងទីក្រុងធំៗ នៅក្នុងតំបន់។ ហេដ្ឋារចនាសម្ព័ន្ធមិនល្អ ក៏បង្កើននូវការចំណាយថាមពល ដែលនាំឱ្យអន្តរាយដល់បរិស្ថានផងដែរ។ ទោះបីជាតំបន់អាស៊ីបានកសាងនូវហេដ្ឋារចនាសម្ព័ន្ធធំៗជាគំរូក្នុងរយៈកាលពីរបីទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ គ្រាន់តែរំលេចឱ្យឃើញនូវគម្លាតសេដ្ឋកិច្ចរវាងទីក្រុង ទីប្រជុំជន និងទីជនបទតែប៉ុណ្ណោះ។ ជាងនេះទៅទៀត ការគ្មានផែនការច្បាស់លាស់ សម្រាប់ជនបទទីប្រជុំជន និងការខ្វះខាតប្រព័ន្ធតភ្ជាប់ហេដ្ឋារចនាសម្ព័នផ្លូវថ្នល់ និងប្រព័ន្ធព័ត៌មានវិទ្យា និងគមនាគមន៍ បានរារាំងការវិនិយោគទុនជាច្រើន។ នៅតំបន់ជនបទក្នុងប្រទេសឥណ្ឌា កង្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ ធ្វើឱ្យអន្តរាយដល់ផលិតភាពនៃវិស័យកសិកម្ម។ ចំណែកឯនៅប្រទេសហ្វីលីពីនវិញ គម្លាតផ្នែកហេដ្ឋារចនាសម្ព័ន្ធបានទប់ស្កាត់ឧស្សាហនីយកម្ម និងការបង្កើតការងារមិនឱ្យមានការរីកចម្រើនទៅមុខ។ ភាពរាំងស្ទះនូវការអភិវឌ្ឍទាំងនេះ កើតឡើងដោយសារតែការកៀងគរប្រាក់ចំណូលវិស័យសាធារណៈបានតិចតួច អាទិភាពចំណាយសាធារណៈខុសគោលដៅ ភាពទន់ខ្សោយផ្នែកស្ថាប័ន បរាជ័យផ្នែកនិយតកម្ម និងប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយ នឹងមិនជំរុញឱ្យមានលំហូរមូលធនឯកជនរយៈពេលវែងក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធឡើយ។

## ៦. ការទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មតំបន់បន្ថែមទៀត ដើម្បីដោះស្រាយបញ្ហាប្រឈម និងកាលានុវត្តភាពរបស់ប្រទេស DMCs

កិច្ចសហការ និងការធ្វើសមាហរណកម្មតំបន់ (RCI) មានសក្តានុពលយ៉ាងធំធេងដើម្បីបង្កើនកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រនិងគំលាតសេដ្ឋកិច្ច លើកកម្ពស់ផលិតភាពនិងការអភិវឌ្ឍ និងពង្រឹងស្ថាប័ន។ RCI អាចកែលម្អលទ្ធភាពរបស់ប្រទេសក្រីក្រ ដើម្បីឆ្ពោះទៅរកកំណើន តាមរយៈការពង្រីកពាណិជ្ជកម្ម និងការវិនិយោគរួមគ្នាជាមួយប្រទេសជិតខាង ការពង្រឹងទំនាក់ទំនង និងការដឹកជញ្ជូន និងការកែលម្អបច្ចេកវិទ្យាកវិទ្យា និងទូរគមនាគមន៍។ ឧទាហរណ៍ នៅតំបន់អាស៊ីខាងត្បូង ធនធានវារីអគ្គិសនី និងឧស្ម័នធម្មជាតិ ដែលនៅរាយប៉ាយនៅក្នុងតំបន់ និងទំហំនៃតម្រូវការថាមពល និងសេដ្ឋកិច្ចជាតិព្រមទាំងអត្រាកំណើនខុសៗគ្នា តម្រូវឱ្យមានសក្តានុពលសម្រាប់ការធ្វើសមាហរណកម្ម និងការធ្វើពាណិជ្ជកម្មលើធនធានថាមពល[១៦] ដើម្បីបម្រើផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ RCI អាចបង្រួមគម្លាតនៃការអភិវឌ្ឍរវាងប្រទេស DMCs។ ការកសាងសមាហរណកម្មពាណិជ្ជកម្មឱ្យកាន់តែមានភាពជិតស្និទ្ធបន្ថែមទៀត ខ្សែចង្វាក់នៃការផ្គត់ផ្គង់ក្នុងតំបន់ និងចំណងទាក់ទងហិរញ្ញវត្ថុដ៏រឹងមាំជាមួយប្រទេសជិតខាង ដែលកំពុងតែមានការរីកចម្រើនយ៉ាងរហ័ស នឹងអាចឱ្យប្រទេសតូចៗដែលមានកំណើនយឺតអាចបង្កើនល្បឿន ដើម្បីពង្រីកការអភិវឌ្ឍរបស់ខ្លួន។

---

[១៦] Jones, S 2004: ការធ្វើសមាហរណកម្មក្នុងតំបន់តាមរយៈហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ព្រំដែន។ ឯកសារក្របខ័ណ្ឌ សម្រាប់ការគ្រប់គ្រងគោលនយោបាយ Oxford ។ Oxford ចក្រភពអង់គ្លេស (ខែ វិច្ឆិកា) ។

ការរីកចម្រើនក្នុង RCI មានភាពខុសប្លែកគ្នានៅក្នុងអនុតំបន់។ ទោះបីជាការធ្វើពាណិជ្ជកម្មក្នុងតំបន់ ដែលកើនឡើងយ៉ាងលឿនពី ៤៣% នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ មក ៥៥% នៃការធ្វើពាណិជ្ជកម្មសរុបក្នុងតំបន់ក៏ដោយ តំបន់អាស៊ីខាងកើតមានចំណែកច្រើនជាងគេបំផុតនៅក្នុងកំណើននោះ។ តំបន់អាស៊ី ក៏ទាមទារឱ្យបន្តគោលការណ៍ "ការបើកទូលាយតំបន់និយម" ដោយរក្សាចំណងទាក់ទង ការវិនិយោគទុន និងពាណិជ្ជកម្មបើកចំហរជាមួយប្រទេសដទៃៗទៀតនៅលើពិភពលោក។ គោលការណ៍នេះ នឹងរក្សាបាននូវអ្វីដែលជាកត្តាចម្បងនៃជោគជ័យផ្នែកសេដ្ឋកិច្ចរបស់ខ្លួន និងបន្ធូរបន្ថយការការពារនិយមនៅក្នុងតំបន់ផ្សេងៗទៀត។ RCI អាចជាទីកន្លែងដ៏សំខាន់នៅក្នុងទីផ្សារតំបន់ដែលកំពុងតែមានការអភិវឌ្ឍចំពោះទំនិញ និងសេវាកម្ម ហើយធានាឱ្យទីផ្សារនេះ គ្មានឧបសគ្គរាំងតាមរយៈកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធលើការកសាងគោលនយោបាយ និងគម្រោងរៀបចំផ្នែកនិយតកម្ម។

## ៧. ប្រព័ន្ធហិរញ្ញវត្ថុនៅអាស៊ី មិនធ្វើអន្តរការីយកម្មឃ្លាំងប្រាក់សន្សំរបស់តំបន់ដោយប្រសិទ្ធភាព ដើម្បីបំពេញតម្រូវការដែលចេះតែកើនឡើងរបស់ខ្លួន

តំបន់អាស៊ី តម្រូវឱ្យមានការខិតខំទ្វេឡើងថែមទៀត ដើម្បីអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុជាតិ និងប្រព័ន្ធហិរញ្ញវត្ថុតំបន់ រួមទាំងទីផ្សារមូលធន ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការពង្រីកទំហំ និងសកម្មភាពទីផ្សារ។ ប្រទេស DMCs ត្រូវធ្វើការតម្រង់ក្របខ័ណ្ឌស្ថាប័ននៃប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនឡើងវិញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យនេះពិតប្រាកដ។ ក្នុងសកម្មភាពមួយ ប្រព័ន្ធហិរញ្ញវត្ថុ កំពុងបង្កើនការធ្វើសកលភាវូបនីយកម្ម ដែលតម្រូវឱ្យមានប្រតិបត្តិការហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន។ ក្នុងសកម្មភាពមួយផ្សេងទៀត ប្រព័ន្ធហិរញ្ញវត្ថុ ត្រូវបានដឹកមុខដោយស្ថាប័នឯកជន ដែលតម្រូវឱ្យមានមូលធនសម្រាប់ហានិភ័យ ជាពិសេសសម្រាប់ការចាប់ផ្តើមដំណើរការក្រុមហ៊ុន និងសហគ្រាសខ្នាតតូច និងមធ្យម (SMEs)។ ប្រព័ន្ធហិរញ្ញវត្ថុនៅប្រទេសភាគច្រើនក្នុងតំបន់នៅតែគ្រប់គ្រងដោយធនាគារ។ ទីផ្សារមូលធន ដែលអភិវឌ្ឍមិនបានល្អនឹងរារាំងការវិនិយោគទុនចំពោះគម្រោងដែលត្រូវការរយៈពេលយូរ ដូចជា គំរោងហេដ្ឋារចនាសម្ព័ន្ធជាដើម។ ជាងនេះទៅទៀត ប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងប្រទេស DMCs នៅតែទាមទារឱ្យមានការគ្រប់គ្រងលើហានិភ័យហិរញ្ញវត្ថុ ស្តង់ដាគណទាន និងនីតិវិធីគ្រប់គ្រងផ្ទៃក្នុងឱ្យបានខ្លាំងក្លាថែមទៀត។ ប្រជាជនភាគច្រើននៅក្នុងតំបន់នៅតែទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងក្រៅផ្លូវការមានកម្រិត ឬមិនបានទទួលតែម្តង ជាពិសេសនៅតាមតំបន់ជនបទ។ ប្រសិនបើ ប្រព័ន្ធហិរញ្ញវត្ថុអាចត្រូវបានគេពង្រីកទៅដល់តំបន់ជនបទ នោះវិស័យជនបទ និងប្រជាជនក្រីក្ររាប់លាននាក់ នឹងមានកាលានុវត្តភាពបន្ថែមទៀត ដើម្បីចូលរួមចំណែកក្នុងកំណើនតំបន់[១៧]។

[១៧] Rahman, Hossain Zillur និង Mark Robinson: អភិបាលកិច្ច និងប្រសិទ្ធភាពរបស់រដ្ឋនៅតំបន់អាស៊ី។ *តំបន់អាស៊ី ២០១៥ : ការគាំទ្រកំណើន និងការបញ្ចប់ភាពក្រីក្រ* (ព្រឹត្តិប័ត្រ IDS ៣៧ [៣])។

## ៨. ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ត្រូវការយកចិត្តទុកដាក់បន្ថែមទៀតលើការច្នៃប្រឌិត ការអភិវឌ្ឍបច្ចេកវិទ្យា និងការអប់រំខ្ពស់

ការអភិវឌ្ឍបានទទួលជោគជ័យ មិនគ្រាន់តែបានបំពេញចន្លោះប្រហោងធនធានប៉ុណ្ណោះទេ តែថែមទាំងតភ្ជាប់នូវបច្ចេកវិទ្យា និងចំណេះដឹងរវាងពិភពអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ផងដែរ។ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ប្រទេស DMCs ត្រូវតែកសាងសមត្ថភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការច្នៃប្រឌិតរបស់ខ្លួន។ ការប្រកួតប្រជែងទៅថ្ងៃអនាគតនឹងត្រូវកំណត់ដោយប្រាក់កម្រៃការងារកាន់តែទាបទៅៗ និងលទ្ធភាពផលិត គ្រប់គ្រងបច្ចេកវិទ្យាទំនិញ និងសេវាកម្មខ្ពស់ (ឧបសម្ព័ន្ធ ៤)។ បណ្តាប្រទេស DMCs ត្រូវតែបង្កើតយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពដែលពាក់ព័ន្ធ រួមទាំងការលើកទឹកចិត្តដើម្បីបង្កើតនូវតម្រូវការបច្ចេកវិទ្យាទំនើបថែមទៀត[១៨] ។ ការច្នៃប្រឌិតអាចកើតឡើងតែនៅពេលដែលសមត្ថភាពស្រូបយកចំណេះដឹងនៅក្នុងស្រុកមានកម្រិតខ្ពស់ប៉ុណ្ណោះ ហើយតម្រូវឱ្យមានកម្លាំងពលកម្មដែលមានចំណេះដឹង និងគ្រឹះស្ថានអប់រំមានគុណភាព[១៩] ។ ការអប់រំ អាចកាត់បន្ថយភាពក្រីក្រតាមរយៈការជួយប្រជាជនក្រីក្រឱ្យទទួលបានការងារដែលមានផលិតភាពជាងមុន ប្រាក់កម្រៃខ្ពស់ និងគុណភាពនៃការរស់នៅកាន់តែប្រសើរឡើង។

## ៩. អភិបាលកិច្ចទន់ខ្សោយអាចរារាំងប្រទេស DMCs មិនឱ្យទទួលបានកាលានុវត្តភាពសេដ្ឋកិច្ច

បញ្ហាប្រឈមដ៏ស្មុគស្មាញ ដែលកើតឡើងដោយកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស បានបង្កើនតម្រូវការសមត្ថភាពរបស់ស្ថាប័នសាធារណៈ ដើម្បីរៀបចំ និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រឱ្យកាន់តែប្រសើរ។ រដ្ឋ ត្រូវតែបង្កើតស្ថាប័ន និងគោលនយោបាយដែលអាចពង្រីកកាលានុវត្តភាពជាអតិបរមា ដើម្បីកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ជោគជ័យផ្នែកសេដ្ឋកិច្ចរបស់ប្រទេស DMCs ជាច្រើន នឹងពឹងផ្អែកទៅលើការរីកចម្រើនរបស់ស្ថាប័នប្រភេទនេះ ព្រមជាមួយនូវបរិយាកាស និយតកម្មដែលគាំទ្រពាណិជ្ជកម្ម ការវិនិយោគទុន និងការអភិវឌ្ឍបច្ចេកវិទ្យា។ តួនាទីសំខាន់របស់ស្ថាប័នរដ្ឋជាញឹកញាប់ តែងតែមានការលើកឡើងអំពីបញ្ហាប្រឈមផ្នែកអភិបាលកិច្ចដែលទាក់ទងនឹងអំពើពុករលួយ ដែលប្រទេស DMCs ជាច្រើន ប្រឈមមុខនៅកម្រិតខុសៗគ្នា ។ ស្ថាប័នសាធារណៈ រួមទាំងស្ថាប័ននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ត្រូវតែកែតម្រូវ និងធ្វើកំណែទម្រង់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ដែលបើកចំហរ និងប្រកួតប្រជែងរបស់ទីផ្សារសេដ្ឋកិច្ច ព្រមទាំងប្រសិទ្ធភាព និងតម្លាភាពក្នុងការគ្រប់គ្រងធនធានសាធារណៈ និងការចែកចាយសេវាសាធារណៈដែលស្នើសុំដោយប្រជាពលរដ្ឋ។ ប្រទេសនានាត្រូវតែចាត់វិធានការបន្ថែមទៀតដើម្បីការពារកម្មសិទ្ធិបញ្ញា និងលើកកម្ពស់នីតិរដ្ឋ។ បណ្តាប្រទេសទន់ខ្សោយ និងស្ថានភាព

---

[១៨] ADB ២០០៧: សេចក្តីសង្ខេបគោលនយោបាយ ERD លេខ ៤៩ ម៉ានីល ។

[១៩] ធនាគារពិភពលោក ២០០៧: *ការងើបឡើងវិញរបស់តំបន់អាស៊ីខាងកើត* វ៉ាស៊ីនតោន DC ។

ផុយស្រួយ អាចទទួលផលប្រយោជន៍យ៉ាងធំធេងពីអភិបាលកិច្ចល្អ និងតម្លាភាពកម្រិតខ្ពស់ ដែលជាកត្តាជម្រុញឱ្យមានការចាប់ផ្តើមការអភិវឌ្ឍសេដ្ឋកិច្ចរបស់ពួកគេ។

ការសម្រេចបាននូវការរីកចម្រើនដែលអាចវាស់វែងបាន និងប្រកបដោយនិរន្តរភាពលើការប្រឈមមុខទាំងនេះ អាចតំណាងឱ្យការរួមចំណែកយ៉ាងសំខាន់ចំពោះសុខមាលភាពក្នុងតំបន់ និងលើពិភពលោក។ ការបញ្ចប់ភាពក្រីក្រយ៉ាងខ្លាំងនៅក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក នឹងក្លាយជាសមិទ្ធិផលជាប្រវត្តិសាស្ត្រ ដែលថ្មីៗនេះ ហាក់ដូចជាមិនទាន់បានទទួលជោគជ័យនៅឡើយ។ ការពង្រឹងសេដ្ឋកិច្ចទីផ្សារទំនើប និងរស់រវើកនៅក្នុងតំបន់ បានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចពិភពលោក តាមរយៈការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច និងការវិនិយោគទុន។ ការធ្វើទំនើបកម្មវិស័យហិរញ្ញវត្ថុក្នុងតំបន់ នឹងអាចធ្វើឱ្យប្រទេស DMCs មានការពឹងផ្អែកលើខ្លួនឯងថែមទៀត នៅក្នុងការផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍរយៈពេលវែង និងរួមចំណែកដល់ស្ថេរភាពហិរញ្ញវត្ថុទូទាំងពិភពលោក។ ការសម្របសម្រួលគោលនយោបាយ និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ឱ្យបានកាន់តែធំធេង ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងប្រទេស និងស្ថានភាពដែលមានភាពផុយស្រួយ អាចពង្រឹងស្ថេរភាពក្នុងតំបន់ និងលើកកម្ពស់សក្តានុពលនៃកំណើនសេដ្ឋកិច្ច។ ជាងនេះទៅទៀត ការរីកចម្រើនគួរឱ្យកត់សម្គាល់លើប្រសិទ្ធផលថាមពល និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាស៊ីប៉ា ស៊ីហ្វិក ដែលកំពុងតែមានការអភិវឌ្ឍន៍ នឹងបង្កើតបានជាលទ្ធផលវិជ្ជមានហួសពីព្រំដែនតំបន់ និងមនុស្សជំនាន់នេះ។ ដោយពិចារណាទៅលើទំហំ ចំនួនប្រជាជន និងធនធាននៅក្នុងតំបន់ ការពុះពារជំនះរាល់បញ្ហាប្រឈមចំពោះការអភិវឌ្ឍ និងការសម្រេចឱ្យបាននូវសមិទ្ធផលផ្សេងៗទៀត គឺជាផលប្រយោជន៍របស់ពិភពលោក។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ គេត្រូវការគំនិតច្នៃប្រឌិត ចំណេះដឹងខ្ពង់ខ្ពស់ បែបបទថ្មីនៃជំនួយអភិវឌ្ឍធនធានហិរញ្ញវត្ថុ និងបទពិសោធន៍ល្អៗ។ នៅក្នុងប្រទេស DMCs ជាច្រើន លក្ខណៈ និងទំហំនៃការប្រឈមទាំងនេះ មានលើសពីធនធាន និងសមត្ថភាព ដែលមានស្រាប់របស់រដ្ឋាភិបាល និងទីផ្សារ។ នេះជាការពិត ជាពិសេសនៅកន្លែងណាដែលសកម្មភាពសហប្រតិបត្តិការរវាងប្រទេស និងប្រទេសមានភាពចាំបាច់ និងនៅកន្លែងណាដែលលទ្ធភាពទទួលបានហិរញ្ញវត្ថុរយៈពេលវែងមានសារៈសំខាន់ ដើម្បីដោះស្រាយការចំណាយសង្គមដ៏ធំ ហើយផលប្រយោជន៍មិនអាចស្រូបយកដោយទីផ្សារ។ នេះក៏ជាករណីដែលកើតមានផងដែរ នៅពេលដែលមានជម្លោះ អភិបាលកិច្ច ឬសមត្ថភាពទន់ខ្សោយ ធ្វើឱ្យការគ្រប់គ្រងលើការអភិវឌ្ឍន៍ត្រូវពឹងផ្អែកទៅលើជំនួយបរទេស និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។ ADB ត្រូវតែបន្តជួយប្រទេស DMCs ឱ្យទទួលបានមូលនិធិរយៈពេលវែងក្នុងលក្ខខណ្ឌដែលអាចទទួលយកបាន អាចគ្រប់គ្រងហានិភ័យធ្វើសកម្មភាពរួម ហើយរៀបចំចំណេះដឹង និងសេវាបច្ចេកទេសថ្មីៗ ដើម្បីបំពេញតាមការផ្តល់ហិរញ្ញប្បទាន។ ADB ក៏ត្រូវគាំទ្រអភិបាលកិច្ច និងលើកកម្ពស់សមភាពយេនឌ័រ ជម្រុញការអភិវឌ្ឍវិស័យឯកជន និងរៀបចំភាពជាដៃគូជាមួយស្ថាប័នមួយចំនួនធំទៀតផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីបន្តនូវប្រសិទ្ធភាពក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមដែលកំពុងតែកើតឡើងនៅក្នុងតំបន់ ADB ត្រូវមានទស្សនវិស័យច្បាស់លាស់ យុទ្ធសាស្ត្រត្រឹមត្រូវ ព្រមទាំង សមត្ថភាព

ស្ថាប័ន និងហិរញ្ញវត្ថុសមស្រប។ ជំពូកទាំងពីរបន្ទាប់ទៅទៀតនេះ នឹងបង្ហាញនូវទិសដៅយុទ្ធសាស្ត្ររបស់ ADB ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០។

# III. ទស្សនវិស័យ និងកម្មវិធីយុទ្ធសាស្រ្ត

ADB ប្តេជ្ញាដើម្បីបញ្ចប់ភាពក្រីក្រនៅក្នុងតំបន់។ ការកាត់បន្ថយភាពក្រីក្រ គឺជាគោលដៅដែលបានបំពេញតាំងពីឆ្នាំ ១៩៩៩ ហើយជាប្រធានបទដ៏សំខាន់មួយនៃការរៀបចំផែនការ និងប្រតិបត្តិការតាំងពី ADB បានបង្កើតមក។ ការបញ្ចប់ភាពក្រីក្រ គឺជាការងារដ៏សំខាន់បំផុតមួយរបស់ ADB និងតំបន់ ។ ការពង្រីកសេដ្ឋកិច្ចដ៏ខ្លាំងក្លាក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ បានលុបបំបាត់ប្រាក់ចំណូលនៃភាពក្រីក្រ (ពោលគឺ សំរាប់អ្នកដែលមានប្រាក់ចំណូលតិចជាង ១ ដុល្លា ក្នុងមួយថ្ងៃ) ដោយសង្ឃឹមទទួលបាននៅត្រឹមឆ្នាំ ២០២០។ ម្ចាស់ភាគហ៊ុន អ្នកខ្ចី និងមិនមែនអ្នកខ្ចី និងដៃគូអភិវឌ្ឍន៍របស់ ADB ទាំងអស់ បានឯកភាពគ្នាថា ការលុបបំបាត់ភាពក្រីក្រគឺជាគោលបំណង និងគោលដៅអភិវឌ្ឍដ៏សំខាន់បំផុតមួយដែលគាំទ្រមុខងារកណ្តាលរបស់ប្រទេស DMCs នៅក្នុងតំបន់ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍។ ដូច្នេះហើយ ទស្សនវិស័យរួមរបស់ ADB ក្រោមយុទ្ធសាស្រ្តឆ្នាំ ២០២០ នឹងបន្តជា "តំបន់អាស៊ី ប៉ាស៊ីហ្វិក គ្មានភាពក្រីក្រ" ហើយបេសកកម្មរបស់ខ្លួន គឺដើម្បីជួយប្រទេស DMCs ក្នុងការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជននៃប្រទេសទាំងនោះ។

កំណើនសេដ្ឋកិច្ច គឺជាកម្លាំងនាំមុខក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់។ ទោះជាយ៉ាងណាក៏ដោយ កំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះមិនគ្រាន់តែជាបញ្ហាជំហាននៃកំណើន (pace of growth ) ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាបញ្ហាគំរូនៃកំណើន (pattern of growth) ផងដែរ។ ការកាត់បន្ថយភាពក្រីក្រទាមទារឱ្យប្រជាជនកាន់តែច្រើនឡើងក្លាយទៅជាអ្នកដែលមានផលិតភាពផ្នែកសេដ្ឋកិច្ច និងចែករំលែកសុខមាលភាពដែលចេះតែកើនឡើងរបស់សង្គម។ លទ្ធភាពដើម្បីសម្រេច និងទ្រទ្រង់នូវការកាត់បន្ថយភាពក្រីក្រពឹងផ្អែកទៅលើកំណើនសេដ្ឋកិច្ច ជាមួយនឹងការគ្រប់គ្រងបរិស្ថានឱ្យបានត្រឹមត្រូវ។ លើសពីនេះទៅទៀត ដំណើរការនៃការបញ្ចប់ភាពក្រីក្រនៅក្នុងតំបន់ អាចនឹងពន្លឿនទៅបាន ប្រសិនបើសេដ្ឋកិច្ចរបស់ប្រទេសជិតខាងមានលក្ខណៈជាទីផ្សារសេរី និងទូលំទូលាយជាងមុន ហើយនៅពេលដែលរដ្ឋាភិបាលសម្រេចបាននូវផលប្រយោជន៍តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា។ ADB អាចរួមចំណែកយ៉ាងសំខាន់ឆ្ពោះទៅរកទស្សនវិស័យនេះ ដោយផ្តោតការគាំទ្ររបស់ខ្លួនទៅលើរបៀបវារៈច្បាស់លាស់បីយ៉ាង ប៉ុន្តែវាជារបៀបវារៈបំពេញឱ្យការអភិវឌ្ឍរបស់តំបន់ៈ កំណើនសេដ្ឋកិច្ចចម្រុះ កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពបរិស្ថាន និងការធ្វើសមាហរណកម្មក្នុងតំបន់។

## ១. កំណើនសេដ្ឋកិច្ចចម្រុះ (Inclusive Economic Growth)

យុទ្ធសាស្រ្តអភិវឌ្ឍន៍ ដែលផ្អែកលើកំណើនចម្រុះ នឹងមានចំណុចផ្តោតយុទ្ធសាស្រ្តពីរដើម្បីបំពេញបន្ថែមគ្នាទៅវិញទៅមក។ ទីមួយ កំណើនខ្ពស់ប្រកបដោយនិរន្តរភាព នឹងបង្កើត ហើយពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច។ ទីពីរ លទ្ធភាពទទួលបានកាលានុវត្តភាពនេះ នឹងធានាថា សមាជិកសង្គមអាចចូលរួម និងទទួលបានផលប្រយោជន៍ពីកំណើន។ ដោយពុំមានការធ្វើផែនការ និងការយកចិត្តទុកដាក់សមស្រប វាកាន់តែមានការលំបាកដើម្បីឱ្យកំណើនបានដល់ប្រជាជនក្រីក្រ ដែលនៅតែមិនបានរាប់បញ្ចូលដោយកាលៈទេសៈ អភិបាលកិច្ចទន់ខ្សោយ និងឧបសគ្គដែលរារាំងទីផ្សារដទៃទៀត។ តំបន់ត្រូវតែ

ជម្រុញលទ្ធភាពទទួលបានកាលានុវត្តភាពដោយការពង្រីកធនធានមនុស្ស ជាពិសេស ចំពោះអ្នកដែលមិនបានទទួលផលប្រយោជន៍ តាមរយៈការវិនិយោគលើវិស័យអប់រំ សុខាភិបាល និងការការពារផ្នែកសង្គមជាមូលដ្ឋាន។ គេក៏ត្រូវតែលើកកម្ពស់លទ្ធភាពទទួលបានទីផ្សាររបស់អ្នកក្រីក្រ និងធនធានផលិតភាពជាមូលដ្ឋាន តាមរយៈការបង្កើតគោលនយោបាយ និងស្ថាប័នសមស្រប។ ជាចុងក្រោយ បណ្តាញសុវត្ថិភាពសង្គមត្រូវតែពង្រឹងដើម្បីការពារនូវការខ្វះខាតដ៏ធ្ងន់ធ្ងរនេះ។ ការគាំទ្ររបស់ ADB ដើម្បីសម្រេចឱ្យបាននូវកំណើនចម្រុះនៅក្នុងប្រទេស DMCs នឹងរាប់បញ្ចូលទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដើម្បីសម្រេចនូវការរីកចម្រើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ភ្ជាប់ប្រជាជនក្រីក្រទៅនឹងទីផ្សារ និងបង្កើនលទ្ធភាពរបស់ពួកគេឱ្យទទួលបានធនធានផលិតភាពជាមូលដ្ឋាន។ ADB នឹងគាំទ្រការធ្វើវិនិយោគទុននៅក្នុងវិស័យអប់រំ និងសេវាសាធារណៈសំខាន់ៗ ដូចជា ទឹក និងអនាម័យ ដែលផ្តល់ផលប្រយោជន៍ ជាពិសេស ដល់អ្នកក្រីក្រ និងស្ត្រី។ ការវិនិយោគនេះនឹងផ្តល់កាលានុវត្តភាពសម្រាប់មនុស្សទាំងអស់គ្នាដើម្បីកែលម្អជីវភាពរស់នៅរបស់ពួកគេ តាមរយៈការរួមចំណែកចំពោះកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការកាត់បន្ថយនូវវិសមភាពដ៏ខ្លាំងក្លា។

ភាគច្រើននៃអ្នកក្រីក្រនៅក្នុងតំបន់ រួមទាំង អ្នកក្រីក្របំផុត គឺជាស្ត្រី។ ស្ត្រីស្ថិតនៅក្នុងក្រុមមនុស្សច្រើនបំផុត ដែលបានបាត់ចេញពីផលប្រយោជន៍ដែលបានមកពីការពង្រីកសេដ្ឋកិច្ចរបស់តំបន់។ ADB នឹងបន្តផ្តោតទៅលើសមភាពយេនឌ័រ និងការផ្តល់អំណាចទៅឱ្យស្ត្រីដែលជាមូលដ្ឋានគ្រឹះមួយដើម្បីសម្រេចបាននូវកំណើនចម្រុះ។ ADB ក៏នឹងជួយបង្កើនការវិនិយោគដែលមានគោលបំណងផ្តល់លទ្ធភាពទៅឱ្យស្ត្រីឱ្យទទួលបានការអប់រំ និងធនធានសេដ្ឋកិច្ចផ្សេងៗទៀត ដូចជា ឥណទាន ជាដើម។

## ២. កំណើនប្រកបដោយនិរន្តរភាពបរិស្ថាន

កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លារបស់អាស៊ី កំពុងតែរួមចំណែកដល់ការបំផ្លាញធនធានធម្មជាតិនៅក្នុងតំបន់ ធ្វើឱ្យខូចខាតបរិស្ថាននៅទីជនបទ និងទីក្រុង និងប៉ះពាល់ដល់បម្រែបម្រួលអាកាសធាតុ។ មានតែកំណើនដែលមាននិរន្តរភាពបរិស្ថានទេដែលអាចកាត់បន្ថយភាពក្រីក្រ ពីព្រោះថា ប្រជាជនក្រីក្រភាគច្រើនពឹងផ្អែកទៅលើធនធានធម្មជាតិសម្រាប់ប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ដើម្បីសម្រេចឱ្យបាននូវកំណើនដែលមាននិរន្តរភាពបរិស្ថាន ADB នឹងគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាដែលមិនប៉ះពាល់ដល់បរិស្ថាន ដាក់ចេញនូវវិធានការការពារបរិស្ថាន និងបង្កើតសមត្ថភាពស្ថាប័នដើម្បីពង្រឹងការអនុវត្តវិធានការទាំងនោះ។ តាមរយៈកិច្ចសហប្រតិបត្តិការក្នុងតំបន់ ADB នឹងជម្រុញនូវយុទ្ធវិធី និងដំណោះស្រាយដែលមានប្រសិទ្ធភាព និងរៀបចំការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាអំពីការគ្រប់គ្រងបរិស្ថាន។ ជាងនេះទៅទៀត ADB នឹងពង្រឹងការផ្តួចផ្តើមគំនិតតំបន់បន្ថែមទៀត ដើម្បីកាត់បន្ថយ និងសម្របទៅតាមការប្រែប្រួលអាកាសធាតុ ដោយហេតុថា តំបន់អាស៊ីកំពុងតែមានការកើនឡើងលើការបញ្ចេញចោលនូវកាបូនឌីអុកស៊ីត ។

## ៣. ការធ្វើសមាហរណកម្មក្នុងតំបន់ (RCI)

ស្របទៅនឹងការគាំទ្រចំពោះកម្មវិធីជាតិដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅ ADB នឹងបង្កើននូវការអនុវត្តយុទ្ធសាស្ត្រ RCI របស់ខ្លួន។ កម្មវិធីយុទ្ធសាស្ត្រនេះ នឹងយកប្រយោជន៍ពីការសន្យាធំៗដែលសកម្មភាព RCI ផ្តល់ឱ្យ ដើម្បីពន្លឿនកំណើនសេដ្ឋកិច្ច លើកកម្ពស់ផលិតភាពនិងបង្កើតការងារ កាត់បន្ថយគំលាតសេដ្ឋកិច្ច និងសម្រេចឱ្យបាននូវការសម្របសម្រួលគោលនយោបាយនិងការសហការឱ្យបានជិតស្និទ្ធជាងមុន ដើម្បីគាំទ្រផលប្រយោជន៍សាធារណៈនៅក្នុងតំបន់ និងលើពិភពលោក រួមទាំង ការងារប្រយុទ្ធប្រឆាំងនឹងការបម្រែបម្រួលអាកាសធាតុ និងមេរោគអេដស៍/ជម្ងឺអេដស៍។ ADB នឹងជួយប្រទេស DMCs ដើម្បីសម្រេចឱ្យបាននូវកំណើនតាមរយៈការធ្វើសមាហរណកម្ម និងទំនាក់ទំនងឱ្យបានជិតស្និទ្ធថែមទៀតជាមួយប្រទេសជិតខាង ។ ជាញឹកញាប់ កិច្ចសហប្រតិបត្តិការក្នុងតំបន់ក៏បានដោះស្រាយប្រភពធនធានរួម (ឧទាហរណ៍ ដូចជា ទន្លេមេគង្គ) ដែលប្រជាជនក្រីក្រពឹងផ្អែកសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ ទីផ្សារក្នុងតំបន់ដែលធំទូលាយសម្រាប់ទំនិញ សេវាកម្ម និងធនធាន នឹងលើកកម្ពស់ប្រសិទ្ធផលនៃការប្រើប្រាស់ធនធាន និងជម្រុញឱ្យមានការប្រកួតប្រជែងជាសកលនៅក្នុងតំបន់។ ការសម្របសម្រួលក្នុងតំបន់ដែលជិតស្និទ្ធជាងនេះ នឹងលើកកម្ពស់គុណភាពទាំងមូលនៃគោលនយោបាយ និងជម្រុញលទ្ធភាពរបស់ប្រទេស និងតំបន់ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពថែមទៀតចំពោះការផ្លាស់ប្តូរភ្លាមៗ និងមិនបានគិតទុកមុននៅក្នុងស្ថានភាពសេដ្ឋកិច្ចផ្សេងៗ។ ការបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតនេះកើតឡើងចំពេលដែលថ្នាក់ដឹកនាំនៅក្នុងតំបន់កំពុងតែបង្កើនការប្តេជ្ញាចំពោះការធ្វើសមាហរណកម្មសេដ្ឋកិច្ច ការបើកទូលាយតំបន់និយម និងកិច្ចសហប្រតិបត្តិការក្នុងបញ្ហាឆ្លងកាត់ព្រំដែន។

ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB ប្តេជ្ញាសម្រេចឱ្យបាននូវការអភិវឌ្ឍន៍ប្រកបដោយសមធម៌ និងនិរន្តរភាព កែលម្អស្ថានភាពរស់នៅ និងលុបបំបាត់ភាពក្រីក្រ ដោយមានគោលបំណងរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុត ចំពោះកំណើនដែលស៊ីសង្វាក់គ្នានៅក្នុងតំបន់ ។ ការធ្វើសមាហរណកម្មប្រកបដោយតុល្យភាពនៃកត្តាទាំងនេះ គួរតែឆ្លុះបញ្ចាំងនៅក្នុងផលបត្រទាំងមូលរបស់ ADB ព្រមទាំងនៅក្នុងភាពជាដៃគូររបស់ប្រទេស និងយុទ្ធសាស្ត្រសហប្រតិបត្តិការ។ ADB ជឿជាក់ថា ខ្លួននឹងអាចធ្វើការបានល្អបំផុតដើម្បីលុបបំបាត់ភាពក្រីក្រ លុះត្រាតែកម្មវិធីរបស់ខ្លួនស្របជាមួយនឹងតម្រូវការជាក់ស្តែងរបស់ប្រទេស DMCs ។ ការឆ្លើយតបពីតម្រូវការរបស់ប្រទេស នឹងមានសារៈសំខាន់ខ្លាំងណាស់ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ពីព្រោះថា វានឹងទទួលស្គាល់ និងគោរពកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍នៅក្នុងកម្មវិធីជំនួយដ៏ធំក្នុងតំបន់។ ហេតុនេះហើយ កម្មវិធី និងគម្រោងជំនួយរបស់ ADB នឹងស្របទៅតាមអ្វីដែលយុទ្ធសាស្ត្រឆ្នាំ ២០២០ បានកំណត់ ហើយវាក៏ជាការងាររបស់ ADB ក្នុងរយៈពេល ១២ឆ្នាំ ខាងមុខទៀត ដែលត្រូវស្វះស្វែងយល់ថា តើកន្លែងណាដែលអាចពាក់ព័ន្ធបំផុត និងកន្លែងណាដែលអាចទទួលបានផលប៉ះពាល់បំផុត។

# IV. ដៃគូ និងភ្នាក់ងារសម្រាប់ធ្វើការផ្លាស់ប្តូរ

## កត្តានាំមកនូវការផ្លាស់ប្តូរ

ដើម្បីសម្រេចតាមចក្ខុវិស័យរបស់ខ្លួន និងកម្មវិធីយុទ្ធសាស្ត្រថ្មី និងដើម្បីសម្រេចលទ្ធផលឱ្យបានធំធេងលើការប្រឈមនៅក្នុងតំបន់ ADB នឹងផ្តោតការយកចិត្តទុកដាក់ទៅលើកត្តានៃការផ្លាស់ប្តូរប្រាំយ៉ាង: (១) ការអភិវឌ្ឍវិស័យឯកជន និងប្រតិបត្តិការវិស័យឯកជន (២) អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព (៣) សមធមិយេនឌ័រ (៤) ដំណោះស្រាយចំណេះដឹង និង (៥) ភាពជាដៃគូ។ កត្តានីមួយៗទាំងនេះផ្តល់កាលានុវត្តភាពឱ្យ ADB ដើរតួបន្ថែមទៀតជាភ្នាក់ងារនៃការផ្លាស់ប្តូរដោយការបង្កើនកំណើន និងបន្ថែមជំនួយអភិវឌ្ឍន៍ឱ្យបានទូលំទូលាយក្នុងនាមជាដៃគូអភិវឌ្ឍន៍ដ៏សកម្ម និងដ៏ប្រពៃ។

## ១. ការអភិវឌ្ឍវិស័យឯកជន និងប្រតិបត្តិការវិស័យឯកជន

ADB នឹងពង្រីកការងាររបស់ខ្លួនជាមួយផ្នែកឯកជន ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចថែមទៀតនៅក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក។ ADB នឹងគិតគូ ហើយវាយតម្លៃហានិភ័យយ៉ាងហ្មត់ចត់ ព្រមទាំងដើរតួជាកាតាលីករសម្រាប់ការវិនិយោគទុន ដែលវិស័យឯកជនប្រហែលជាមិនចង់ធ្វើ។ ADB នឹងបំពេញការងារច្រើនថែមទៀតដើម្បីជួយប្រទេស DMCs ក្នុងការទាក់ទាញការវិនិយោគវិស័យឯកជនផ្ទាល់ ដែលអាចគាំទ្រកំណើនចម្រុះ និងការកែលម្អបរិស្ថាន។ ដើម្បីលើកទឹកចិត្តដល់កំណើនទីផ្សារសេរី ADB នឹងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់យោបល់ដល់រដ្ឋាភិបាលលើបរិយាកាសជាមូលដ្ឋានសម្រាប់ធ្វើពាណិជ្ជកម្ម រួមទាំងច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយទទួលខុសត្រូវ ដែលមិនធ្វើឱ្យបាត់បង់ផលប្រយោជន៍ដល់វិស័យឯកជន។ វិធានរបស់ ADB ដើម្បីជម្រុញឱ្យមានការផ្លាស់ប្តូរតាមរយៈការវិនិយោគឯកជនឱ្យបានធំធេងបន្ថែមទៀតនៅក្នុងប្រទេស DMCs នឹងរាប់បញ្ចូលការផ្តល់ហិរញ្ញប្បទានផ្ទាល់ ការលើកកម្ពស់ផ្នែកឥណទាន ការធានានូវការកាត់បន្ថយហានិភ័យ និងការផ្តល់នូវបរិធានហិរញ្ញវត្ថុច្នៃប្រឌិតថ្មីៗ។ វិធានទាំងនេះ នឹងទាក់ទាញមូលធនឯកជន និងប្រើប្រាស់ការគ្រប់គ្រងពាណិជ្ជកម្ម ឬ ជំនាញបច្ចេកទេសសំរាប់វិស័យ និងប្រតិបត្តិការជាក់លាក់ផ្សេងៗ។ ADB នឹងជួយជម្រុញភាពជាដៃគូរវាងផ្នែកឯកជន និងសាធារណៈនៅក្នុងវិស័យប្រតិបត្តិការស្នូលរបស់ខ្លួន ដោយប្រមូលបទពិសោធន៍ជាមុននៅក្នុងប្រទេសមានប្រាក់ចំណូលកណ្តាល (MICs) ហើយបន្ទាប់មកពង្រីកកិច្ចខិតខំប្រឹងប្រែងទាំងនេះទៅដល់ប្រទេស DMCs។

## ២. អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព

ADB នឹងបង្កើនការគាំទ្រចំពោះអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍សមត្ថភាព ពីព្រោះថា ការគាំទ្រនេះ នឹងជួយលើកកម្ពស់ការចែកចាយទំនិញ និងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងពង្រីកកំណើនចម្រុះ។ ADB នឹងផ្តោតលើកត្តាបួននៃអភិបាលកិច្ចល្អ (គណនេយ្យភាព ការចូលរួម ភាពអាចទស្សន៍ទាយបាន និងតម្លាភាព) ឱ្យបានស៊ីជម្រៅទៅក្នុងដំណើរប្រតិបត្តិការ និងសកម្មភាពរបស់ខ្លួន។ ADB នឹងចាត់ទុកគណនេយ្យភាពសម្រាប់សកម្មភាពសេដ្ឋកិច្ច ប្រសិទ្ធភាពនៃការរៀប

ចំ និងការអនុវត្តន៍គោលនយោបាយ និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាពដើម្បីបម្រុងទុកនូវធនធានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍។ ADB នឹងធ្វើការដើម្បីធានាថា អ្នកក្រីក្រអាចចូលរួមនៅក្នុងដំណើរការសម្រេចចិត្តទៅលើការគ្រប់គ្រងធនធានដែលពួកគេពឹងផ្អែកដើម្បីចិញ្ចឹមជីវិត។ ដើម្បីជួយឱ្យការធ្វើសមាហរណកម្មក្នុងតំបន់សម្រេចបាននូវសក្តានុពលរបស់ខ្លួនក្នុងការជម្រុញកំណើន ADB នឹងគាំទ្រដល់ការបង្កើតនូវតម្លាភាព និងការព្យាករណ៍ទុក នៅក្នុងបទប្បញ្ញត្តិ និងការសម្រេចចិត្តលើបញ្ហាឆ្លងកាត់ព្រំដែន កិច្ចសហប្រតិបត្តិការវិនិយោគទុន និងពាណិជ្ជកម្ម ការធ្វើសមាហរណកម្មហិរញ្ញវត្ថុ និងទំនិញសាធារណៈតំបន់។

ADB នឹងព្យាយាមកាត់បន្ថយអំពើពុករលួយដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ ជាពិសេសដល់អ្នកក្រីក្រ។ ការប្រឹងប្រែងរបស់ ADB ក្នុងការប្រឆាំងនឹងអំពើពុករលួយ នឹងត្រូវផ្សារភ្ជាប់ទៅនឹងការគាំទ្រចំពោះអភិបាលកិច្ច និងការកែលម្អគុណភាព និងសមត្ថភាពនៃវិស័យសាធារណៈទាំងមូល។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងបន្តផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងកិច្ចផ្តួចផ្តើម និងប្រព័ន្ធដែលសង្កត់ធ្ងន់ទៅលើការការពារ និងការប្រើប្រាស់ក្របខ័ណ្ឌអន្តរជាតិដែលមាននៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ។ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB នឹងពិចារណាទៅលើការកែលម្អអភិបាលកិច្ច កាត់បន្ថយអំពើពុករលួយ និងជួយស្ថាប័ន និងអង្គការសាធារណៈ ឱ្យមានសមត្ថភាពកាន់តែខ្លាំងឡើងដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការបង្កើនការវិនិយោគវិស័យឯកជនទូទាំងតំបន់។

## ៣. សមធម៌យេនឌ័រ

ក្នុងនាមជាភ្នាក់ងារដើម្បីធ្វើការផ្លាស់ប្តូរ ADB នឹងបន្តលើកកម្ពស់ និងគាំទ្រសមធម៌យេនឌ័រ ដោយរៀបចំបញ្ចូលយេនឌ័រនៅក្នុងគម្រោង និងផ្តោតការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះបញ្ហាយេនឌ័រក្នុងប្រតិបត្តិការរបស់ខ្លួនទាំងមូល។ ការស្រាវជ្រាវ និងបទពិសោធន៍ជាង ១០ ឆ្នាំ កន្លងមកនេះ បានបញ្ជាក់យ៉ាងច្បាស់នូវសារៈសំខាន់នៃសមធម៌យេនឌ័រចំពោះការកាត់បន្ថយភាពក្រីក្រ ការកែលម្អជីវភាពរស់នៅ និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តភាព[២០]។ ADB នឹងលើកកម្ពស់សមធម៌យេនឌ័រតាមរយៈប្រតិបត្តិការដែលផ្តល់នូវលទ្ធផលយេនឌ័រជាក់លាក់ ដូចជា ស្ត្រីអាចទទួលបានសេវាអប់រំ និងសុខភាព ទឹកស្អាត អនាម័យល្អ និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន។ ការផ្តល់អំណាចទៅឱ្យស្ត្រី ផ្តល់ផលចំណេញដោយផ្ទាល់ និងប្រយោលជាច្រើន ទាំងផ្នែកសេដ្ឋកិច្ច និងសង្គម ដែល ADB នឹងជួយប្រទេស DMCs ឱ្យសម្រេចបាន។ ប្រតិបត្តិការរបស់ ADB នឹងត្រូវណែនាំដោយគោលនយោបាយ និងការអភិវឌ្ឍនយេនឌ័រ[២១] និងផែនការសកម្មភាព និងការអភិវឌ្ឍយេនឌ័ររបស់ខ្លួន[២២]។

---

[២០] ADB: *ការពិនិត្យឡើងវិញលើការអនុវត្តនៃគោលនយោបាយស្តីអំពីយេនឌ័រ និងការអភិវឌ្ឍ* ម៉ានីល ។

[២១] ADB ១៩៩៨: យេនឌ័រ និងការអភិវឌ្ឍន៍ ម៉ានីល ។

[២២] ADB: ផែនការសកម្មភាព និងការអភិវឌ្ឍយេនឌ័រ (២០០៨-២០១០) ម៉ានីល ។

## ៤. ដំណោះស្រាយផ្នែកចំណេះដឹង

ចំណេះដឹង ជាកាតាលីករដ៏មានឥទ្ធិពលមួយដើម្បីជម្រុញការអភិវឌ្ឍឈានទៅមុខ និងលើកកម្ពស់ប្រសិទ្ធភាពរបស់វា។ ADB នឹងដើរតួក្នុងផ្នែកមួយយ៉ាងធំក្នុងការបញ្ចូលដំណោះស្រាយចំណេះដឹងដែលមានសក្តានុពលឱ្យដំណើរការនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ លទ្ធភាពដ៏ពិសេសរបស់ ADB ដើម្បីរួមចំណែក និងប្រើប្រាស់ចំណេះដឹងអភិវឌ្ឍន៍បានចាក់ឫសនៅក្នុងតួនាទីកណ្តាលរបស់ខ្លួនក្នុងការបង្ហាញទិន្នាការក្នុងនិងក្រៅតំបន់ យុទ្ធវិធីធ្វើសមាហរណកម្មសមត្ថភាព និងចំណេះដឹងក្នុងការអនុវត្តការងារតាមរយៈការផ្តល់ហិរញ្ញប្បទានដែលទាក់ទាញធំៗ។ ADB នឹងប្រើប្រាស់ផលប្រយោជន៍ទាំងនេះ ដើម្បីគាំទ្រស្ថាប័នដែលមានសុឆន្ទៈ និងបទពិសោធន៍ជាក់ស្តែង ក្នុងការដោះស្រាយឧបសគ្គ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍ ដោយប្រើប្រាស់បុគ្គលិកដែលមានពហុចំណេះដឹងរបស់ខ្លួន។ សេវាផ្តល់ចំណេះដឹងរបស់ ADB នឹងឆ្លើយតបចំពោះតម្រូវការចំណេះដឹងបន្ទាន់របស់អតិថិជនខ្លួន នៅពេលដែលខ្លួនកំពុងធ្វើការកំណត់ និងផ្តល់ការអនុវត្តដ៏ល្អបំផុតសម្រាប់សេវាកម្មចំណេះដឹង។ ADB នឹងគាំទ្រគម្រោងសាកល្បងដែលនឹងជួយផ្សព្វផ្សាយបទពិសោធន៍របស់ខ្លួន។ ADB នឹងចែកចាយចំណេះដឹងទៅតាមមធ្យោបាយដែលអាចមានផលប៉ះពាល់ភ្លាមៗ និងប្រកបដោយកំលាំងជម្រុញ ឧទាហរណ៍ ចំណេះដឹងពីរបៀបដែលប្រទេស DMCs អាចសម្រេចបាននូវភាពជាដៃគូជាមួយផ្នែកសាធារណៈ និងឯកជន ដើម្បីផ្តល់សេវាសង្គម និងសម្រេចបានផលប្រយោជន៍ដល់អ្នកក៏ក្រ។

លទ្ធភាពរបស់ ADB ដើម្បីធ្វើការយ៉ាងជិតស្និទ្ធ និងក្នុងរយៈពេលវែងជាមួយរដ្ឋាភិបាលក្នុងតំបន់ ធ្វើឱ្យ ADB មានការយល់ដឹងកាន់តែច្បាស់លាស់ចំពោះប្រទេសទាំងនោះថែមទៀត។ ទោះជាយ៉ាងណាក៏ដោយ ទស្សនវិស័យរបស់ ADB សំឡឹងហួសពីតម្រូវការរបស់ប្រទេសនីមួយៗទៅទៀត។ កិច្ចខិតខំរបស់ ADB ដើម្បីកសាង និងប្រើប្រាស់ចំណេះដឹងក៏នឹងដាក់បញ្ចូលនូវកិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មទូទាំងប្រទេស និងតំបន់ផងដែរ។ ADB នឹងមានចំណេះដឹងកាន់តែកើនឡើងជាបន្តបន្ទាប់តាមរយៈ (១) ការសិក្សាផ្ទៃក្នុងពីបទពិសោធន៍ការងារ និងសហគមន៍ និង (២)ការសិក្សាខាងក្រៅពីភាពជាដៃគូយុទ្ធសាស្ត្ររយៈពេលវែងជាមួយគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នស្រាវជ្រាវលំដាប់ពិភពលោករួមទាំង មជ្ឈមណ្ឌលចំណេះដឹងក្នុងតំបន់របស់ ADB ខ្លួនឯងផងដែរ។

## ៥. ភាពជាដៃគូ

ដើម្បីដោះស្រាយនូវហានិភ័យ និងបញ្ហាប្រឈមក្នុងតំបន់ និងដើម្បីឆ្លើយតបទៅតាមតម្រូវការផ្សេងៗសម្រាប់សម្រេចឱ្យបាននូវកំណើនចម្រុះ កំណើនដែលប្រកបដោយនិរន្តរភាពបរិស្ថាន និងការធ្វើសមាហរណកម្មក្នុងតំបន់ ADB នឹងធ្វើទំនាក់ទំនងដៃគូជាមួយក្រុមស្ថាប័នផ្សេងៗគ្នាជាច្រើនបន្ថែមទៀត។ ភាពជាដៃគូជាមួយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ស្ថាប័នទ្វេភាគី និងពហុភាគី វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ និងបណ្តាមូលនិធិនានា នឹងក្លាយជាចំណុចសំខាន់នៃការធ្វើផែនការ ការផ្តល់ហិរញ្ញប្បទាន និងការអនុវត្តនូវប្រតិបត្តិការរបស់ ADB ។ ADB នឹងប្រើលក្ខណៈសម្បត្តិរបស់ខ្លួនដែលជាស្ថាប័នអភិវឌ្ឍន៍របស់តំបន់អាស៊ី-ប៉ាស៊ីហ្វិក រួមទាំង សមត្ថភាពនៅនឹងកន្លែងដែលផ្តល់ដោយបេសកកម្មតាមនិវេសនដ្ឋានជាង ២០ នៅពាសពេញតំបន់ ។ ADB បានអភិវឌ្ឍនូវទំនាក់ទំនងប្រកបដោយផ្លែផ្កាជាមួយរដ្ឋាភិបាលនៃប្រទេស DMCs ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ អង្គការពាណិជ្ជកម្មពិភពលោក បណ្តាទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ និងស្ថាប័នទ្វេភាគី និងពហុភាគីធំៗជាច្រើនផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្រឆ្នាំ ២០២០ នឹងពង្រីកវិសាលភាពនៃកម្មវិធីជាដៃគូលើសពីដៃគូអភិវឌ្ឍន៍ហិរញ្ញវត្ថុបច្ចុប្បន្ន ដើម្បីបញ្ចូលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនជាមួយវិស័យ និងស្ថាប័នឯកជន។ ADB នឹងបើកទូលាយនូវសកម្មភាពជាដៃគូថ្មីៗបន្ថែមទៀត ដែលអាចចែកចាយជំនួយប្រកបដោយប្រសិទ្ធិភាព លើកកម្ពស់លទ្ធផលអភិវឌ្ឍន៍ និងជំនួយសង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ។ ការផ្តល់នូវភាពជាដៃគូទាំងនេះ ទំនងជាអាចលើកកម្ពស់របៀបគ្រប់គ្រងជំនួយថ្មី ការប្រើប្រាស់ជំនាញគ្រប់គ្រង និងបច្ចេកទេសរបស់ប្រទេស DMCs ឱ្យធំទូលាយ និងបង្កើនកិច្ចសហការអោយបានជិតស្និទ្ធបន្ថែមទៀត ជាមួយវិស័យឯកជននៅក្នុងគម្រោងដែលផ្តល់សហហិរញ្ញប្បទាន និងប្រើប្រាស់នូវវិធានវិនិយោគទីផ្សារជាមូលដ្ឋាន។

## ប្រទេសជាដៃគូអភិវឌ្ឍ

ក្រោមយុទ្ធសាស្ត្រ ឆ្នាំ ២០២០ គោលនយោបាយឆ្លងផុត[២៣] (graduation policy) របស់ ADB នឹងអនុញ្ញាតឱ្យ ADB ពិនិត្យមើលប្រទេស DMCs នីមួយៗលើការរីកចម្រើនពីសកម្មភាពគ្រប់គ្រងសេដ្ឋកិច្ច និងកិច្ចអភិវឌ្ឍន៍របស់ពួកគេ ហើយធ្វើការសម្រេចចិត្តលើសិទ្ធិទទួលបានរបស់ពួកគេសម្រាប់មូលនិធិអភិវឌ្ឍន៍អាស៊ី (ADF) និងធនធានមូលធនធម្មតា (OCR)។ ដោយសំលឹងមើលឱ្យហួសពីកត្តាសំខាន់ៗទាំងនេះ ADB នឹងពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយលើសមត្ថភាពអភិវឌ្ឍ និងបញ្ហាប្រឈមរបស់ប្រទេស DMCs បរិយាកាសសង្គម និងសេដ្ឋកិច្ច ស្ថាប័ន និងប្រវត្តិសាស្ត្រ ហើយធ្វើការកែតម្រូវជំនួយ និងកិច្ចសហប្រតិបត្តិការចំពោះប្រទេសនីមួយៗទៅតាមទស្សនវិស័យដូចខាងក្រោម:

### ១. ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកដែលឆ្លងផុតពីគោលនយោបាយរបស់ ADB (Graduated DMCs)

ចំណេះដឹង និងជំនាញរបស់ប្រទេស DMCs ដែលឆ្លងផុតគោលនយោបាយ អាចផ្តល់ទៅឱ្យប្រទេស DMCs ដទៃទៀត គឺជាធនធានដ៏មានតម្លៃមួយដែល ADB នឹងប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់ខ្លួន។ ការវិវត្តនៃទំនាក់ទំនងដ៏រឹងមាំថែមទៀតរវាងប្រទេស DMCs ដែលឆ្លងផុតគោលនយោបាយ និង ADB ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ នឹងរាប់បញ្ចូលកិច្ចសហប្រតិបត្តិការលើកិច្ចពិភាក្សាគោលនយោបាយ និងវិធីសាស្ត្រអនុវត្តល្អបំផុតចំពោះកំណែទម្រង់គោលនយោបាយនៅក្នុងប្រទេស DMCs ការផ្តល់ហិរញ្ញប្បទានគម្រោងដោយផ្ទាល់ ឬ ការផ្តល់សហហិរញ្ញប្បទានគម្រោងដែលទ្រទ្រង់ដោយ ADB និងការពង្រីកការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាពីប្រទេស DMCs ដែលឆ្លងផុតគោលនយោបាយរបស់ ADB ទៅឱ្យប្រទេស DMCs ដែលកំពុងទទួលកម្ចី នៅក្នុងវិស័យដែលមានឧត្តមភាព។

### ២. ប្រទេសដែលមានប្រាក់ចំណូលកណ្តាល (MICs)

ជនក្រីក្រនៅតំបន់អាស៊ីភាគច្រើនរស់នៅក្នុងប្រទេស MICs។ ក្នុងករណីជាច្រើន វិសមភាពបានរីកធំ ហើយជះឥទ្ធិពលទៅលើស្ថេរភាពសេដ្ឋកិច្ច-សង្គម និងផលប្រយោជន៍អភិវឌ្ឍ។ ទោះបីជាប្រទេស MICs ជាច្រើនមាន ឬងាយទទួលបានធនធាន ដើម្បីដោះស្រាយចំពោះបញ្ហាប្រឈមលើការអភិវឌ្ឍន៍ក៏ដោយ ក៏លទ្ធភាពរបស់ប្រទេសជាច្រើនផ្សេងទៀតនៅមានកម្រិតដែរ។ ប្រទេស MICs តំណាងឱ្យអាទិភាពជាយុទ្ធសាស្ត្រក្នុងចក្ខុវិស័យរបស់ ADB ស្តីពី តំបន់រួចផុតពីភាពក្រីក្រ ហើយ ADB នឹងមិនបោះបង់ឱកាសដើម្បីជួយប្រទេសទាំងនោះក្នុងការកាត់បន្ថយ និងលុបបំបាត់ភាពក្រីក្រទេ។ ជាងនេះទៅទៀត ការរីកចម្រើនសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេស MICs អាចជាប្រភពនៃកំណើនសម្រាប់ប្រទេសជិតខាងផ្សេងទៀត ជាពិសេសរាល់បណ្តាប្រទេសដែលបានបង្កើតចំណងទាក់ទងពាណិជ្ជកម្ម និងការវិនិយោគទុនជាមួយគ្នា។ ការរួមចំណែករបស់ប្រទេស

---

[23] ADB ២០០៧: *ការពិនិត្យឡើងវិញលើគោលនយោបាយឆ្លងផុត (Graduation policy) របស់ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ១៩៩៨* ។ ឯកសារការងារ ម៉ានីល ។

MICs ចំពោះការផ្តល់នូវសេវាសាធារណៈក្នុងតំបន់ និងក្នុងពិភពលោក ជាពិសេស សេវាបរិស្ថាន ជាញឹកញាប់ ពោរពេញដោយការសម្រេចចិត្តយ៉ាងហ្មត់ចត់ និងផ្តល់ផលប្រយោជន៍ដល់មនុស្សគ្រប់ៗគ្នា។ ADB នឹងគាំទ្រកម្មវិធីអភិវឌ្ឍន៍របស់ MICs ដែលអ្នកពាក់ព័ន្ធគិតថាសំខាន់បំផុត។ ឧទាហរណ៍ ប្រសិនបើប្រទេស MICs ណាមួយបានធ្វើការលើកកម្ពស់យ៉ាងជិតដល់ទៅលើសុខមាលភាពសង្គមសម្រាប់ប្រជាជនរបស់ខ្លួននោះ ជំនួយរបស់ ADB អាចផ្តោតទៅលើការលុបបំបាត់បញ្ហាផ្សេងៗទៀតដែលនៅសេសសល់។ ផ្ទុយទៅវិញ ប្រសិនបើមានតែការរីកចម្រើនបន្តិចបន្តួច ឬ គ្មានការរីកចម្រើនសោះនៅក្នុងប្រទេស MICs ADB អាចជួយដោះស្រាយបញ្ហាគម្លាត ឬការបរាជ័យនៃគោលនយោបាយ វិសមភាពផ្នែករចនាសម្ព័ន្ធ ឬកង្វះខាតចំណេះដឹង ឬជំនាញគ្រប់គ្រង និងបច្ចេកទេស។ ក្នុងករណីមួយចំនួន ADB អាចធ្វើអន្តរាគមន៍តាមរយៈការគាំទ្រដោយមានការជ្រើសរើសខ្ពស់ និងពេលវេលាជាក់លាក់ ដើម្បីលើកកម្ពស់គោលនយោបាយអភិវឌ្ឍសមត្ថភាព ឬធានាការវិនិយោគទុនលើហេដ្ឋារចនាសម្ព័ន្ធជាតិ និងអនុតំបន់។ នៅក្នុងប្រទេសផ្សេងៗទៀត ADB អាចផ្តល់នូវជំនួយតាមរយៈការសហការជាមួយស្ថាប័នដែលពាក់ព័ន្ធ។

## ៣. ប្រទេសដែលមានប្រាក់ចំណូលទាប

ប្រទេស DMCs ប្រភេទនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនួយអភិវឌ្ឍន៍ផ្លូវការក្នុងការប្រឹងប្រែងឆ្ពោះទៅរកការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ។ ទោះជាយ៉ាងណាក៏ដោយ បើផ្អែកទៅលើលក្ខណៈខុសគ្នានៃប្រទេសទាំងនោះ ដំណោះស្រាយត្រូវតែមានភាពខុសប្លែកពីគ្នាដែរ។ សម្រាប់ប្រទេសមួយចំនួន ត្រូវផ្តល់អាទិភាពទៅលើការបន្តពង្រឹងកំណើនដ៏ខ្លាំងក្លានាពេលថ្មីៗ ហើយត្រូវធ្វើឱ្យកំណើនទាំងនេះមាននិរន្តរភាព។ រីឯប្រទេសមួយចំនួនទៀត ទាមទារឱ្យមានការជួយគ្រប់គ្រងនិរន្តរភាព និងការបន្តផលប្រយោជន៍សេដ្ឋកិច្ចដែលបានមកពីធនធានធម្មជាតិរបស់ពួកគេ។ ចំណែកប្រទេសខ្លះទៀតតម្រូវឱ្យបង្កើត និងចាប់ផ្តើមនូវដំណើរការកំណើនដ៏ខ្លាំងក្លា។ ទោះបីជាមានភាពខុសប្លែកគ្នាក៏ដោយ ក៏ប្រទេសទាំងនេះប្រឈមមុខទៅនឹងបញ្ហាប្រហាក់ប្រហែលគ្នា ដូចជាការកែលម្អបរិយាកាសវិនិយោគ និងការអភិវឌ្ឍវិស័យឯកជន ការរីកចម្រើនផ្នែកអភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយ ការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង ការគ្រប់គ្រងលើធនធានរួម ការលើកកម្ពស់ការធ្វើសមាហរណកម្មក្នុងតំបន់ និងការដាក់បញ្ហាប្រឈមទាំងនេះជាធាតុមួយទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ប្រតិបត្តិការនឹងត្រូវរៀបចំឡើងដើម្បីតម្រូវទៅតាមស្ថានភាពនៃប្រទេស ADF នីមួយៗឱ្យស្របតាមគោលបំណងដើម្បីជម្រុញប្រទេសទាំងនោះឱ្យរួចផុតពីជំនួយដែលមានលក្ខណៈសម្បទានឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន តាមរយៈកំណើនសេដ្ឋកិច្ចដែលលឿនជាងមុន។ ប្រតិបត្តិការ ADF X ដែលមានរយៈពេលបួនឆ្នាំដំបូងនៃយុទ្ធសាស្ត្រឆ្នាំ ២០២០ នឹងជួយប្រទេស DMCs ឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ត្រឹមឆ្នាំ ២០១៥។

## ៤. ប្រទេស និងស្ថានភាពដែលងាយបែកបាក់ (Fragile Countries and Situations)

អាស្រ័យដោយរបបគោលនយោបាយមានភាពទន់ខ្សោយ និងមានទំហំតូច ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងភាពទន់ខ្សោយផ្នែកស្ថាប័ន និងវិស័យផ្សេងៗនៅក្នុងប្រទេសទាំងនេះ ADB ត្រូវរកមធ្យោបាយប្រកបដោយការច្នៃប្រឌិត ដើម្បីពង្រឹងប្រសិទ្ធភាពនៃគំរូដឹកនាំប្រទេសដោយមានការចូលរួម[២៤] ។ ADB នឹងគាំទ្រការប្តេជ្ញាចិត្តរយៈពេលវែង ដោយរំពឹងទុកថា ការអនុវត្តសកម្មភាពក្នុងប្រទេស និងប្រសិទ្ធភាពជំនួយ នឹងត្រូវធ្វើការកែសម្រួល។ ADB នឹងប្រឹងប្រែងធ្វើការតម្រង់នូវជំនួយអភិវឌ្ឍន៍របស់ខ្លួនជាមួយទីភ្នាក់ងារផ្តល់មូលនិធិដទៃទៀត នៅកម្រិតយុទ្ធសាស្ត្រ និងគម្រោង ហើយនឹងស្វែងរកការចូលរួមរយៈពេលវែងប្រកបដោយភាពបត់បែន និងស៊ីជម្រៅបន្ថែមទៀត ក្នុងការបង្កើនសមត្ថភាព និងការអភិវឌ្ឍស្ថាប័ន ហើយពេលខ្លះត្រូវរួមជាមួយអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់ផ្សេងៗទៀត។ ស្របពេលជាមួយគ្នានេះដែរ ADB នឹងដើរតួជាឃ្លាំងចំណេះដឹងក្នុងការរួមចំណែកចំពោះការផ្លាស់ប្តូរ។ ADB នឹងប្រើប្រាស់វិធាន និងយុទ្ធវិធីប្រកបដោយការច្នៃប្រឌិតក្នុងយុទ្ធសាស្ត្រប្រទេស និងគម្រោង ដោយមិនធ្វើការសម្របសម្រួលនូវការអនុវត្តគោលនយោបាយ និងវិធានការពារដ៏តឹងរឹងសម្រាប់ការគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួនឡើយ។ វិសាលភាពពេញលេញនៃធនធានសម្បទាន ADF មូលនិធិពិសេសផ្សេងៗទៀត ជំនួយឥតសំណង មូលនិធិ (trust fund) ត្រូវគេរំពឹងទុកថា នឹងត្រូវផ្តល់យ៉ាងធំបំផុតនៃហិរញ្ញប្បទានរបស់ ADB ទៅដល់ប្រទេស និងស្ថានភាពដែលងាយបែកបាក់ (fragile countries and situations)។ ការជ្រើសរើសក្នុងការប្រើប្រាស់ធនធានមូលនិធិធម្មតា អាចធ្វើទៅបានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសាធារណៈ និងប្រតិបត្តិការវិស័យឯកជននៅក្នុងប្រទេសមួយចំនួន។

---

[២៤] ADB ២០០៧: ការសម្រេចប្រសិទ្ធភាពអភិវឌ្ឍនៅក្នុងបណ្តាប្រទេសដែលមានសកម្មភាពការងារទន់ខ្សោយ *(យុទ្ធវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីចូលរួមជាមួយប្រទេសដែលមានសកម្មភាពការងារទន់ខ្សោយ)* ម៉ានីល ។

## វិស័យប្រតិបត្តិការស្នូល

ADB មិនអាច និងមិនព្យាយាមបំពេញនូវតម្រូវការទាំងអស់របស់ប្រទេស DMCs ទេ។ ដើម្បីបង្កើននូវលទ្ធផលជាអតិបរមា ប្រសិទ្ធផល និងផលប៉ះពាល់នានា ADB នឹងប្រើប្រាស់ធនធានស្ថាប័ន និងហិរញ្ញវត្ថុរបស់ខ្លួនទៅលើវិស័យសំខាន់ចំនួនប្រាំ គឺ ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ (RCI) ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការអប់រំ។ បណ្តាប្រទេស DMCs របស់ ADB បានទទួលស្គាល់នូវឧត្តមភាពរបស់ ADB នៅក្នុងវិស័យឯកទេសទាំងនេះ និងសមិទ្ធផលដែលបានបង្ហាញជូន[២៥] ។ វិស័យទាំងនេះ ក៏មានចំណងទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងកម្មវិធីអភិវឌ្ឍជាយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចចម្រុះ កំណើនប្រកបដោយនិរន្តរភាពបរិស្ថាន និងការធ្វើសមាហរណកម្មក្នុងតំបន់។ ការគាំទ្រចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការអប់រំ នឹងមានសារៈសំខាន់ដើម្បីទ្រទ្រង់កំណើន និងផ្តល់នូវលទ្ធភាពទទួលបានកាលានុវត្តភាពសេដ្ឋកិច្ចដែលជាសរសរទ្រូងពីរនៃកំណើនចម្រុះ។ ហេដ្ឋារចនាសម្ព័ន្ធ និងជំនួយវិស័យហិរញ្ញវត្ថុរបស់ ADB នឹងជួយជម្រុញឱ្យ RCI ដើរទៅមុខ។

### ១. ហេដ្ឋារចនាសម្ព័ន្ធ

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបស់ ADB គឺជាមូលដ្ឋានដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ និងកំណើនចម្រុះ និងអាចរួមចំណែកចំពោះកំណើនប្រកបដោយនិរន្តរភាពបរិស្ថាន និងការធ្វើសមាហរណកម្មក្នុងតំបន់[២៦] ផងដែរ។ ADB នឹងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដើម្បីកែលម្អការដឹកជញ្ជូន និងការភ្ជាប់ទូរគមនាគមន៍នៅក្នុង និងរវាងប្រទេស DMCs។ ដើម្បីបំពេញបានទៅតាមតម្រូវការថាមពលប្រកបដោយនិរន្តរភាព ADB នឹង: (១) ជួយពង្រីកការផ្គត់ផ្គង់ថាមពល (២) លើកកម្ពស់ប្រសិទ្ធផលថាមពលតាមវិធានការផ្គត់ផ្គង់ និងបំពេញតម្រូវការ (៣) គាំទ្រថាមពលបរិសុទ្ធ និង (៤) សម្របសម្រួលការលុបចោលនូវការរាំងស្ទះដោយសារតែបញ្ហាគោលនយោបាយ ស្ថាប័ន បទប្បញ្ញត្តិ បច្ចេកវិទ្យា និងផ្នែកច្បាប់ ដើម្បីលើកកម្ពស់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធផល។ ដើម្បីរួមចំណែកដល់សុខភាពសាធារណៈ ADB នឹងវិនិយោគលើទឹក អនាម័យ និងប្រព័ន្ធគ្រប់គ្រងកាកសំណល់។ ADB ក៏នឹងបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយគ្របដណ្តប់លើការគ្រប់គ្រងទឹក និងប្រព័ន្ធធារាសាស្ត្រ ផ្លូវជនបទ អគ្គិសនីយកម្ម និងសេវាកម្មជនបទដែលផ្តល់ផលប្រយោជន៍ជាពិសេសដល់ស្ត្រី។ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធទីក្រុង ADB នឹងផ្តោតទៅលើការផ្គត់ផ្គង់ទឹកអនាម័យ ការគ្រប់គ្រងកាកសំណល់ និងការដឹកជញ្ជូនក្នុងទីក្រុង។ ជាងនេះទៅទៀត ADB នឹងបន្តផ្តល់ការស្តារនីតិសម្បទាជាអាទិភាព និងជំនួយលើការកសាងស្ថានភាពក្រោយជម្លោះ និងក្រោយគ្រោះមហន្តរាយ។

---

[២៥] តាមរយៈការពិគ្រោះយោបល់ក្នុងតំបន់ ADB បានពិចារណាលើការឆ្លើយតបដែលខ្លួនបានទទួលពីប្រទេស DMCs ភាគីពាក់ព័ន្ធមួយចំនួន និងការវាយតម្លៃ ដែលធ្វើឡើងដោយនាយកដ្ឋានវាយតម្លៃកិច្ចប្រតិបត្តិការ។

[២៦] ប្រទេស DMCs ទាំងអស់ បានបង្ហាញនូវការគាំទ្រយ៉ាងមុតមាំចំពោះការបន្តប្រតិបត្តិការទៅលើហេដ្ឋារចនាសម្ព័ន្ធ។

ប្រតិបត្តិការរបស់ ADB លើហេដ្ឋារចនាសម្ព័ន្ធ នឹងមិនកំណត់ត្រឹមតែការស្ថាបនាទ្រព្យរូបវន្តនោះទេ។ ប្រតិបត្តិការទាំងនោះនឹងរាប់បញ្ចូលទាំងការកែលម្អលើការបែងចែកសេវាហេដ្ឋារចនាសម្ព័ន្ធ ដែលនឹងបង្កើតបាននូវបរិយាកាសជួយជម្រុញលើការអភិវឌ្ឍន៍វិស័យឯកជន។ ADB នឹង (១)កសាងសមត្ថភាពរបស់ប្រទេស DMCs សម្រាប់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឱ្យប្រសើរឡើង (២)លើកម្ពស់កំណែទម្រង់គោលនយោបាយ និងស្ថាប័នដើម្បីជួយបង្កើនប្រសិទ្ធផលនៃប្រតិបត្តិការ និងនិរន្តរភាពនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ និង (៣)គាំទ្រលើប្រព័ន្ធចែកចាយដើម្បីបង្កើនការធ្វើពាណិជ្ជកម្ម និងការវិនិយោគទុនដោយសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងបង្កើតកាលានុវត្តភាពពីកំណែទម្រង់គោលនយោបាយ និងស្ថាប័ន។ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធរបស់ ADB នឹងសង្កត់ធ្ងន់ទៅលើភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងការចូលរួមរបស់វិស័យឯកជន។ ADB នឹងលើកកម្ពស់តួនាទីរបស់ខ្លួនឱ្យបានធំធេងបន្ថែមទៀតសម្រាប់វិស័យឯកជននៅក្នុងការផ្តល់ហិរញ្ញប្បទាន ទោះជាតាមលក្ខណៈជាអ្នកឧបត្ថម្ភគម្រោង ឬផលប័ត្រស្ថាប័ន (Institutional bond)ឬជាវិនិយោគិនសមធម៌ក៏ដោយ។ តួនាទីបន្ទាប់របស់ ADB នឹងបង្កើននូវការផ្គត់ផ្គង់មូលធនចំពោះហេដ្ឋារចនាសម្ព័ន្ធក្នុងការអភិវឌ្ឍតំបន់។ ទោះជាយ៉ាងណាក៏ដោយ ក៏ការកែលម្អទីផ្សារបំណុលក្នុងស្រុករបស់ប្រទេសមួយ នឹងត្រូវមានជាចាំបាច់ ដើម្បីបង្កើនលំហូរមូលនិធិទៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

## ២. បរិស្ថាន

ADB នឹងពង្រឹងការយកចិត្តទុកដាក់នៃប្រតិបត្តិការរបស់ខ្លួនទៅលើបរិស្ថាន ដើម្បីសម្រេចឱ្យបាននូវកំណើនប្រកបដោយនិរន្តរភាពបរិស្ថានសម្រាប់តំបន់។ ADB នឹងពង្រីកការលើកកម្ពស់ និងការវិនិយោគទៅលើការគ្រប់គ្រងបរិស្ថានឱ្យបានសមស្រប ខណៈពេលដែលកំពុងបង្កើនដើមទុនលើប្រតិបត្តិការឧត្តមភាពរបស់ខ្លួន ដូចជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ហិរញ្ញវត្ថុ។ នៅក្នុងកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួន ADB នឹងផ្តោតទៅលើ :

(i) **បម្រែបម្រួលអាកាសធាតុ:** ADB នឹងជួយប្រទេស DMCs ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គេឆ្ពោះទៅរកកំណើនដែលប្រើប្រាស់កាបូនទាប (low-carbon growth) ដោយ: (ក)កែលម្អប្រសិទ្ធផលនៃថាមពល (ខ) ពង្រីកការប្រើប្រាស់ប្រភពថាមពលបរិសុទ្ធ (គ)កាត់បន្ថយការបញ្ចេញឧស្ម័នអាគារកញ្ចក់ ដូចជា Methane ដែលកើតចេញពីការចាក់បំពេញដី (ឃ)ធ្វើទំនើបកម្មប្រព័ន្ធដឹកជញ្ជូនសាធារណៈ និង (ង) បញ្ឈប់ការកាប់បំផ្លាញព្រៃឈើ។ ADB នឹងជួយដល់ប្រទេស DMCs ផងដែរ ឱ្យសម្របទៅតាមផលប៉ះពាល់ដែលមិនអាចចៀសផុតបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ ដូចជា ផលប៉ះពាល់ដែលទាក់ទងទៅនឹងសុខភាព តាមរយៈការធ្វើផែនការថ្នាក់ជាតិ និងថ្នាក់ក្រុង ការវិនិយោគលើវិធានការការពារ ការគាំទ្រការធានា និងឧបករណ៍ចែករំលែកហានិភ័យផ្សេងៗ និងគម្រោង "ទប់ទល់នឹងអាកាសធាតុ - climate proofing"។ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ គឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការអភិវឌ្ឍន៍ ។ ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃព្រៃឈើ និងធនធានធម្មជាតិផ្សេងៗទៀត សំរាប់ផ្គត់ផ្គង់ទឹកស្អាត ការការពារជីវសាស្ត្រចម្រុះ និងការគ្រប់គ្រងជាតិកាបូនពីបរិយាកាសដើម្បីទប់

ទល់នឹងការបញ្ចេញឧស្ម័នអាគារកញ្ចក់ នឹងក្លាយជាផ្នែកមួយនៃជំនួយរបស់ ADB ដើម្បីដោះស្រាយបម្រែបម្រួលអាកាសធាតុ។

(ii) **ទីក្រុងដែលអាចរស់នៅបាន:** ដើម្បីកាត់បន្ថយជាតិកាបូនពីទីក្រុងនៅតំបន់អាស៊ី ឧទាហរណ៍ បរិមាណនៃឧស្ម័នអាគារកញ្ចក់ដ៏គ្រោះថ្នាក់ដែលបានបញ្ចេញ ADB នឹងជួយប្រទេស និងទីក្រុងនៅក្នុងប្រទេសទាំងនោះដើម្បីដោះស្រាយបញ្ហាបរិស្ថានមួយចំនួនដែលបណ្តាលមកពីការរីកចម្រើននៃទីក្រុងដ៏ឆាប់រហ័ស។ ជំនួយទាំងនេះរួមមានការកាត់បន្ថយការបំពុលបរិស្ថានក្នុងខ្យល់ និងក្នុងទឹក ការគាំទ្ររបៀបដឹកជញ្ជូនដែលស្អាត ការកែលម្អប្រព័ន្ធសម្រាប់គ្រប់គ្រងកាកសំណល់រឹង និងការកាត់បន្ថយកាកសំណល់ក្នុងទីក្រុង។

(iii) **សកម្មភាពបំពេញបន្ថែម:** ADB នឹងជួយដល់គំនិតផ្តួចផ្តើមលើបរិស្ថាន ទៅក្នុងគោលនយោបាយ និងកម្មវិធីវិនិយោគរបស់ប្រទេស DMCs ខណៈពេលដែលកំពុងជួយពង្រឹងច្បាប់ បទប្បញ្ញត្តិ និងបង្កើនសមត្ថភាពរបស់ស្ថាប័នសាធារណៈលើគំនិតផ្តួចផ្តើមអំពីបរិស្ថាន។ ADB នឹងបន្តពង្រឹងការការពារបរិស្ថាននៅក្នុងប្រតិបត្តិការរបស់ខ្លួន និងក្នុងប្រព័ន្ធរបស់ប្រទេស លើកកម្ពស់ និងគាំទ្រសហប្រតិបត្តិការក្នុងតំបន់ ដើម្បីផ្តល់វិធីសាស្ត្រ និងដំណោះស្រាយដ៏មានប្រសិទ្ធភាពលើសេវាបរិស្ថានសាធារណៈ និងសម្របសម្រួលការផ្ទេរចំណេះដឹងស្តីពីការគ្រប់គ្រងបរិស្ថាន និងបច្ចេកវិទ្យាថ្មី។

## ៣. កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មក្នុងតំបន់ (RCI)

ស្របទៅតាមកម្មវិធីយុទ្ធសាស្ត្រថ្មី ដើម្បីលើកកម្ពស់ការធ្វើសមាហរណកម្មក្នុងតំបន់ឱ្យបានធំទូលាយបន្ថែមទៀត ADB នឹងបង្កើនការគាំទ្ររបស់ខ្លួនចំពោះ RCI ដោយបង្កើនទាំងបរិមាណនៃប្រតិបត្តិការ RCI និងការរួមចំណែករបស់ RCI នៅក្នុងប្រតិបត្តិការទាំងមូល។ ដើម្បីដំណើរការដូច្នេះបាន ADB នឹងព្យាយាមបំពេញនូវតម្រូវការដែលមិនបានបំពេញមួយចំនួនសម្រាប់ការផ្តួចផ្តើមរបស់ RCI ក្នុងតំបន់។ ការវិនិយោគរបស់ ADB នឹងពន្លឿនកំណើន និងភាពជាដៃគូសេដ្ឋកិច្ច ព្រមទាំង ដើម្បីដោះស្រាយហានិភ័យ និងការប្រឈមមុខរួមមួយចំនួន។ ក្រោមយុទ្ធសាស្ត្រ ឆ្នាំ ២០២០ ADB នឹងដើរតួនាទីបួននៅក្នុងតំបន់ (១) បង្កើនធនធានហិរញ្ញវត្ថុសម្រាប់គម្រោង កម្មវិធី RCI និងជំនួយបច្ចេកទេសដែលពាក់ព័ន្ធ[២៧] និង/ឬ ជួយប្រទេស DMCs ក្នុងការកៀងគរមូលនិធិ និងជំនួយបច្ចេកទេស (២) ពង្រីកការបង្កើត និងផ្សព្វផ្សាយចំណេះដឹង និងព័ត៌មានស្តីអំពី RCI ដល់ប្រទេស DMCs (៣) បង្កើនការគាំទ្រចំពោះប្រទេស DMCs និងអង្គការក្នុងតំបន់ដើម្បីកសាងសមត្ថភាពស្ថាប័នក្នុងការគ្រប់គ្រង RCI និង (៤) ពង្រឹងតួនាទីរបស់ ADB ជាកាតាលីករ និងអ្នកសម្របសម្រួល RCI សម្រាប់ប្រទេស DMCs។ សកម្មភាពទាំងនេះ មានគោលបំណងបង្កើនសកម្មភាព

[២៧] TA ជួយបណ្តាប្រទេសនានាដើម្បីកំណត់ និងរៀបចំគម្រោង លើកកម្ពស់ស្ថាប័ន រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឬជម្រុញកិច្ចសហប្រតិបត្តិការក្នុងតំបន់។ TA អាចទទួលហិរញ្ញប្បទានដោយជំនួយឥតសំណង ឬ កម្ចី (ម្តងម្កាល) តាមរយៈថវិកាកណ្តាលរបស់ ADB ឬ មូលនិធិពិសេសមួយចំនួន ដែលផ្តល់ឱ្យដោយម្ចាស់ជំនួយជាសមាជិករបស់ ADB ។

RCI ជាពិសេស នៅក្នុងអនុតំបន់ដែលកំពុងខ្វះខាត និងកំពុងត្រូវការផលប្រយោជន៍ពី RCI ដើម្បីបំពេញតម្រូវការដែលកំពុងតែកើតមានឡើងសម្រាប់ការវិនិយោគដើម្បីផលប្រយោជន៍តំបន់ និងពិភពលោក ដូចជា បម្រែបម្រួលអាកាសធាតុ ជាដើម ។

## ៤. ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ ដើម្បីធានាកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងនាំមុខដោយវិស័យឯកជន ។ ជាងនេះទៅទៀត ដោយគ្មានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងការធានារ៉ាប់រងសង្គមដោយនិរន្តរភាព រួមទាំង ប្រាក់សោធននិវត្តន៍ផងនោះ អ្នកក្រីក្រ នឹងត្រូវបានផាត់ចេញពីដំណើរការ និងផលប្រយោជន៍នៃកំណើន ។ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB នឹងពង្រឹងការគាំទ្ររបស់ខ្លួនចំពោះវិស័យហិរញ្ញវត្ថុថ្នាក់តំបន់ និងថ្នាក់ជាតិដោយការជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ស្ថាប័ន ផលិតផល និងសេវាកម្ម ។ ដើម្បីលើកកម្ពស់កំណើនចម្រុះ ADB នឹងជួយបង្កើតបរិយាកាសសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ស្ថាប័នហិរញ្ញវត្ថុជនបទ សហគ្រាសខ្នាតតូច និងមធ្យម ហើយនឹងជួយផ្សព្វផ្សាយនូវការប្រើប្រាស់បច្ចេកវិទ្យាដើម្បីពង្រីកការទទួលបាននៃប្រព័ន្ធហិរញ្ញវត្ថុផ្លូវការដល់តំបន់ជនបទ ។ នៅថ្នាក់តំបន់ ADB នឹងបន្តគាំទ្រការធ្វើពាណិជ្ជកម្មឆ្លងដែន ។ ចំពោះការបង្កើតនូវទីផ្សារផលប័ត្រក្នុងតំបន់ ADB នឹងសម្របសម្រួលដល់ការបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិ យន្តការធានាឥណទានរួម និងប្រព័ន្ធទូទាត់ហិរញ្ញវត្ថុតំបន់មួយ ។ តាមរយៈការផ្តួចផ្តើមបែបនេះ ADB នឹងបន្តជួយចាត់ចែងប្រាក់សន្សំរបស់តំបន់អោយប្រែក្លាយទៅជាការវិនិយោគផ្សេងៗប្រកបដោយផ្លែផ្ការបំផុតជាពិសេស ក្នុងការអភិវឌ្ឍទីផ្សារមូលធន ។ ADB នឹងបន្តជួយកសាងសមត្ថភាពរបស់ស្ថាប័នហិរញ្ញវត្ថុ និងនិយតករ ដោយណែនាំនូវការអនុវត្តអន្តរជាតិដ៏ល្អបំផុត ដោយធ្វើសហប្រតិបត្តិការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ។ ADB ក៏នឹងគាំទ្រផងដែរដល់ការបង្កើតយន្តការប្រឆាំងការលាងលុយកខ្វក់ ដោយសហការជាមួយទីភ្នាក់ងារផ្តល់ជំនួយនានា ។

## ៥. ការអប់រំ

ការវិនិយោគក្នុង និងលទ្ធភាពទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈមានភាពចាំបាច់ចំពោះកំណើនចម្រុះបន្ថែមទៀត ។ ADB បានបង្ហាញសមិទ្ធផលអប់រំដែលបានទទួលជោគជ័យក្នុងតួនាទីដឹកនាំការអភិវឌ្ឍគម្រោង និងកម្មវិធីអប់រំទូទាំងប្រទេស ។ ADB នឹងបន្តពង្រីកការគាំទ្រនូវលទ្ធភាពទទួលបានការអប់រំមូលដ្ឋាន និងមធ្យមសិក្សា ឱ្យប្រកបដោយគុណភាពខ្ពស់ ជាពិសេសនៅប្រទេស DMCs តូចៗ និងក្រីក្រ ។ ADB នឹងបង្កើនការយកចិត្តទុកដាក់ដោយផ្ទាល់របស់ខ្លួនដើម្បីលើកកម្ពស់គុណភាពអប់រំ វគ្គបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំង ជំនាញជ្រើសរើសមួយចំនួននៅក្នុងឧត្តមសិក្សា ។ ADB ក៏នឹងពង្រីកការគាំទ្រផងដែរដល់អនុវិស័យអប់រំក្រោយមធ្យមសិក្សា ។ ADB នឹងជួយអភិវឌ្ឍគោល-នយោបាយ និងសមត្ថភាព ដើម្បីធានាថា កម្មវិធីកែលម្អការអប់រំត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព ។ នៅក្នុងវិស័យទាំងអស់នេះ

ADB នឹងស្វែងរកកាលានុវត្តភាពសម្រាប់អភិវឌ្ឍន៍វិធីសាស្ត្រ និងឧបករណ៍ថ្មីៗដែលពាក់ព័ន្ធជាមួយនឹងភាពជាដៃគូរវាងផ្នែកសាធារណៈ និងឯកជន។

## វិស័យប្រតិបត្តិការនានា

ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB នឹងធានាថា ការជ្រើសរើស និងការឆ្លើយតបត្រូវតែដើរទន្ទឹមគ្នា ដើម្បីអនុញ្ញាតឱ្យ ADB ផ្តល់ប្រទេស DMCs នូវលទ្ធផល និងសេវាកម្មដែលមានការពាក់ព័ន្ធបំផុតនៅក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍជាតិ និងតំបន់។ ក្នុងដំណើរការយុទ្ធសាស្ត្រភាពជាដៃគូជាមួយរដ្ឋាភិបាលនៃប្រទេស DMCs ADB នឹងកំណត់ការរួមបញ្ចូលគ្នានៃផលិតផល និងសេវាកម្មដ៏ត្រឹមត្រូវរបស់ខ្លួន។ សម្រាប់បញ្ហានានាក្នុងអាទិភាពប្រតិបត្តិការសំខាន់ៗរបស់ខ្លួន ADB នឹងប្រឹងប្រែងលើកទឹកចិត្តសកម្មភាពសហប្រតិបត្តិការ និងជួយបង្កើតកម្មវិធីភាពជាដៃគូ។ ADB នឹងទទួលតួនាទីភាពជាអ្នកដឹកនាំ និងការប្រើប្រាស់ធនធានរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងការប្រឈមមុខលើការអភិវឌ្ឍរបស់ប្រទេស DMCs ខណៈដែលខ្លួនកំពុងតែកៀងគរ និងគ្រប់គ្រងធនធានខាងក្រៅ។ ADB ប៉ាន់ប្រមាណថា ប្រតិបត្តិការប្រមូលផ្តុំរបស់ខ្លួន ៨០% នឹងធ្វើទៅលើវិស័យសំខាន់ៗចំនួនប្រាំ ។ ADB ក៏នឹងធ្វើប្រតិបត្តិការក្នុងកម្រិតមួយសម្រាប់វិស័យផ្សេងៗទៀតដែលត្រូវការវត្តមានរបស់ខ្លួនផងដែរ។

## ១. សុខភាព

ADB ទទួលស្គាល់ថា សុខភាពមានសារៈសំខាន់ណាស់ចំពោះការអភិវឌ្ឍន៍ ផលិតភាព ការចូលរួមក្នុងសង្គម និងសមធម៌យេនឌ័រ។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍អន្តរជាតិបានបង្កើតដៃគូភាពសុខភាពសកលប្រហែល៧០ ក្នុងអំឡុងពេលជាងដប់ឆ្នាំកន្លងមកនេះ។ សហគមន៍អន្តរជាតិទាំងនេះ បានបង្កើនការផ្តល់ហិរញ្ញប្បទានដល់វិស័យសុខាភិបាលនៃប្រទេស DMCs និងបានពង្រីកលទ្ធភាពទទួលបានសេវា និងផលិតផលសុខាភិបាលដែលមានគុណភាពជាលក្ខណៈអន្តរជាតិ។ ក្នុងបរិយាកាសនេះ ADB នឹងរួមចំណែកលើកកម្ពស់វិស័យសុខាភិបាល ភាគច្រើន នឹងធ្វើតាមតាមរយៈគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជាការគ្រប់គ្រងទឹកស្អាត និងអនាម័យ និងធ្វើតាមរយៈការងារអភិបាលកិច្ចដែលផ្តោតទៅលើការគ្រប់គ្រងចំណាយសាធារណៈ ដើម្បីចែកចាយសេវា និងកម្មវិធីសុខាភិបាលប្រកបដោយប្រសិទ្ធភាពដល់ក្រុមប្រជាជនទាំងអស់។ ចំពោះបញ្ហាដែលទាក់ទងទៅនឹងផ្នែកសុខាភិបាលដទៃទៀត ADB ត្រូវតែមានការជ្រើសរើស និងការផ្តោតការយកចិត្តទុកដាក់ខ្ពស់ ដោយចូលរួមនៅក្នុងតួនាទីដែលបានកំណត់យ៉ាងច្បាស់លាស់ក្នុងដៃគូភាពផ្ទាល់ជាមួយនឹងស្ថាប័នជំនាញផ្សេងៗទៀត។ ADB នឹងបន្តកិច្ចសហការ ដើម្បីសម្រាល និងគ្រប់គ្រងការឆ្លង និងរាលដាលនៃជម្ងឺឆ្លង ជាពិសេស ជម្ងឺអេដស៍ នៅក្នុងគម្រោងដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតរបស់ខ្លួន។ ADB នឹងផ្តល់ជំនួយកំណត់ទុកផ្សេងៗទៀត រួមទាំង ការអភិវឌ្ឍសមត្ថភាពសម្រាប់ប្រទេស DMCs ដែលជាញឹកញាប់មានបញ្ហាអន្តោប្រវេសន៍ក្នុងស្រុក និងឆ្លងកាត់ព្រំដែនរបស់បុគ្គលដែលមានផ្ទុកជម្ងឺឆ្លង

ប្រកបដោយគ្រោះថ្នាក់។ ADB នឹងសហការជាមួយដៃគូដទៃទៀតដើម្បីឃ្លាំមើល[២៨] ចែករំលែកនូវព័ត៌មាន និងធ្វើផែនការនៅថ្នាក់ជាតិ និងតំបន់នៅពេលដែលមានការលេចឡើងនូវការព្រួយបារម្ភអំពីបញ្ហាឆ្លងជម្ងឺទូទាំងតំបន់។

## ២. កសិកម្ម

កាលពីអតីតកាល កសិកម្មជម្រុញនូវកំណើនភាគច្រើនក្នុងតំបន់តាមរយៈវដ្តជនបទមូលដ្ឋាន (roral-based cycle) សម្រាប់ការលើកកម្ពស់ផលិតភាព ការផ្តល់ការងារធ្វើ និងការប្រើប្រាស់ផ្សេងៗ។ ជាលទ្ធផល កសិកម្មជួយជម្រុញដល់កំណើនឧស្សាហកម្ម។ ទោះជាយ៉ាងណាក៏ដោយ នៅពេលសេដ្ឋកិច្ចមានការផ្លាស់ប្តូរ ការរួមចំណែករបស់កសិកម្មចំពោះកំណើនសេដ្ឋកិច្ចជាតិកំពុងតែមានការធ្លាក់ចុះ។ ភាគច្រើននៃអ្នកក្រីក្រនៅតែរស់នៅក្នុងតំបន់ជនបទនៅឡើយ ហើយវិស័យកសិកម្មនៅតែជាប្រភពលើកកម្ពស់ផលិតភាព ផ្តល់ការងារតាមរដូវ និងប្រភពនៃកំណើនប្រាក់ចំណូល ជាពិសេស នៅពេលដែលវាត្រូវបានតភ្ជាប់ទៅនឹងទីផ្សារទីក្រុង ឧស្សាហកម្ម និងទីផ្សារនាំចេញ។ ដូច្នេះហើយ ការគាំទ្រចំពោះវិស័យកសិកម្ម និងតំបន់ជនបទ គឺជាផ្នែកមូលដ្ឋានមួយនៃយុទ្ធសាស្រ្តកំណើនចម្រុះ។ ជាងនេះទៅទៀត កំណើនប្រជាជន សម្ពាធលើធនធានធម្មជាតិ ការប្រកួតប្រជែងលើការប្រើប្រាស់ស្បៀងអាហារ ដំណាំ ផលប៉ះពាល់អាកាសធាតុដ៏ខ្លាំង និងបម្រែបម្រួលអាកាសធាតុ នឹងបង្កើននូវហានិភ័យចំពោះសុវត្ថិភាពស្បៀងអាហារទៅថ្ងៃអនាគត។ ADB នឹងគាំទ្រការអភិវឌ្ឍកសិកម្ម និងជនបទ ភាគច្រើន នឹងធ្វើតាមរយៈគំរោងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ធ្វើការដឹកជញ្ជូននៅជនបទ ប្រព័ន្ធធារាសាស្រ្ត និងទឹក និងមីក្រូហិរញ្ញវត្ថុ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងបំពេញបន្ថែមដោយការគ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាព RCI ដូចជា សកម្មភាពដែលទាក់ទងទៅនឹងការវិនិយោគ និងការធ្វើពាណិជ្ជកម្មកសិកម្ម នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ តាមរយៈភាពជាដៃគូជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ឯកទេស និងអង្គការមិនមែនរដ្ឋាភិបាលដ៏ទៃទៀត។

## ៣. ជំនួយសម្រាប់ការសង្គ្រោះបន្ទាន់ និងគ្រោះមហន្តរាយ

តំបន់អាស៊ី ប៉ាស៊ីហ្វិក ទទួលរងគ្រោះមហន្តរាយធម្មជាតិច្រើនជាងតំបន់ផ្សេងៗទៀតនៅលើពិភពលោក។ ADB មានប្រវត្តិជាយូរមកហើយក្នុងការឆ្លើយតបបានយ៉ាងឆាប់រហ័ស និងយ៉ាងមានប្រសិទ្ធភាពចំពោះតម្រូវការបន្ទាន់សម្រាប់ការស្តារនិងស្ថាបនាប្រទេស DMCs ឡើងវិញ។ ក្រោមយុទ្ធសាស្រ្តឆ្នាំ ២០២០ ADB នឹងបន្តជួយគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

---

[២៨] នៅក្នុងប្រទេស ឬវិស័យដែលផលប័ត្ររបស់ ADB មិនសកម្ម គឺដោយសារកត្តានានា ដូចជា បំណុលមិនសង អសន្តិសុខ ឬអភិបាលកិច្ចទន់ខ្សោយ។ ការឃ្លាំមើលព័ត៌មានខ្លីៗជួយរក្សាមូលដ្ឋានចំណេះដឹងរបស់ ADB និងការយល់ដឹង ចំពោះនិន្នាការសេដ្ឋកិច្ច និងសង្គម។ ការឃ្លាំមើលព័ត៌មានខ្លីៗ ជួយឱ្យ ADB ឆ្លើយតបបានយ៉ាងឆាប់រហ័សនៅពេលស្ថានភាពតម្រូវឱ្យមានអន្តរាគមន៍ជាបន្ទាន់ និង/ឬ ការចាប់ផ្តើមសកម្មភាពរបស់ ADB ឡើងវិញ។ ការឃ្លាំមើលព័ត៌មានខ្លីៗទាំងនេះ ជាធម្មតាធ្វើតាមរយៈភាគីទីបី ដូចជា អង្គការមិនមែនរដ្ឋាភិបាល ឬ ទីភ្នាក់ងារជាដៃគូរបស់អង្គការសហប្រជាជាតិ ដែលកំពុងបំពេញការងារនៅនឹងកន្លែង។

និងផ្តល់នូវការឆ្លើយតបដំបូង និងរយៈពេលពាក់កណ្តាលនៃគ្រោះមហន្តរាយ និងជំនួយ ដោយសហការជាមួយទីភ្នាក់ងារផ្តល់ជំនួយឯកទេសដ៏ទៃទៀត។

## V. គោលដៅ និងសកម្មភាពការងារ

ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB នឹងប្តូរដំណើរប្រតិបត្តិការ និងកែសម្រួលលក្ខណៈស្ថាប័នរបស់ខ្លួន ដែលបានណែនាំដោយចំណុចរួមសំខាន់៧ដូចខាងក្រោម :

(i) **ភាពឆ្លើយតប:** ចំពោះផលប្រយោជន៍នៃការអភិវឌ្ឍន៍ជាក់លាក់របស់ប្រទេសជាសមាជិកទាំងអស់ ។

(ii) **ការទទួលស្គាល់កម្មសិទ្ធរបស់ប្រទេស:** ដើម្បីសម្រួលឱ្យប្រទេសជាដៃគូមានលទ្ធភាពអនុវត្តភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពលើគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពអភិវឌ្ឍន៍ ។

(iii) **ការផ្សាភ្ជាប់ទៅនឹងស្តង់ដារសីលធម៌ និងវិជ្ជាជីវៈខ្ពស់បំផុត:** សម្រាប់អង្គភាព និងកម្មវិធីរបស់ខ្លួន និងទំនាក់ទំនងរបស់ភាគីដែលពាក់ព័ន្ធនានា ។

(iv) **ភាពជាអ្នកដឹកនាំ និងសេវាកម្មលេចធ្លោ:** តាមរយៈការចែករំលែកព័ត៌មាន និងចំណេះដឹង និងតាមរយៈសកម្មភាពសហប្រតិបត្តិការលើបញ្ហាដែលកំពុងប្រឈមនៅក្នុងតំបន់។

(v) **ការប្តេជ្ញាចំពោះភាពជាដៃគូ:** ជាមួយសមាជិកដទៃទៀតនៃសហគមន៍អន្តរជាតិនៅក្នុងការអនុវត្តកម្មវិធីផែនការ និងការកៀងគរធនធានសម្រាប់ការអភិវឌ្ឍក្នុងតំបន់ និង

(vi) **គណនេយ្យភាព និងការផ្តោតលើលទ្ធផល:** ដោយការកំណត់គោលបំណងច្បាស់លាស់ និងការរៀបចំការងារ និងធនធានដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងនោះ។

ដើម្បីធានានូវគុណភាព ប្រសិទ្ធផល និងប្រសិទ្ធភាពនៃការរីកចម្រើន និងប្រតិបត្តិការរបស់ខ្លួន ADB នឹងប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលដែលនឹងបញ្ចូលសូចនាករគម្រោង ប្រទេស និងស្ថាប័ន។

### ការផ្លាស់ប្តូររបស់ ADB ឆ្ពោះទៅឆ្នាំ ២០២០ : គោលដៅប្រតិបត្តិ

សូចនាករ និងគោលដៅខាងក្រោមនេះ នឹងត្រូវប្រើប្រាស់ដើម្បីវាស់វែងការរីកចម្រើនរបស់ ADB ក្នុងការកែប្រែប្រតិបត្តិការរបស់ខ្លួនដោយអនុលោមទៅតាមកត្តានៃការផ្លាស់ប្តូរសំខាន់៧ និងវិស័យប្រតិបត្តិស្នូលរបស់យុទ្ធសាស្ត្រឆ្នាំ ២០២០។

### ១. ផលប័ត្រកម្ចីរបស់ ADB

គេរំពឹងទុកថា ផលប័ត្រកម្ចីរបស់ ADB នឹងមានការផ្លាស់ប្តូរ ហើយនឹងមានកាន់តែច្រើនបន្ថែមទៀតនៅក្នុងវិស័យយុទ្ធសាស្ត្រ និងប្រតិបត្តិការថ្មីរបស់ខ្លួន ហើយមានភាពខុសគ្នាពីផលប័ត្រកម្ចីបច្ចុប្បន្នរបស់ ADB នៅក្នុងបួនចំណុចដូចខាងក្រោម :

(i) **ចំណែកដ៏លើសលប់នៃប្រតិបត្តិការរបស់ ADB នៅក្នុងវិស័យប្រតិបត្តិការស្នូលរបស់ខ្លួន:** ប្រតិបត្តិការរបស់ ADB នឹងបង្កើនការយកចិត្តទុកដាក់ទៅលើវិស័យប្រតិបត្តិការសំខាន់ប្រាំ ហើយមានការអនុម័តសរុបប្រចាំឆ្នាំ ៨០% ត្រឹមឆ្នាំ ២០១២។

(ii) **ការបង្កើនការអភិវឌ្ឍវិស័យឯកជន និងប្រតិបត្តិការវិស័យឯកជន នៅគ្រប់វិស័យប្រតិបត្តិការទាំងអស់:** ការគាំទ្ររបស់ ADB ចំពោះការអភិវឌ្ឍវិស័យឯកជននៅក្នុងតំបន់ នឹងមានការកើនឡើងយ៉ាងខ្លាំង ទាំងចំនួននៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB និងទាំងភាគហ៊ុននៃប្រតិបត្តិការប្រចាំឆ្នាំរបស់ខ្លួន ដែលមានគោលដៅ ៥០% ត្រឹមឆ្នាំ ២០២០។

(iii) **ការបង្កើនជំនួយដើម្បីគាំទ្រការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបរិស្ថាន:** ADB នឹងបង្កើនជំនួយរបស់ខ្លួនចំពោះការអភិវឌ្ឍប្រកបដោយនិរន្តរភាពបរិស្ថាន រួមទាំង កិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយការបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីត និងបម្រែបម្រួលអាកាសធាតុ។ ប្រតិបត្តិការទាំងនេះ នឹងក្លាយទៅជាចំណែកយ៉ាងសំខាន់នៃប្រតិបត្តិការរបស់ ADB ត្រឹមឆ្នាំ ២០១២។

(iv) **ការបង្កើនកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់នៅក្នុងវិស័យប្រតិបត្តិការទាំងអស់:** ដើម្បីបំពេញនូវតម្រូវការដែលបានរំពឹងទុក និងដើម្បីសម្រេចនូវគោលដៅរបស់ខ្លួនក្នុងការលើកទឹកចិត្ត និងការគាំទ្រ RCI ADB នឹងបង្កើនកម្ចីសរុបរបស់ខ្លួនសម្រាប់វិស័យសាធារណៈ និងឯកជននៅថ្នាក់តំបន់ និងអនុតំបន់។ កម្ចីនេះនឹងរៀបចំសម្រាប់ចំនួនដែលកំពុងតែកើនឡើងនៃប្រតិបត្តិការទាំងមូល យ៉ាងហោចណាស់ ឱ្យបាន ៣០% ត្រឹមឆ្នាំ ២០២០។

## ២. ការបង្កើនដៃគូភាព

ADB នឹងធ្វើដៃគូភាពជាផ្នែកស្នូលមួយនៃគំរូការងាររបស់ខ្លួន។ ដៃគូភាពទាំងនេះ នឹងកៀងគរធនធានហិរញ្ញវត្ថុ លើកកម្ពស់ការយល់ដឹង ដាក់លទ្ធភាពដ៏វិសេសរបស់ ADB ឱ្យប្រើប្រាស់ធំទូលាយ និងកាន់តែប្រសើរជាងមុន បំពេញតម្រូវការពិសេសសម្រាប់គម្រោងអភិវឌ្ឍន៍ឯកទេស និងជួយលើកកម្ពស់ប្រសិទ្ធភាពជំនួយទូទាំងតំបន់។ ដៃគូភាព នឹងក្លាយទៅជាស្នូលកណ្តាលមួយនៃការចូលរួមរបស់ ADB ក្នុងការរៀបចំផែនការ ការផ្តល់ហិរញ្ញប្បទាន និងការអនុវត្តប្រតិបត្តិការ។ របៀបវារៈដៃគូភាពក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ នឹងបង្កើនលំហូរធនធាន ជួយសម្របសម្រួលពាណិជ្ជកម្ម ផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីៗ និងបង្កើនបណ្តាញជំនាញការងារ។ ក្រៅពីវិស័យប្រតិបត្តិការស្នូលរបស់ខ្លួន ADB អាចផ្ទេរតួនាទីដឹកនាំនៅក្នុងកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍។ ផ្នែកជាក់លាក់នៃគោលដៅនេះ រួមមាន :

(i) **ការបង្កើនដៃគូភាពលើប្រតិបត្តិការ និងសហហិរញ្ញប្បទានជាមូលដ្ឋាន:** កម្ចីសហហិរញ្ញប្បទានរបស់ ADB នឹងបង្កើននូវអត្រាមួយលឿនជាងប្រតិបត្តិការដែលផ្តល់ហិរញ្ញប្បទានតែឯងរបស់ ADB ជាមួយនឹងគោលដៅរយៈពេលវែងនៃសហហិរញ្ញប្បទានផ្ទាល់ប្រចាំឆ្នាំសរុបលើសចំនួនគម្រោងហិរញ្ញប្បទានដែល ADB ផ្តល់តែឯង។

(ii) **ការផ្សព្វផ្សាយចំណេះដឹងឱ្យបានទូលំទូលាយបន្ថែមទៀត:** ADB នឹងពង្រឹងដំណោះស្រាយចំណេះដឹង ដើម្បីទទួលបានការវាយតម្លៃខ្ពស់ពីអតិថិជនរបស់ខ្លួនដោយផ្អែកលើការអង្កេតទស្សនៈយល់ដឹង (perception survey)[២៩] និងការសិក្សាវាយតម្លៃពិសេសរបស់នាយកដ្ឋានវាយតម្លៃប្រតិបត្តិការស្តីពីការអនុវត្តគម្រោងជំនួយបច្ចេកទេស[៣០]។ ADB នឹងពង្រីកបណ្តាញជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ការចែករំលែកចំណេះដឹង និងទស្សនៈផ្សេងៗ។

## ៣. ការតាំងចិត្តអនុវត្តសេចក្តីថ្លែងការណ៍ក្រុងប៉ារីស

ក្នុងការស្ថាបនាដៃគូភាពជាមួយប្រទេស DMCs និងភ្នាក់ងារអភិវឌ្ឍន៍ដទៃទៀតរបស់ខ្លួន ADB នឹងចែករំលែកការទទួលខុសត្រូវដែលបានកំណត់ មានតម្លាភាព សម្របសម្រួល និងមានការទទួលខុសត្រូវទៅវិញទៅមក ដើម្បីកែលម្អប្រសិទ្ធភាពជំនួយ។ ADB នឹងបន្តរាយការណ៍សកម្មភាពប្រតិបត្តិ និងស្ថាប័ន ក្រោមប្រព័ន្ធវាយតម្លៃសកម្មភាពប្រចាំឆ្នាំរួម និងរបាយការណ៍អង្កេតតាមដានប្រចាំឆ្នាំពិភពលោក ដែលរបាយការណ៍ទាំងពីរនេះត្រូវបានរៀបចំឡើងតាមរយៈកិច្ចសហការរវាងធនាគារអភិវឌ្ឍន៍ពហុភាគី និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងៗទៀត។ ADB ធ្វើការប្តេជ្ញាដើម្បីបំពេញរាល់ការតាំងចិត្តសំខាន់ៗរបស់ខ្លួន ក្រោមសេចក្តីថ្លែងការណ៍ក្រុងប៉ារីស ដែលមានគោលដៅព្រមព្រៀងឆ្នាំ ២០១២។

## ៤. គោលនយោបាយឆ្លងផុតរបស់ប្រទេស DMCs (DMCs Graduation)

ដោយពិចារណាទៅលើការពិភាក្សាមុនៗនៅក្នុងជំពូកទី៤ ស្តីអំពីសារៈសំខាន់នៃការយល់ដឹងបរិបទអភិវឌ្ឍ និងទស្សនវិស័យចំពោះប្រទេស DMCs នីមួយៗ និងការសន្និដ្ឋាន ដែលថា សេដ្ឋកិច្ចរបស់តំបន់ទាំងមូលនឹងរក្សាកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំងរបស់ខ្លួន ADB មានគោលបំណងជួយប្រទេស DMCs ដើម្បីវាស់វែងការវិវត្តក្រោមគោលនយោបាយឆ្លងផុត (graduation policy) របស់ខ្លួនៈ (១)អ្នកខ្ចីក្រុម "គ" (បណ្តាប្រទេសដែលមានសិទ្ធខ្ចីតែធនធាន OCR) នៅត្រឹមឆ្នាំ ២០០៨ នឹងបានទទួល ឬស្ថិតនៅពាក់កណ្តាលដំណើរការ (medium-term path)ដើម្បីទទួលបានគោលនយោបាយឆ្លងផុតពីជំនួយធម្មតារបស់ ADB ត្រឹមឆ្នាំ ២០២០ (២) អ្នកខ្ចីក្រុម "ខ" (បណ្តាប្រទេសដែលមានសិទ្ធខ្ចីធនធាន ADF និង OCR ) នៅត្រឹមឆ្នាំ ២០០៨ នឹងបានទទួល ឬស្ថិតនៅពាក់កណ្តាលដំណើរការ ដើម្បីទទួលបានគោលនយោបាយឆ្លងផុត OCR ត្រឹមឆ្នាំ ២០២០ និង (៣) អ្នកខ្ចីក្រុម "ក" (ប្រទេសដែលមានសិទ្ធខ្ចីតែធនធាន ADF) នៅត្រឹមឆ្នាំ ២០០៨ នឹងបានទទួល ឬស្ថិតនៅពាក់កណ្តាលដំណើរការ ដើម្បីទទួលបានគោលនយោបាយឆ្លងផុតទៅឋានៈក្រុម "ខ" ត្រឹមឆ្នាំ ២០២០។ ADB នឹងបន្តខិតខំប្រឹងប្រែងដើម្បីធានាថា គ្មានប្រទេសណាមួយត្រូវបានទុកចោលឡើយ ហើយរាល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ត្រូវបានធ្វើឡើងដើម្បីជួយប្រទេសទន់ខ្សោយឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់ខ្លួន។

---

[២៩] ADB ២០០៦: *ការស្ទាបស្ទង់លើការយល់ដឹងរបស់* ADB *: ការស្ទាបស្ទង់ពហុជាតិនៃគំនិតថ្នាក់ដឹកនាំឆ្នាំ ២០០៦* ម៉ានីល ។

[៣០] ADB ២០០៧: *ការសិក្សាវាយតម្លៃពិសេសលើការអនុវត្តនៃសកម្មភាពបច្ចេកទេស* ម៉ានីល ។

## ការផ្លាស់ប្តូររបស់ ADB ឆ្ពោះទៅឆ្នាំ ២០២០ : គោលដៅស្ថាប័ន

ថ្នាក់ដឹកនាំរបស់ ADB តាំងចិត្តបង្កើត និងទ្រទ្រង់ប្រព័ន្ធស្ថាប័ន និងលើកកម្ពស់សមត្ថភាពដែលចាំបាច់សម្រាប់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០។ នៅដំណាក់កាលចាប់ផ្តើមដំបូងរបស់ខ្លួន ថ្នាក់ដឹកនាំមានបំណងផ្តោតទៅលើផ្នែកមូលដ្ឋានបួននៃការកែប្រែស្ថាប័នរបស់ ADB : យុទ្ធសាស្ត្រ ធនធានមនុស្ស រចនាសម្ព័ន្ធស្ថាប័ន និងដំណើរការការងារ។

## ១. ការកែលម្អសម្ព័ន្ធភាពនៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយរួម

ភាពច្រំដែល និងភាពត្រួតស៊ីគ្នាចំពោះការកើនឡើងនៃយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ ADB បណ្តាលឱ្យមានការបែងចែកធនធានរបស់ស្ថាប័នតិចជាងតម្រូវការ។ នៅក្នុងដំណាក់កាលចាប់ផ្តើមដំបូងនៃយុទ្ធសាស្ត្រឆ្នាំ ២០២០ ថ្នាក់ដឹកនាំ នឹងសម្រួលការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្ររួមរបស់ ADB ដើម្បីធ្វើឱ្យយុទ្ធសាស្ត្រឆ្នាំ ២០២០ ក្លាយជាក្របខ័ណ្ឌយុទ្ធសាស្ត្រទូលំទូលាយ និងមានសារៈសំខាន់របស់ ADB។ យុទ្ធសាស្ត្រឆ្នាំ ២០២០ នឹងផ្តោតការយកចិត្តទុកដាក់ និងដឹកនាំដៃគូយុទ្ធសាស្ត្រតាមប្រទេស វិស័យ និងតាមផ្នែក។ កម្មវិធីការងារ និងក្របខ័ណ្ឌថវិកា នឹងឆ្លុះបញ្ចាំង និងគាំទ្រទិសដៅយុទ្ធសាស្ត្ររបស់យុទ្ធសាស្ត្រឆ្នាំ ២០២០ លើមូលដ្ឋានរយៈមធ្យម ដើម្បីធានាថា ប្រតិបត្តិការរបស់ ADB ទៅអនាគតនិងការកៀងគរធនធានស៊ីសង្វាក់គ្នា។ កម្មវិធី និងក្របខ័ណ្ឌនេះ នឹងបង្កើននូវប្រសិទ្ធផលរួម និងលើកកម្ពស់លទ្ធផលអភិវឌ្ឍន៍។ ក្របខ័ណ្ឌលទ្ធផលរបស់ ADB នឹងជួយធ្វើការវាយតម្លៃលើការរីកចម្រើននៃការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០។

## ២. ការអភិវឌ្ឍធនធានមនុស្ស និងជំនាញចម្រុះ

ជាការពិតណាស់ បុគ្គលិករបស់ ADB គឺជាទ្រព្យដ៏សំខាន់បំផុត ហើយសមត្ថភាពក្នុងការជួល និងរក្សាទុកបុគ្គលិកដែលប្រកបដោយជំនាញ និងទេពកោសល្យ នឹងផ្តល់ឱ្យ ADB នូវសក្តានុពលដើម្បីសម្រេចនូវទស្សនវិស័យរបស់ខ្លួនសម្រាប់តំបន់។ ទោះបីជា ADB មានការទទួលស្គាល់ជាប្រវត្តិសាស្ត្រថាបានប្រើប្រាស់ធនធានមនុស្សរបស់ខ្លួនប្រកបដោយប្រសិទ្ធផលក៏ដោយ ក៏ ADB ត្រូវការកសាងសមត្ថភាពនេះជាបន្តបន្ទាប់ ប្រសិនបើ ADB ចង់រក្សាបាននូវការពាក់ព័ន្ធ និងល្បឿនទាក់ទងទៅនឹងការផ្លាស់ប្តូរនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ កម្រិតបទពិសោធន៍វិជ្ជាជីវៈ និងអន្តរជាតិរបស់បុគ្គលិក ADB នឹងកំណត់នូវលទ្ធភាពរបស់ខ្លួនដើម្បីអនុវត្តយុទ្ធសាស្ត្រជាអាទិភាព និងបំពេញតម្រូវការរបស់អតិថិជនខ្លួនសម្រាប់ផលិតផល និងសេវាកម្មដ៏ទំនើប និងរស់រវើក។ ទិសដៅ និងទំហំនៃការផ្លាស់ប្តូរនៅក្នុងជំនាញចម្រុះ នឹងមានភាពខុសប្លែកគ្នាទៅតាមវិស័យឯកទេស ប៉ុន្តែការកសាងសមត្ថភាពសំខាន់ៗនឹងមានភាពចាំបាច់ណាស់សម្រាប់វិស័យមួយចំនួន។ ទោះជាផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលអាចនិយាយបានថា ជាវិស័យប្រតិបត្តិការស្នូលដ៏ខ្លាំងបំផុតរបស់ ADB ក៏ដោយ ក៏ ADB នឹងត្រូវការរៀបចំជំនាញបច្ចេកទេសហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់ខ្លួនឱ្យដល់ស្តង់ដារ ដែលអាចរក្សាបាននូវការគោរព ការជឿទុកចិត្តពីអតិថិជន និងការងារពាណិជ្ជកម្មសំខាន់ផ្សេងៗទៀតជាមួយវិស័យសាធារណៈ និងឯកជន។ ក្នុងសកម្មភាពដែលប្រតិបត្តិការរបស់ខ្លួនត្រូវបាន

កម្រិត ប៉ុន្តែ រំពឹងថា នឹងកើនឡើង (ឧទាហរណ៍ ដូចជា វិស័យបរិស្ថាន និងឯកជន) ADB ត្រូវតែបន្ថែមជំនាញថ្មីៗ ឬលើកកម្ពស់ជំនាញដែលចាំបាច់ដល់បុគ្គលិករបស់ខ្លួនជាប្រចាំ។ ក្នុងបរិបទនេះ ថ្នាក់ដឹកនាំនឹងពិចារណារកវិធីសាស្ត្រផ្សេងៗដើម្បីរៀបចំដាក់ពង្រាយ និងរក្សាទុកបុគ្គលិកបច្ចេកទេសរបស់ខ្លួននៅទីស្នាក់ការកណ្តាល និងទីស្នាក់ការផ្សេងៗទៀតទូទាំងតំបន់។ ការជ្រើសរើសបុគ្គលិកដែលប្រកបដោយភាពបត់បែនបន្ថែមទៀតត្រូវបានអនុវត្ត រួមទាំងការប្រើប្រាស់លក្ខខណ្ឌខុសៗគ្នា ការផ្សាយព័តិមានជ្រើសរើសទាំងក្នុងនិងក្រៅស្ថាប័នសំរាប់ជ្រើសរើសបុគ្គលិកទាំងអស់ រាប់ទាំង បុគ្គលិកជាន់ខ្ពស់ផងដែរ។ ជាងនេះទៅទៀត ដោយឈរលើលទ្ធផលស្ទាបស្ទង់មតិបុគ្គលិក ថ្នាក់ដឹកនាំនឹងចាត់វិធានការសមស្របដើម្បីបន្តការលើកទឹកចិត្តដល់បុគ្គលិករបស់បេសកកម្ម ADB និងប្រើប្រាស់ចំណេះដឹងបុគ្គលិក និងឆន្ទះរបស់ខ្លួនឱ្យល្អបំផុតសម្រាប់ការងារអភិវឌ្ឍ។ ដោយមានជំនួយពីអ្នកជំនាញការខាងក្រៅ ថ្នាក់ដឹកនាំនឹងធ្វើការពិនិត្យឡើងវិញអោយបានល្អិតល្អន់លើយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សរបស់ ADB នៅឆ្នាំ ២០០៨។

## ៣. ការកែលម្អរចនាសម្ព័ន្ធរបស់អង្គភាព

ក្នុងការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០ ថ្នាក់ដឹកនាំ នឹងពិចារណាលើការរៀបចំរចនាសម្ព័ន្ធដែលអាចជួយគាំទ្រឱ្យបានល្អបំផុតដល់ប្រទេសជាសមាជិកឱ្យប្រកបដោយឧត្តមភាពវិជ្ជាជីវៈ ការជំនះភាពទន់ខ្សោយផ្ទៃក្នុង និងការបង្កើនកម្លាំងក្នុងប្រតិបត្តិការរបស់ ADB។ ដើម្បីឆ្លើយតបទៅតាមតម្រូវការផ្សេងៗរបស់អតិថិជនឱ្យបានកាន់តែមានប្រសិទ្ធភាព និងដើម្បីប្រើប្រាស់ធនធានរបស់ខ្លួនឱ្យបានល្អបំផុត ថ្នាក់ដឹកនាំ នឹងអនុញ្ញាតឱ្យនាយកដ្ឋាននីមួយៗមានភាពបត់បែនក្នុងការកំណត់អំពីរចនាសម្ព័ន្ធនៃអង្គភាពរបស់ខ្លួន។ ថ្នាក់ដឹកនាំ នឹងត្រួតពិនិត្យមើលជម្រើសដ៏ល្អបំផុតដើម្បីដាក់ពង្រាយធនធានសម្រាប់ធ្វើការគាំទ្រការអភិវឌ្ឍវិស័យឯកជនដោយនាយកដ្ឋានគ្រប់គ្រងតំបន់ និងនាយកដ្ឋានប្រតិបត្តិការវិស័យឯកជន។ ការកើនឡើងនៃកម្ចីសម្រាប់វិស័យឯកជន នឹងតម្រូវឱ្យមានការលើកកម្ពស់សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ និងហានិភ័យរបស់ ADB ផងដែរ។ ជាងនេះទៅទៀត យុទ្ធសាស្ត្រដែលផ្តោតទៅលើបរិស្ថាន ជាពិសេស បម្រែបម្រួលអាកាសធាតុ នឹងទាមទារឱ្យថ្នាក់ដឹកនាំពិចារណាលើរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីបំពេញតម្រូវការដែលចេះតែកើនឡើងយ៉ាងឆាប់រហ័សលើសេវាកម្ម និងផលិតផលរបស់ ADB នៅក្នុងវិស័យនេះ។ ការផ្លាស់ប្តូរដទៃទៀតដែលអាចនឹងកើតឡើងក្នុងរយៈពេលវែង រាប់បញ្ចូល ទាំងការធ្វើវិមជ្ឈការរបស់អង្គភាពបន្ថែមទៀត បង្កើនសមត្ថភាពតាមនិវេសនដ្ឋាន និងរៀបចំការិយាល័យចំណេះដឹង ប្រសិនចាំបាច់។

## ៤. ការបង្កើនការឆ្លើយតបរួម

ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ អតិថិជនរបស់ ADB បានសំដែងនូវបំណងប្រាថ្នាសុំឱ្យមានការចំណាយទាបសម្រាប់ការរៀបចំ និងអនុវត្តគម្រោង មានការកាត់បន្ថយនូវតម្រូវការឯកសារ និងការធ្វើវិមជ្ឈការពីសេចក្តីសម្រេចដល់និវេសនដ្ឋានបេសកកម្ម។ ទោះបីជាថ្នាក់ដឹកនាំត្រូវការថ្លឹងថ្លែងនូវភាពឆ្លើយតប និងប្រសិទ្ធភាពនៃការចំណាយជាមួយនឹងតម្រូវការការងារចាំបាច់ផ្សេងៗ តម្រូវការច្បាប់ និងការអនុវត្តដ៏ល្អបំផុត យុទ្ធសាស្ត្រឆ្នាំ ២០២០ តម្រូវឱ្យ ADB រិះរកវិធីដែលឆ្លើយតប

បានល្អបំផុតទៅនឹងផលប្រយោជន៍របស់អ្នកខ្ចីហិរញ្ញវត្ថុរបស់ខ្លួន រួមទាំងការប្រើប្រាស់នូវយុទ្ធសាស្ត្រព័ត៌មាន និងបច្ចេកវិទ្យាទំនាក់ទំនងទំនើប និងការបង្កើតនូវបទដ្ឋាន (benchmark) ដើម្បីអង្កេតតាមដាន និងវាស់វែងចំពោះភាពឆ្លើយតបរបស់ខ្លួន។

## ការគ្រប់គ្រងលើការអនុវត្តយុទ្ធសាស្ត្រ ឆ្នាំ ២០២០ : ក្របខ័ណ្ឌលទ្ធផលរបស់ ADB

ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការសម្រេចបាននូវការអភិវឌ្ឍន៍ក្នុងតំបន់ ADB ត្រូវតែមានសមត្ថភាពអង្កេតតាមដាន និងវាយតម្លៃការងាររបស់ខ្លួនតាមវិធីដែលអាចវាស់វែងបាន ហើយចាត់វិធានការសមស្របដោយផ្អែកលើលទ្ធផល។ នេះមានន័យថា អាចមានលទ្ធភាពវាស់វែងទិន្នផល លទ្ធផល និងផលប៉ះពាល់របស់គម្រោង ប្រទេស និងស្ថាប័ន។ ចាប់តាំងពី ឆ្នាំ ២០០៤ មក ADB បានអង្កេតតាមដានលើកសកម្មភាពការងាររបស់ស្ថាប័នខ្លួនតាមរយៈការដាក់ចេញនូវក្របខ័ណ្ឌលទ្ធផលដែលរួមបញ្ចូលទាំងសូចនាករសកម្មភាពការងារ និងគោលដៅកំណត់មួយចំនួន (quantified targets) ទៅក្នុងរបាយការណ៍ និងឯកសារផែនការមេរួមរបស់ខ្លួន។ ក្នុងន័យនៃការផ្លាស់ប្តូររបស់យុទ្ធសាស្ត្រឆ្នាំ ២០២០ ឆ្ពោះទៅរករបាយការណ៍ស្អិតរមួត និងប្រសិទ្ធភាព ក៏ដូចជា ឆ្ពោះទៅរកការផ្តោតទៅលើយុទ្ធសាស្ត្រ និងគោលនយោបាយស្ថាប័នស្អិតរមួតផងដែរនោះ ADB បានបង្កើតរចនាសម្ព័ន្ធក្របខ័ណ្ឌលទ្ធផលកម្រិតរួមមួយ ដែលមានសូចនាករបបថ្មី ដើម្បីអង្កេតតាមដាន និងរាយការណ៍អំពីប្រសិទ្ធភាពទាំងមូលរបស់ខ្លួន (ឧបសម្ព័ន្ធទី ២)។ ក្របខ័ណ្ឌលទ្ធផលដែលបានកែតម្រូវ ព្រមជាមួយនឹងរង្វាស់ទិន្នន័យ និងគោលដៅ នឹងត្រូវបញ្ចូលទៅក្នុងការពិនិត្យឡើងវិញនូវប្រសិទ្ធភាពអភិវឌ្ឍន៍ (development effectiveness review) ដែលត្រូវធ្វើឡើងនៅត្រីមាសទីបី ឆ្នាំ ២០០៨។ ក្របខ័ណ្ឌលទ្ធផលនេះ នឹងតាមដានការរីកចម្រើននៅក្នុងលទ្ធផលអភិវឌ្ឍប្រមូលផ្តុំរយៈពេលវែង (long-term development outcomes) ព្រមទាំង នៅក្នុងសកម្មភាព និងទិន្នផលជាក់លាក់ពាក់ព័ន្ធទៅនឹងការសម្រេចបាននូវអាទិភាពយុទ្ធសាស្ត្ររបស់ ADB។ នៅពេលដែល ADB អនុវត្តយុទ្ធសាស្ត្រ ឆ្នាំ ២០២០ ក្របខ័ណ្ឌនេះ នឹងត្រូវមានការកែតម្រូវខ្លះ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូររបស់តំបន់ និងស្ថាប័ន។

ក្នុងលក្ខណៈនៃឧបករណ៍អង្កេតតាមដាន និងវាយតម្លៃដ៏ពេញលេញមួយ ក្របខ័ណ្ឌលទ្ធផលមានប្រភេទលទ្ធផលចំនួនបួនៈ (១) លទ្ធផលតំបន់ (២) ការរួមចំណែកដល់លទ្ធផលប្រទេស (contribution to country outcomes) (៣) ប្រសិទ្ធភាពនៃប្រតិបត្តិការ និង (៤) ប្រសិទ្ធភាពនៃការរៀបចំស្ថាប័ន ADB។

## ១. លទ្ធផលតំបន់

ប្រភេទទីមួយនៃក្របខ័ណ្ឌលទ្ធផលជួយឱ្យ ADB អាចអង្កេតតាមដានលើការរួមចំណែករបស់ខ្លួនចំពោះកម្មវិធីអភិវឌ្ឍន៍អន្តរជាតិរបស់សហគមន៍ទូទៅ។ ADB នឹងអង្កេតតាមដានលើការរីកចម្រើនតាមរយៈក្រុមនៃសូចនាករគោលដៅ-អភិវឌ្ឍន៍សហស្សវត្សរ៍ ដែលទាក់ទងទៅនឹងវិស័យប្រតិបត្តិការស្នូលរបស់ខ្លួន ពោលគឺ សូចនាករដែលវាយតម្លៃវង្វាស់នៃភាពក្រីក្រលើប្រាក់ចំណូល និងមិនប្រាក់ចំណូល និងសូចនាករដែលវាយតម្លៃលើកំណើនហេដ្ឋារចនាសម្ព័ន្ធ និងបរិយាកាសពាណិជ្ជកម្ម។ ប្រសិនបើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាំងនេះ អាចសម្រេចបាន ឬស្ថិតនៅក្នុងការតាមដានត្រឹមឆ្នាំ ២០១៥ នោះជំនួយរបស់ ADB ដែលទាក់ទងទៅនឹងវិស័យស្នូលផ្សេងៗទៀតរបស់ខ្លួន អាចត្រូវបានកែតម្រូវ ដើម្បីគាំទ្រដល់ការរីកចម្រើននៃវិស័យផ្សេងៗទៀត។

## ២. ការចូលរួមចំណែកចំពោះលទ្ធផលប្រទេស : ទិន្នផលគន្លឹះ

ប្រភេទទីពីរនៃក្របខ័ណ្ឌលទ្ធផល ប្រមូលផ្តុំនូវការរួមចំណែកជាក់ស្តែងពីសកម្មភាពផ្សេងៗនៃជំនួយរបស់ ADB ចំពោះលទ្ធផលប្រទេសជាក់លាក់។ ADB នឹងត្រួតពិនិត្យមើលសូចនាករទិន្នផលនៃវិស័យចំនួនប្រាំគឺ ការដឹកជញ្ជូន ថាមពល ទឹក ហិរញ្ញវត្ថុ និងការអប់រំ ដើម្បីសម្រួលដល់ការអង្កេតតាមដានវិស័យប្រតិបត្តិការស្នូលផ្សេងៗទៀតក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០។ លទ្ធផលសម្រាប់អ្នកទទួលផល (outcomes for beneficiaries) នឹងបំបែកទៅតាមផ្នែក ដូចជា ជនបទ ទីប្រជុំជន និងតំបន់នានា ដើម្បីធ្វើការតាមដានលទ្ធផលអនុផ្នែកគន្លឹះផ្សេងៗទៀត ដូចជា ការសាងសង់ទីក្រុងដែលអាចរស់នៅបាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ និងការតភ្ជាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។

## ៣. ប្រសិទ្ធភាពនៃប្រតិបត្តិការ

ប្រភេទទីបីនៃក្របខ័ណ្ឌលទ្ធផល គឺវាស់វែងប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ ADB ដែលរួមមាន សំណុំបទដ្ឋាននៃវិធានការ (a standard set of measures) ដែលត្រូវដាក់ឱ្យអនុវត្តទូទាំងធនាគារអភិវឌ្ឍន៍ពហុភាគី។ ADB នឹងអង្កេតតាមដានប្រសិទ្ធភាពនៃការរីកចម្រើនលើប្រតិបត្តិការរបស់ខ្លួន តាមរយៈក្រុមសូចនាករបួនគឺៈ គុណភាពប្រតិបត្តិ និងសកម្មភាពការងារផលប័ត្រ (operational quality and portfolio performance) ការកៀងគរហិរញ្ញវត្ថុ ការអភិវឌ្ឍចំណេះដឹង និងភាពជាដៃគូ។

## ៤. ប្រសិទ្ធភាពនៃការរៀបចំរចនាសម្ព័ន្ធស្ថាប័ន

ប្រភេទទីបួននៃក្របខ័ណ្ឌលទ្ធផល គឺផ្ដោតលើការរីកចម្រើនក្នុងការអនុវត្តកំណែទម្រង់ផ្ទៃក្នុង ដែលនឹងធានានូវកិត្តិនាមរបស់ ADB ដែលជាស្ថាប័នពាក់ព័ន្ធមួយ និងផ្ដោតលើលទ្ធផលជាចម្បង។ ក្របខ័ណ្ឌនេះ មានបីផ្នែកគឺ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងដំណើរការ និងការអនុវត្តពាណិជ្ជកម្ម (business processes and practices)[៣១]។

## ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផល

ថ្នាក់ដឹកនាំ នឹងប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលដើម្បីត្រួតពិនិត្យសូចនាករជាក់លាក់ ប៉ុន្តែមានវិសាលភាពទូលំទូលាយដែលស្របទៅតាមទិសដៅ និងទស្សនវិស័យរបស់យុទ្ធសាស្ត្រ ឆ្នាំ ២០២០ ដើម្បីអង្កេតតាមដានការរីកចម្រើន វាស់វែងលទ្ធផល និងចាត់វិធានការកែតម្រូវក្នុងករណីចាំបាច់។ ភាពញឹកញាប់ និងភាពទៀងពេលនៃការរាយការណ៍ នឹងត្រូវពិចារណាយ៉ាងប្រុងប្រយ័ត្នសម្រាប់សូចនាករនីមួយៗ ហើយនឹងត្រូវកំណត់ដោយផ្អែកលើសារៈប្រយោជន៍ដែលរំពឹងទុក ភាពជាប់ពាក់ព័ន្ធល្បឿននៃការផ្លាស់ប្ដូររបស់វា និងការវាយតម្លៃលើផលប្រយោជន៍ និងការចំណាយ លើការទទួលបានព័ត៌មានសម្រាប់ស្ថាប័ន។

ADB នឹងធ្វើការវាយតម្លៃ និងរាយការណ៍អំពីការរីកចម្រើនក្នុងការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០ តាមរយៈរបាយការណ៍ត្រួតពិនិត្យឡើងវិញលើប្រសិទ្ធភាពអភិវឌ្ឍប្រចាំឆ្នាំរបស់ខ្លួន ដោយចាប់ផ្ដើមពីការពិនិត្យឡើងវិញនៅឆ្នាំ ២០០៨ ដែលត្រូវចេញផ្សាយនៅត្រីមាសទីបី ឆ្នាំ ២០០៩ ក្រោមការណែនាំដោយក្របខ័ណ្ឌលទ្ធផល។ ការត្រួតពិនិត្យឡើងវិញ នឹងក្លាយជារបាយការណ៍សកម្មភាពការងាររួមមួយរបស់ ADB ដោយដាក់បញ្ចូលទាំងរបាយការណ៍ដែលមានស្រាប់ស្ដីពីការកាត់បន្ថយភាពក្រីក្រប្រចាំឆ្នាំ របាយការណ៍រីកចម្រើននៃការអនុវត្តកម្មវិធីកំណែទម្រង់ និងរបាយការណ៍រីកចម្រើនឆមាសស្ដីពីការគ្រប់គ្រងសម្រាប់ផែនការសកម្មភាព និងលទ្ធផលអភិវឌ្ឍ។ ការត្រួតពិនិត្យឡើងវិញ នឹងក្លាយជាឧបករណ៍ដ៏សំខាន់មួយក្នុងការផ្ដល់ព័ត៌មានដល់ថ្នាក់ដឹកនាំស្ដីអំពីការរីកចម្រើនដែលបានទទួល និងបង្ហាញពីវិស័យផ្សេងៗទៀតដែលទាមទារឱ្យមានការខិតខំប្រឹងប្រែង ឬកែតម្រូវជាបន្ថែមទៀត។

---

[៣១] សូចនាករសម្រាប់កម្រិតនេះ គឺជារង្វាស់ស្ដង់ដារចំនួន ដែលជាធម្មតាទាមទារឱ្យមានការអង្កេតតាមដានក្នុងរយៈពេលវែង។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់គោលបំណងរបស់យុទ្ធសាស្ត្រឆ្នាំ ២០២០ ការរីកចម្រើននៃកំណែទម្រង់ផ្ទៃក្នុង នឹងអាចសម្រេចបានល្អបំផុតតាមរយៈមធ្យោបាយផ្សេងៗ ដូចជាសូចនាករដំណើរការ និងការវាយតម្លៃគុណភាព។ ដូច្នេះហើយ ទោះបីជារបាយការណ៍ផ្អែកលើសកម្មភាព នឹងត្រូវបានប្រើប្រាស់ជាចម្បង ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ ADB ក៏ដោយ ក៏របាយការណ៍នេះ នឹងភ្ជាប់ដោយផ្ទាល់ផងដែរ ទៅនឹងប្រសិទ្ធភាពនៃស្ថាប័នខ្លួន។ ជាងនេះទៅទៀត សម្រាប់សូចនាករកម្រិតនេះ ទិសដៅ និងគោលដៅ នឹងឆ្លុះបញ្ចាំងនូវការផ្លាស់ប្ដូរជាបន្តបន្ទាប់នៅក្នុងគំរូបរិយាកាស និងពាណិជ្ជកម្មរបស់តំបន់ ដែលត្រូវបានរំពឹងទុកដល់ឆ្នាំ ២០២០។ ឧទាហរណ៍ កម្រិតគួរជាទីពេញចិត្តនៃវិមជ្ឈការ និងតុល្យការដ៏ប្រសើរបំផុតរបស់បុគ្គលិកនៅក្នុងវិស័យប្រតិបត្តិ និងមិនមែនប្រតិបត្តិ ទំនងជាមានការផ្លាស់ប្ដូរដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍរបស់តំបន់។ ជាលទ្ធផល កម្រិតនៃក្របខ័ណ្ឌនេះ នឹងមានភាពរលូនបន្ថែមទៀត និងតម្រូវឱ្យមានការត្រួតពិនិត្យឡើងវិញតាមពេលវេលាកំណត់។

**ជំហានបន្ទាប់**

ថ្នាក់ដឹកនាំ នឹងចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០ ភ្លាមបន្ទាប់ពីទទួលបានការអនុម័តមពីក្រុមប្រឹក្សាភិបាល។ នាយកដ្ឋាន និងការិយាល័យរបស់ ADB ទាំងអស់ នឹងត្រួតពិនិត្យផលប៉ះពាល់នៃយុទ្ធសាស្ត្រឆ្នាំ ២០២០ ទៅលើកម្មវិធីការងាររយៈពេលខ្លី និងមធ្យមរបស់ពួកគេ ព្រមទាំងតម្រូវការធនធាន ហើយដាក់ស្នើផែនការសកម្មភាពទៅអនុប្រធានរបស់ពួកគេរៀងៗខ្លួន សម្រាប់ការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០ នៃដំណាក់កាលដំបូង។

ក្រោយពីការអនុម័តយុទ្ធសាស្ត្រឆ្នាំ ២០២០ ភ្លាម ADB នឹងផ្សព្វផ្សាយយុទ្ធសាស្ត្រនេះឱ្យបានទូលំទូលាយ។ ADB នឹងផ្សព្វផ្សាយទិសដៅយុទ្ធសាស្ត្រថ្មីរយៈពេលវែងរបស់ខ្លួនដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ និងវិស័យឯកជន ដើម្បីទទួលបានការយល់ដឹង និងការគាំទ្រឱ្យបានទូលំទូលាយ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រដំបូង រួមទាំង ដៃគូភាពផង។

ជាងនេះទៅទៀត ទិន្នន័យប្រតិបត្តិការទូលំទូលាយ (wide operational database) របស់ ADB នឹងដាក់ឱ្យប្រើប្រាស់ស្របគ្នាជាមួយយុទ្ធសាស្ត្រឆ្នាំ ២០២០ ត្រឹមខែធ្នូ ឆ្នាំ ២០០៨។ ដោយបានរៀបចំដើម្បីដោះស្រាយភាពទន់ខ្សោយនៃទិន្នន័យបច្ចុប្បន្ន ដែលបានបង្ហាញនៅក្នុងរបាយការណ៍របស់នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ ទិន្នន័យថ្មីនឹងជួយតាមដានការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០២០ ទល់នឹងក្របខ័ណ្ឌលទ្ធផល ដែលអនុញ្ញាតឱ្យមានការកែសម្រួលនៅដំណាក់កាលដំបូង។

## VI. ការផ្តល់ធនធានសម្រាប់ដំណើរការយុទ្ធសាស្ត្រ

បញ្ហាប្រឈមក្នុងតំបន់ នឹងទាមទារឱ្យមានការវិនិយោគមូលធនយ៉ាងច្រើន។ ដោយផ្អែកលើការសិក្សាផ្ទៃក្នុងរបស់ ADB មួយ គេត្រូវការទឹកប្រាក់ចំនួន ៤,៧00 (4.7 trillion) ពាន់លានដុល្លា សម្រាប់រយៈពេល ១០ ឆ្នាំខាងមុខ ដើម្បីបំពេញសេចក្តីត្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធរបស់តំបន់។ តួលេខនេះមាន ៣,១00 (3.1 trillion) ពាន់លានដុល្លា សម្រាប់ការសាងសមត្ថភាពថ្មី និងតុល្យការសម្រាប់ជំនួសសមត្ថភាព។ តម្រូវការវិនិយោគប្រចាំឆ្នាំដែលបានប៉ាន់ស្មានសម្រាប់បញ្ហាបរិស្ថានមានរហូតដល់ ១00 ពាន់លានដុល្លា ក្នុងនោះ រួមមាន ៣0 ពាន់លានដុល្លា សម្រាប់ថាមពលកកើតឡើងវិញ ២៨ ពាន់លានដុល្លា សម្រាប់ការផ្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ ១៤ ពាន់លានដុល្លា សម្រាប់ប្រសិទ្ធផលថាមពល និង ៨ ពាន់លានដុល្លា សម្រាប់ការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព។ តម្រូវការអភិវឌ្ឍវិស័យហិរញ្ញវត្ថុសម្រាប់តំបន់ ក៏ហាក់ដូចជាមានទំហំធំផងដែរ ដោយទឹកប្រាក់ប៉ាន់ស្មានក្នុងការវិនិយោគមានប្រហែល ១៩៧ ពាន់លានដុល្លា សម្រាប់ផ្តល់មូលធនទៅឱ្យធនាគាររហូតដល់ឆ្នាំ ២០២០ សម្រាប់តែតំបន់អាស៊ីខាងត្បូងតែប៉ុណ្ណោះ[៣២]។ សម្រាប់វិស័យអប់រំ កង្វះខាតនៃហិរញ្ញប្បទានដែលត្រូវការសម្រាប់សម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍លើការអប់រំបឋមសិក្សាទូទៅ ត្រឹមឆ្នាំ ២០១៥ ត្រូវបានប៉ាន់ប្រមាណដល់ ៧ ពាន់លានដុល្លា ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២00១ ដល់ ២០១៥។

យុទ្ធសាស្ត្រឆ្នាំ ២០២០ ជម្រុញឱ្យ ADB ដើរតួជាដៃគូអភិវឌ្ឍន៍ឈានមុខ។ បន្ថែមពីលើចំណេះដឹង និងជំនាញរបស់ខ្លួន ADB ត្រូវមានធនធានចាំបាច់ដែលមានលក្ខណៈជាសម្បទាន និងមិនសម្បទាន ដើម្បីទទួលខុសត្រូវលើតួនាទីឈានមុខនេះ និងទទួលខុសត្រូវលើលើហានិភ័យរបស់ ADB។ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB ត្រូវតែធានាថា ខ្លួនតែងតែមានមធ្យោបាយខាងហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ។

និន្នាការថ្មីៗនៅក្នុងកម្ចីជាសម្បទាន និងជំនួយឥតសំណងរបស់ ADB បង្ហាញពីតម្រូវការដ៏ខ្លាំងក្លារបស់ប្រទេស DMCs ដើម្បីទទួលបាននូវធនធានមូលនិធិអភិវឌ្ឍន៍អាស៊ី (ADF)។ លទ្ធភាពរបស់ ADB ក្នុងការជួយ និងគាំទ្រដល់ដំណើរការអភិវឌ្ឍន៍គោលដៅអភិវឌ្ឍន៍សហវត្សរ៍ក្នុងអ្នកខ្ចី ADF គឺពឹងផ្អែកទៅលើធនធានសម្បទានដែលអាចវាស់វែងគ្នាបានជាមួយនឹងតួនាទីអភិវឌ្ឍន៍របស់ខ្លួននៅក្នុងប្រទេស DMCs ទាំងនេះ។ ការប៉ាន់ស្មានជាបឋមរបស់ ADB បង្ហាញថា គំលាតហិរញ្ញវត្ថុដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍នៅក្នុងប្រទេស ADF ទាំង ២៩ របស់ខ្លួន អាចមានទឹកប្រាក់ដល់ទៅ ១00 ពាន់លានដុល្លា សម្រាប់រយៈពេល ADF X ចាប់ពីឆ្នាំ ២00៩ ដល់ ២០១២។ ការធ្វើចំណោលរយៈពេលវែងរបស់ ADB លើកំណើនប្រាក់ចំណូលមនុស្សម្នាក់ៗក្នុងអ្នកមានសិទ្ធខ្ចី ADF បច្ចុប្បន្ន បង្ហាញថា អ្នកខ្ចីជាច្រើន នឹងនៅតែស្ថិតក្រោម

---

[៣២] ការប៉ាន់ប្រមាណ បានសន្មត់មូលធនគ្រប់គ្រាន់សំរាប់ហានិភ័យ (risk-based capital adequacy) នៃកំណើន ១0% ក្នុងមួយឆ្នាំ។ នៅក្នុងទ្រព្យសកម្មធនាគារ និងការធ្លាក់ចុះជាលំដាប់នៅក្នុងអនុបាតនៃកម្ចីសម្រាប់ទ្រព្យសកម្មដែលមិនប្រតិបត្តិ (nonperforming loan-asset ration)។

លក្ខខណ្ឌក្នុងការទទួលបានសិទ្ធិជាអ្នកខ្ចីរបស់ ADF តែមួយ ឬ ចម្រុះ[៣៣] រហូតដល់ ឆ្នាំ ២០២០។ ដូច្នេះ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB នឹងស្វែងរកការគាំទ្របន្ថែមទៀតពីសមាជិកម្ចាស់ជំនួយរបស់ខ្លួន ដើម្បីពង្រឹងសមត្ថភាពហិរញ្ញវត្ថុរបស់ ADF ។

ការធ្វើផែនការប្រតិបត្តិយុទ្ធសាស្ត្រ និងកិច្ចពិភាក្សាគោលនយោបាយជាមួយអ្នកខ្ចីធនធានមូលធនសាមញ្ញ (OCR) របស់ ADB (ទាំងអ្នកខ្ចី OCR តែមួយ ឬ ចម្រុះ) បានស្នើសុំនូវតម្រូវការកាន់តែខ្លាំងបន្ថែមទៀតសំរាប់ជំនួយមិនមែនលក្ខណៈជាសម្បទានដែលលើសពីកំរិតនៃប្រតិបត្តិការបច្ចុប្បន្ន។ នេះជាករណីពិសេសសម្រាប់អ្នកខ្ចីចម្រុះបច្ចុប្បន្ន ដែលកំណើនសេដ្ឋកិច្ច និងការពង្រឹងស្ថាប័ន កំពុងតែពង្រីកសមត្ថភាពរបស់ពួកគេ ដើម្បីប្រើប្រាស់ជំនួយមិនមានលក្ខណៈជាសម្បទានរបស់ ADB ក្នុងការលើកកំពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម និងក្នុងការដោះស្រាយបញ្ហាបរិស្ថានរបស់ពួកគេ។ ការធ្វើចំណោលចំពោះកំណើនប្រាក់ចំណូលមនុស្សម្នាក់ៗនៅក្នុងប្រទេស DMCs បង្ហាញថា អ្នកខ្ចី OCR បច្ចុប្បន្នជាច្រើននឹងនៅតែស្ថិតក្រោមលក្ខខណ្ឌឆ្លងផុត (graduation threshold) រហូតដល់ឆ្នាំ ២០២០[៣៤] ។

ការប៉ាន់ស្មាននាពេលបច្ចុប្បន្នអំពីលទ្ធភាពផ្តល់ប្រាក់កម្ចីរបស់ OCR ទៅអនាគត នឹងមិនអាចឱ្យ ADB ទ្រទ្រង់កំរិតបច្ចុប្បន្ននៃប្រតិបត្តិការ OCR បានទេ ហើយរិតតែមិនអាចឱ្យ ADB បង្កើនជំនួយដើម្បីបញ្ចប់ភាពក្រីក្រ និងបន្តអនុវត្តកម្មវិធីយុទ្ធសាស្ត្រទាំងបីបានឡើយ។ ដំណើរការសម្រាប់កិច្ចផ្តួចផ្តើម និងការបង្កើតកិច្ចព្រមព្រៀងមួយនៅដំណាក់កាលដំបូងនៃយុទ្ធសាស្ត្រឆ្នាំ ២០២០ ដែលនឹងគាំទ្រដល់ការពង្រឹងតួនាទីក្នុងការអភិវឌ្ឍន៍ និងផ្តល់ហិរញ្ញប្បទានរបស់ ADB នៅក្នុងតំបន់ ត្រូវការជាចាំបាច់ក្នុងខណៈពេលដែលលទ្ធភាពផ្តល់ប្រាក់កម្ចីហួសពីវិសាលភាពនៃយុទ្ធសាស្ត្រឆ្នាំ ២០២០ ដើម្បីកំណត់នូវកម្រិតដែលល្អបំផុត និងប្រភពផ្តល់ធនធានសម្រាប់ ADB រហូតដល់ឆ្នាំ ២០២០។

---

[៣៣] អ្នកខ្ចី" ទាំងពីរ" សំដៅទៅលើប្រទេស DMCs ដែលទទួលប្រាក់កម្ចីពី ADF ផង និងពី OCR ផង។

[៣៤] បទពិសោធន៍បង្ហាញថា អ្នកខ្ចីរបស់ OCR តែមួយ អាចសម្រេចចិត្តបន្ថយ និងបញ្ឈប់កម្ចីពី ADB មុនពេលដល់លក្ខខណ្ឌឆ្លងផុត។

# VII. សេចក្តីសន្និដ្ឋាន

តំបន់អាស៊ី-ប៉ាស៊ីហ្វិក កំពុងតែមានការរីកចម្រើនយ៉ាងឆាប់រហ័ស ប៉ុន្តែទន្ទឹមនឹងនេះ ក៏មានការព្រួយបារម្ភពាក់ពន្ធ័នឹងការរួមបញ្ចូលគ្នារបស់ខ្លួន ផលប៉ះពាល់លើបរិស្ថាន និងនិរន្តរភាព ដែលតម្រូវឱ្យមានយុទ្ធវិធីអភិវឌ្ឍន៍ថ្មីមួយ គំនិតច្នៃប្រឌិត និងសកម្មភាពប្រកបដោយកិច្ចសហប្រតិបត្តិការ។

ដោយទទួលស្គាល់ពីតម្រូវការផ្លាស់ប្តូរ ទើបយុទ្ធសាស្ត្រឆ្នាំ ២០២០ តម្រូវឱ្យ ADB រៀបចំមុខងាររបស់ខ្លួនឡើងវិញនៅក្នុងក្របខ័ណ្ឌនៃការវិវត្តនូវរចនាសម្ព័ន្ធជំនួយអន្តរជាតិ កំណត់នូវការយកចិត្តទុកដាក់លើប្រតិបត្តិការ និងបង្កើតគោលដៅប្រតិបត្តិយុទ្ធសាស្ត្រ និងស្ថាប័ន។ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ និងរួមជាមួយលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ និងធនធានស្ថាប័នដែលចាំបាច់ផ្សេងៗទៀត ADB នឹងព្យាយាមសម្រេចឱ្យបាននូវឧត្តមភាពក្នុងការវិនិយោគ និងជំនួយ ដោយផ្អែកលើមូលដ្ឋានចំណេះដឹងរបស់ខ្លួន ដើម្បីបែងចែកជំនួយឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលឱ្យកាន់តែធំធេងបន្ថែមទៀត។ យុទ្ធសាស្ត្រឆ្នាំ ២០២០ នឹងជួយ ADB ឱ្យសម្រេចបាននូវសក្តានុពលពេញលេញរបស់ខ្លួនក្នុងការផ្តល់ផលប្រយោជន៍ដល់តំបន់ និងសហគមន៍អន្តរជាតិ។

# តួលេខគ្រួសៗនៃការអភិវឌ្ឍន៍នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក

## តារាង ក ១.១ : ផលិតផលក្នុងស្រុកសរុប

| សូចនាករ | អាស៊ីខាងលិច និងកណ្ដាល | អាស៊ីខាងកើត | អាស៊ីខាងត្បូង | អាស៊ីអាគ្នេយ៍ | តំបន់ប៉ាស៊ីហ្វិក | ពិភពលោក |
|---|---|---|---|---|---|---|
| GDP (តម្លៃថេរឆ្នាំ ២000 គិតជាពាន់លានដុល្លា) | | | | | | |
| ២000 | ១១៨,0 | ១.៨៧៩,៨ | ៥៣0,២ | ៥៨៣,៣ | ៦,៨ | ៣១.៨00,៣ |
| ចំណែកជា % | 0,៤ | ៥,៩ | ១,៧ | ១,៨ | 0,0 | ១00,0 |
| ២00៦ | ១៧៦,៧ | ២.៩៨៧,៦ | ៧៩៨,២ | ៧៨១,៦ | ៧,៧ | ៣៧.៨៦៦,៤ |
| ចំណែកជា % | 0,៥ | ៧,៩ | ២,១ | ២,១ | 0,0 | ១00,0 |
| GDP ម្នាក់ៗ (តម្លៃថេរឆ្នាំ ២000 ជាដុល្លា) | | | | | | |
| ២000 | ៥៧៦,៧ | ១.៤២៩,៥ | ៤៤៥,៧ | ១.១៣៥,២ | ៨៤៧,៦ | ៥.២៤២,៩ |
| ២00៦ | ៧៧២,៨ | ២.១៨១,១ | ៦១២,៨ | ១.៤0១,៥ | ៨៤២,៥ | ៥.៨0៩,៩ |
| ការនាំទំនិញចេញ (តម្លៃបច្ចុប្បន្ន ពាន់លានដុល្លា) | | | | | | |
| ២000 | ២៧,0 | ៦២៤,៧ | ៥៥,២ | ៤៣២,0 | ២,៨ | ៦.៤៥៤,៦ |
| ចំណែកជា % | 0,៤ | ៩,៧ | 0,៩ | ៦,៧ | 0,0 | ១00,0 |
| ២00៦ | ៧៦,0 | ១.៦១៨,៩ | ១៤0,៤ | ៧៧0,៦ | ៥,២ | ១២.0៦៣,៥ |
| ចំណែកជា % | 0,៦ | ១៣,៤ | ១,២ | ៦,៤ | 0,0 | ១00,0 |

ប្រភព : ធនាគារពិភពលោក សូចនាករអភិវឌ្ឍន៍ពិភពលោក *online* (ដកស្រង់ ថ្ងៃទី ២៨ កុម្ភៈ ឆ្នាំ ២00៨) ។

## តារាង ក ១.២: ភាពក្រីក្រ

| | ១៩៩០ | | ២០០៤ | | ២០១៥ | |
|---|---|---|---|---|---|---|
| សូចនាករ | លាន | % | លាន | % | លាន | % |
| **ចំណែកនៃអនុតំបន់ ចំពោះប្រជាជនដែលរស់នៅដោយប្រាក់ចំណូលតិចជាង ១ ដុល្លា ក្នុងមួយថ្ងៃ** | | | | | | |
| អាស៊ីខាងកើត និងប៉ាស៊ីហ្វិក | ៤៧៦ | ៣៨,២ | ១៦៩ | ១៧,៥ | ៤០ | ៦,៤ |
| អាស៊ីខាងត្បូង | ៤៧៩ | ៣៨,៤ | ៤៤៦ | ៤៦,១ | ២៥៦ | ៤១,០ |
| អឺរ៉ុប និងអាស៊ីកណ្ដាល | ២ | ០,២ | ៤ | ០,៤ | ២ | ០,៣ |
| មជ្ឈិមបូពា៌ និងអាហ្វ្រិកខាងជើង | ៥ | ០,៤ | ៤ | ០,៤ | ២ | ០,៣ |
| អាមេរិកឡាទីន និងការីបីន | ៤៥ | ៣,៦ | ៤៧ | ៤,៩ | ៣៤ | ៥,៤ |
| អាហ្វ្រិកអនុតំបន់សាហារ៉ា | ២៤០ | ១៩,២ | ២៩៨ | ៣០,៨ | ២៩០ | ៤៦,៥ |
| **សរុប** | **១.២៤៧** | **១០០,០** | **៩៦៨** | **១០០,០** | **៦២៤** | **១០០,០** |
| **ចំណែកនៃអនុតំបន់ ចំពោះប្រជាជនដែលរស់នៅដោយប្រាក់ចំណូលតិចជាង ២ ដុល្លា ក្នុងមួយថ្ងៃ** | | | | | | |
| អាស៊ីខាងកើត-ប៉ាស៊ីហ្វិក | ១.១១៣ | ៤២,០ | ៦៨៤ | ២៦,៨ | ២៩៦ | ១៤,៧ |
| អាស៊ីខាងត្បូង | ៩៥៤ | ៣៦,០ | ១.១១៦ | ៤៣,៨ | ៩៩៧ | ៤៩,៥ |
| អឺរ៉ុប និងអាស៊ីកណ្ដាល | ២០ | ០,៨ | ៤៦ | ១,៨ | ១៦ | ០,៨ |
| មជ្ឈិមបូពា៌ និងអាហ្វ្រិកខាងជើង | ៤៩ | ១,៩ | ៥៩ | ២,៣ | ៣៨ | ១,៩ |
| អាមេរិកឡាទីន និងការីបីន | ១១៥ | ៤,៣ | ១២១ | ៤,៧ | ១០២ | ៥,១ |
| អាហ្វ្រិកអនុតំបន់សាហារ៉ា | ៣៩៦ | ១៥,០ | ៥២២ | ២០,៥ | ៥៦៧ | ២៨,១ |
| **សរុប** | **២.៦៤៧** | **១០០,០** | **២.៥៤៨** | **១០០,០** | **២.០១៦** | **១០០,០** |

ប្រភព: ធនាគារពិភពលោក ២០០៨ *ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ២០០៨* វ៉ាស៊ីនតោន DC ។

# តារាង ក ១.៣ : ប្រាក់បម្រុងបរទេស និងបំណុលសរុប (បំណាច់ឆ្នាំ)

| សូចនាករ | អាស៊ីកណ្តាល និងខាងលិច | អាស៊ីខាងកើត[ក] | អាស៊ីខាងត្បូង | អាស៊ីអាគ្នេយ៍ | តំបន់ប៉ាស៊ីហ្វិក |
|---|---|---|---|---|---|
| ប្រាក់បម្រុងបរទេស (លានដុល្លា) ២០០៦ | ៤៨.៩៥២,០ | ១.៧២៤.៣៨៦,០ | ១៨៥.២៧៧,០ | ៣៦៨.៧៨៤,០ | ១.៨៣៤,០ |
| បំណុលបរទេសសរុប (លានដុល្លា) ២០០៥ | ៩១.០៥៣,០ | ៥៥៧.៩៤១,០ | ១៥៧.៦៨១,០ | ៦៣៥.៥៧១,០ | ៣.២៥៣,០ |
| បំណុលសរុបដែលបានសង (លានដុល្លា) ២០០៥ | ១៧.៤៨៦,០ | ២៧.៤០៧,០ | ២៥.៧២៦,០ | ៥៨.០៤៥,០ | ៤៥៧,០ |
| បំណុលបរទេសសរុប/ GNI (%) ២០០៥ | ៤៣,៥ | ១២,៥ | ១៧,៦ | ៤៣,៧ | ៣៦,៦ |
| បំណុលបរទេសសរុប/ការនាំចេញ (%) ២០០៥ | ១២៨,៣ | ៣២,០ | ៥៦៤,៧ | ៦៣,៨ | ៧៩,៣ |

[ក] សម្រាប់ទិន្នន័យស្តីអំពីបំណុលបរទេសសរុប/GNI (%) និងបំណុលបរទេសសរុប/ការនាំចេញ (%) អាស៊ីខាងកើត រួមបញ្ចូលតែសាធារណរដ្ឋប្រជាមានិតចិន និងម៉ុងហ្គោលី ។

ប្រភព: ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៧: *សូចនាករគន្លឹះ ២០០៧* ម៉ានីល។ ធនាគារពិភពលោក: ហិរញ្ញវត្ថុអភិវឌ្ឍន៍សកល (ដកស្រង់ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៨) ។

## តារាង ក ១.៤: ថាមពល និងបរិស្ថាន

| សូចនាករ | ២០០០/២០០១ | ២០០៥ | អត្រាកំណើន ២០០០-២០០៥ (%) | ២០១៥ | អត្រាកំណើន ២០០៥-២០១៥ (%) | ២០៣០ | អត្រាកំណើន ២០១៥-២០៣០ (%) |
|---|---|---|---|---|---|---|---|
| **តម្រូវការចរន្តអគ្គិសនី** (TWh) | | | | | | | |
| អាស៊ី | ២.០២៥,០ | ៣.២៧៧,០ | ១០,១ | ៦.៦៦៥,០ | ៧,៤ | ១១.១៣១,០ | ៣,៥ |
| (%) | ១៦,១ | ២១,៨ | | ៣១,៣ | | ៣៧,៤ | |
| ពិភពលោក | ១២.៦០៩,០ | ១៥.០១៦,០ | ៣,៦ | ២១.២៧៨,០ | ៣,៥ | ២៩.៧៣៧,០ | ២,៣ |
| (%) | ១០០,០ | ១០០,០ | | ១០០,០ | | ១០០,០ | |
| **ការផ្គត់ចរន្តអគ្គិសនី** (TWh) | | | | | | | |
| អាស៊ី | ២.៦០៧,០ | ៤.១៤៣,០ | ៩,៧ | ៨.២៣៣,០ | ៧,១ | ១៣.៤៨០,០ | ៣,៣ |
| (%) | ១៦,៩ | ២២,៨ | | ៣២,២ | | ៣៨,១ | |
| ពិភពលោក | ១៥.៣៩១,០ | ១៨.១៩៧,០ | ៣,៤ | ២៥.៥៥៦,០ | ៣,៥ | ៣៥.៣៨៤,០ | ២,២ |
| (%) | ១០០,០ | ១០០,០ | | ១០០,០ | | ១០០,០ | |
| **ការបញ្ចេញឧស្ម័នកាបូនិច** (MT) | | | | | | | |
| អាស៊ី | ៥.២៩២,០ | ៧.៦៩០,០ | ៧,៨ | ១២.៤៤០,០ | ៤,៩ | ១៧.៤៦៤,០ | ២,៣ |
| (%) | ២២,៣ | ២៨,៣ | | ៣៦,៥ | | ៤១,៧ | |
| ពិភពលោក | ២៣.៦៨៣,៣ | ២៦.៦២០,០ | ២,៤ | ៣៤.០៧១,០ | ២,៥ | ៤១.៩០៥,០ | ១,៤ |
| (%) | ១០០,០ | ១០០,០ | | ១០០,០ | | ១០០,០ | |

ប្រភព : ទីភ្នាក់ងារថាមពលអន្តរជាតិ ឆ្នាំ២០០២ និង ២០០៧។ *ទស្សនវិស័យថាមពលពិភពលោក* ប៉ារីស ។

TWh = តេរ៉ាវ៉ាត់-ម៉ោង

ឧបសម្ព័ន្ធ ២

# រចនាសម្ព័ន្ធនៃក្របខ័ណ្ឌលទ្ធផលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី [ក]

| សូចនាករ |
|---|
| **កម្រិតទី ១: លទ្ធផលក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក**<br>គោលដៅអភិវឌ្ឍន៍សហវត្សរ៍<br>ផលិតផលក្នុងស្រុកសរុប ហេដ្ឋារចនាសម្ព័ន្ធ បរិយាកាសពាណិជ្ជកម្ម អភិបាលកិច្ច និងពាណិជ្ជកម្ម |
| **កម្រិតទី ២ :ការរួមចំណែកចំពោះលទ្ធផលរបស់ប្រទេស: ទិន្នផលគន្លឹះ**<br>ការដឹកជញ្ជូន<br>ថាមពល<br>ទឹក<br>ការអប់រំ ( គ្រប់កម្រិត)<br>ហិរញ្ញវត្ថុ |
| **កម្រិតទី ៣ :ប្រសិទ្ធភាពនៃប្រតិបត្តិការ**<br>គុណភាពប្រតិបត្តិការ និងសកម្មភាពផលប័ត្រ<br>ការកៀងគរហិរញ្ញវត្ថុ<br>ការអភិវឌ្ឍចំណេះដឹង<br>ដៃគូភាព |
| **កម្រិតទី ៤: ប្រសិទ្ធភាពនៃរចនាសម្ព័ន្ធស្ថាប័ន**<br>ការប្រើប្រាស់ធនធានមនុស្ស<br>ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ<br>ដំណើរការ និងការអនុវត្តពាណិជ្ជកម្ម |

[ក] ក្របខ័ណ្ឌលទ្ធផល នឹងត្រូវកែសម្រួល ហើយសូចនាករ រង្វាស់ និងគោលដៅ នឹងត្រូវអភិវឌ្ឍ ។ ក្របខ័ណ្ឌលទ្ធផលចុងក្រោយ នឹងត្រូវដាក់ជូនទៅក្រុមប្រឹក្សាដើម្បីពិនិត្យអនុម័ត ។

**អំពីសៀវភៅនេះ**

តំបន់អាស៊ី ប៉ាស៊ីហ្វិក កំពុងតែមានការរីកចម្រើនយ៉ាងឆាប់រហ័ស ប៉ុន្តែទន្ទឹមនឹងនេះ ក៏មានការព្រួយបារម្ភពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នារបស់ខ្លួន ផលប៉ះពាល់លើបរិស្ថាន និងនិរន្តរភាព ដែលតម្រូវឱ្យមានយុទ្ធវិធីអភិវឌ្ឍន៍ថ្មីៗ គំនិតច្នៃប្រឌិត និងសកម្មភាពប្រកបដោយកិច្ចសហប្រតិបត្តិការ។ ដោយទទួលស្គាល់ពីតម្រូវការផ្លាស់ប្តូរ ទើបយុទ្ធសាស្ត្រឆ្នាំ ២០២០ តម្រូវឱ្យ ADB រៀបចំមុខងាររបស់ខ្លួនឡើងវិញនៅក្នុងការវិវត្តនៃរចនាសម្ព័ន្ធជំនួយអន្តរជាតិ កំណត់នូវការយកចិត្តទុកដាក់លើប្រតិបត្តិការ និងដាក់ចេញនូវគោលដៅប្រតិបត្តិការយុទ្ធសាស្ត្រ និងស្ថាប័ន។ ក្រោមយុទ្ធសាស្ត្រឆ្នាំ ២០២០ ADB នឹងព្យាយាមសម្រេចឱ្យបាននូវឧត្តមភាពក្នុងការវិនិយោគ និងជំនួយដែលផ្អែកលើមូលដ្ឋានចំណេះដឹងរបស់ខ្លួន ដោយចាត់ចែងជំនួយឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលកាន់តែប្រសើរឡើងថែមទៀត។ យុទ្ធសាស្ត្រឆ្នាំ ២០២០នឹងជួយ ADB ឱ្យសម្រេចបាននូវសក្តានុពលពេញលេញរបស់ខ្លួនក្នុងការផ្តល់ផលប្រយោជន៍ដល់តំបន់ និងសហគមន៍អន្តរជាតិ។

**អំពីធនាគារអភិវឌ្ឍន៍អាស៊ី**

ទស្សនវិស័យរបស់ ADB គឺប្រែក្លាយតំបន់អាស៊ី ប៉ាស៊ីហ្វិក ឱ្យរួចផុតពីភាពក្រីក្រ។ បេសកកម្មរបស់ ADB គឺដើម្បីជួយបណ្តាប្រទេសកំពុងអភិវឌ្ឍដែលជាសមាជិករបស់ខ្លួន ក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព និងកែលម្អគុណភាពនៃការរស់នៅរបស់ប្រជាជននៃប្រទេសទាំងនោះ។ ថ្វីបើបានទទួលជោគជ័យជាច្រើនក៏ដោយ ក៏តំបន់នេះនៅតែមានប្រជាជនគឺពីរភាគបីនៃប្រជាជនក្រីក្រនៅលើពិភពលោក។ ប្រជាជននៅក្នុងតំបន់ប្រមាណ ១.៧ ពាន់លាននាក់ រស់នៅដោយមានប្រាក់ចំណូល ២ ដុល្លារ ឬតិចជាងនេះ ក្នុងមួយថ្ងៃ។ ADB បានប្តេជ្ញាកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ចចម្រុះ កំណើនប្រកបដោយនិរន្តរភាពបរិស្ថាន និងការធ្វើសមាហរណកម្មក្នុងតំបន់។

ដោយមានមូលដ្ឋាននៅទីក្រុងម៉ានីល ADB មានប្រទេសជាសមាជិកចំនួន ៦៧ ក្នុងនោះ ៤៨ នៅក្នុងតំបន់។ វិធានសំខាន់ៗដែល ADB ប្រើប្រាស់សម្រាប់ជួយបណ្តាប្រទេសកំពុងអភិវឌ្ឍដែលជាសមាជិករបស់ខ្លួន រួមមាន ការពិភាក្សាគោលនយោបាយ ការផ្តល់ប្រាក់កម្ចី ការវិនិយោគសមធម៌ ការធានា ការផ្តល់ជំនួយឥតសំណង និងជំនួយបច្ចេកទេស។ នៅឆ្នាំ ២០០៧ ADB បានអនុម័តផ្តល់ប្រាក់កម្ចីចំនួន ១០.១ ពាន់លានដុល្លារ គម្រោងជំនួយឥតសំណងចំនួន ៦៧៣ លានដុល្លារ និងជំនួយបច្ចេកទេសមានចំនួន ២៤៣ លានដុល្លារ។

**ធនាគារអភិវឌ្ឍន៍អាស៊ី**
6 ADB Avenue Mandluyong City
1550 Metro Manila Philippines
www.adb.org

**សន្និធិបោះពុម្ពលេខ** : PRF137908